ធនាគារ ស្ថាបនា
SATHAPANA BANK




# 2018
# របាយការណ៍ប្រចាំឆ្នាំ

រីករាយជាមួយនឹងការរស់នៅប្រកបដោយ
ភាពងាយស្រួល **បែបស៊ីវិល័យ**
របស់អ្នកដោយមិនចាំបាច់ប្រើប្រាស់
សាច់ប្រាក់





“ធនាគាររបស់ប្រជាជន”
យើងនឹងបន្តលើកតម្កើង
សេវាកម្មអតិថិជន និងពង្រីកអាជីវកម្ម
ជាមួយនឹងគំនិតច្នៃប្រឌិត និង
ស្មារតីជាអ្នកដឹកនាំ

# មាតិកា


អំពីធនាគារ ស្ថាបនា 4
ការវិវឌ្ឍន៍របស់ធនាគារ 6
តំបន់ប្រតិបត្តិការ 7
បណ្តាញសាខា ធនាគារ ស្ថាបនា 8
ចក្ខុវិស័យ និង បេសកកម្ម 10
សារពីប្រធានក្រុមប្រឹក្សាភិបាល 12
សារពីប្រធាននាយកប្រតិបត្តិ 13
រចនាសម្ព័ន្ធ ធនាគារ 14
ក្រុមប្រឹក្សាភិបាល 16
គណៈកម្មការប្រតិបត្តិ 20
របាយការណ៍ហិរញ្ញវត្ថុសង្ខេប 24
ព័ត៌មានសំខាន់ៗអំពីអាជីវកម្ម ឆ្នាំ2018 26
សមិទ្ធផលឆ្នាំ2018 28
ការអភិវឌ្ឍន៍និយោជិត 33
ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចសាជីវកម្ម 34
ចីរភាពបរិស្ថាន និងសង្គម 36
ទំនួលខុសត្រូវសង្គម 37
ផ្នែកសវនកម្ម និងការត្រួតពិនិត្យផ្ទៃក្នុង 38
របាយការណ៍ហិរញ្ញវត្ថុសម្រាប់កាលបរិច្ឆេទ ដែលបានបញ្ចប់
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 និងរបាយការណ៍របស់សវនករឯករាជ្យ 39



# អំពីធនាគារ ស្ថាបនា

ធនាគារស្ថាបនា គឺជាធនាគារពាណិជ្ជឈានមុខគេមួយនៅកម្ពុជា ដែលមានទ្រព្យសកម្មសរុបលើសពី 1.3 ពាន់លានដុល្លារអាមេរិក និងមានបុគ្គលិកបម្រើការងារច្រើនជាង 4,000 នាក់។

យើងមានបណ្តាញសាខាធំជាងគេទីពីរនៅក្នុងប្រទេសកម្ពុជា ចំនួន 171 សាខា និងម៉ាស៊ីនអេធីអឹមចំនួន 151 គ្រឿង ដែលមានសមត្ថភាពទទួលយកក្រដាសប្រាក់ ដកប្រាក់ និងធ្វើការទូទាត់ប្រាក់។ យើងផ្តល់សេវាកម្មធនាគារដ៏ពេញលេញ ដូចជា សេវាប្រាក់កម្ចី សេវាប្រាក់បញ្ញើ សេវា iBanking សេវាធនាគារតាមទូរស័ព្ទដៃ សេវាប័ណ្ណឥណពន្ធនិងប័ណ្ណឥណទានប្រភេទវីសា សេវាផ្ទេរប្រាក់ក្នុងស្រុកនិងក្រៅប្រទេស សេវាផ្ទេរប្រាក់ជុំវិញពិភពលោក (Western Union) ហិរញ្ញវត្ថុពាណិជ្ជកម្ម និងសេវាកម្មផ្សេងៗទៀតជាច្រើន។

យើងបានសហការជាមួយក្រុមហ៊ុនដៃគូ ដើម្បីផ្តល់សេវាកម្មទូទាត់ប្រាក់ចល័តតាមទូរស័ព្ទដៃ Wing និង PiPay ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនរបស់យើង។

ទ្រព្យសកម្ម
**1.3 ពាន់លានដុល្លារអាមេរិក**

ប្រាក់ចំណេញសុទ្ធ (ក្រោយបង់ពន្ធ)
**23.1 លានដុល្លារអាមេរិក**

អតិថិជនដាក់ប្រាក់បញ្ញើលើសពី
**358,000 នាក់**

អតិថិជនទទួលសេវាឥណទាន
**លើសពី 131,000 នាក់**

បុគ្គលិកបម្រើការងារលើសពី
**4,000 នាក់**

# “ដើម្បីក្លាយជាធនាគារពាណិជ្ជឈានមុខគេនៅកម្ពុជា”







លោកអ្នកអាចធ្វើប្រតិបត្តិការធនាគារ តាមរយៈបណ្តាញសាខា និងបណ្តាញអេធីអឹមរបស់យើងនៅទូទាំងប្រទេស និងបណ្តាញធនាគារឌីជីថល។

សេវាកម្មធនាគារពេញលេញរបស់យើងបើកឱកាសដើម្បីលើកកម្ពស់អាជីវកម្ម ដើម្បីទទួលបានភាពជោគជ័យ និងធ្វើឱ្យប្រសើរឡើងនូវស្តង់ដាររស់នៅរបស់ប្រជាជនកម្ពុជា។

## ធ្វើឲ្យជីវិតកាន់តែប្រសើរឡើង

# ការវិវឌ្ឍន៍របស់ ធនាគារ ស្ថាបនា

**1995**

អង្គការស្ថាបនាសហគមន៍កម្ពុជា (CCB) ត្រូវបានបង្កើតឡើងជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ

**2000**

CCB បានផ្លាស់ប្តូរពីអង្គការក្រៅរដ្ឋាភិបាលទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI)

**2003**

ទទួលបានអាជ្ញាប័ណ្ណក្រុមហ៊ុនឯកជនពីក្រសួងពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា ប្តូរឈ្មោះទៅជាស្ថាបនា សហគ្រិន កម្ពុជា លីមីតធីត (CEB)

**2008**

បានប្តូរឈ្មោះទៅជាស្ថាបនា លីមីតធីត ហើយបានយករូបរាជសីហ៍ដែលជាសត្វចតុបាតមកធ្វើជានិមិត្តសញ្ញាផ្លូវការរបស់ខ្លួន

ម៉ារ៉ូហាន់ ធនាគារ ជប៉ុន ភីអិលស៊ី ត្រូវបានបង្កើតឡើងជាធនាគារពាណិជ្ជដែលមានអាជ្ញាប័ណ្ណពេញលេញ

**2009**

ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដំបូងបង្អស់ដែលទទួលបានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា

**2011**

ទទួលបានពានរង្វាន់ Chief Security Officer (CSO) ASEAN Award (CSO) ពីអង្គការទិន្នន័យអន្តរជាតិ (IDG)

**2012**

ម៉ារ៉ូហាន់ ធនាគារ ជប៉ុន បានក្លាយជាម្ចាស់ភាគហ៊ុនធំជាងគេរបស់ស្ថាបនាលីមីតធីត

**2013**

ស្ថាបនាលីមីតធីតមានវត្តមាននៅទូទាំង 25 ខេត្តក្រុង

**2014**

បានដាក់ដំណើរការសេវា អេធីអឹម

ទទួលបានងារជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខ្នាតតូច និងមធ្យមឆ្នើម (Outstanding Retail MFI) ពីអង្គការទិន្នន័យអន្តរជាតិ (IDG)

**2016**

ស្ថាបនាលីមីតធីតបានរួមបញ្ចូលគ្នាជាមួយម៉ារ៉ូហាន់ ធនាគារ ជប៉ុន ដើម្បីបង្កើតជាធនាគារស្ថាបនា ដែលមានអាជ្ញាប័ណ្ណពេញលេញជាធនាគារពាណិជ្ជ

**2017**

ទ្រព្យសកម្មសរុបបានកើនដល់ចំនួន**មួយពាន់លានដុល្លារអាមេរិក**

ធនាគារស្ថាបនាដាក់ឲ្យប្រើប្រាស់ស្លាកសញ្ញាថ្មីរបស់ខ្លួន

**2018**

សម្ពោធជាផ្លូវការនូវកម្មវិធី សេវាធនាគារតាមទូរស័ព្ទដៃ Sathapana Mobile និងការដាក់ឲ្យប្រើប្រាស់ម៉ាស៊ីនអេធីអឹមដំណើរការសាច់ប្រាក់ ( ដាក់ប្រាក់តាមម៉ាស៊ីនអេធីអឹម )

បើកដំណើរការប័ណ្ណឥណពន្ធវីសា

ប្រកាសភាពជាដៃគូជាមួយវីង, Pipay និង Western Union

បានដាក់ចេញនូវម៉ាស៊ីនអេធីអឹមដំណើរការសាច់ប្រាក់ ( ដាក់ប្រាក់តាមម៉ាស៊ីនអេធីអឹម )

សាខានៅផ្សារទំនើបអ៊ីអន II បានបើកដំណើរការ

# តំបន់ប្រតិបត្តិការ

គិតត្រឹមខែមេសា ឆ្នាំ2019

## តំបន់ដែលគ្របដណ្តប់

**25**
ខេត្ត/ក្រុង

**197**
ស្រុក/ខណ្ឌ



**1,651**
ឃុំ/សង្កាត់

**14,383**
ភូមិ

## បណ្តាញសាខា

**171**
សាខា

**151**
អេធីអឹម

សេវា
ទូរស័ព្ទចល័ត

**24/7**
ទំនាក់ទំនង
សហការី

# បណ្តាញសាខា ធនាគារ ស្ថាបនា

**សាខា (ក)**: ផ្តល់សេវាកម្មធនាគារពេញលេញទៅតាមតំបន់ប្រតិបត្តការរបស់ខ្លួន។

**សាខា (ខ)**: ស្ថិតក្រោមការគ្រប់គ្រងរបស់សាខា (ក) និងផ្តល់សេវាកម្មធនាគារ ប៉ុន្តែនៅមានកម្រិត។

## រាជធានីភ្នំពេញ

1. សាខា ស្នាក់ការការិយាល័យកណ្តាល (ក)
2. សាខា ចំការមន (ក)
3. សាខា ភ្នំពេញ (ក)
4. សាខា ពោធិ៍សែនជ័យ (ក)
5. សាខា ឫស្សីកែវ (ក)
6. សាខា ព្រែកព្នៅ (ខ)
7. សាខា ផ្សារដើមគរ (ក)
8. សាខា ស្ទឹងមានជ័យ (ក)
9. សាខា ចំការដូង (ក)
10. សាខា ទួលគោក (ក)
11. សាខា ប្រាំពីរមករា (ក)
12. សាខា ចោមចៅ (ក)
13. សាខា ជ្រោយចង្វារ (ក)
14. សាខា ផ្សារហេងលី (ក)
15. សាខា ផ្សារអ៊ីអនម៉ល ២ (ក)
16. សាខា ច្បារអំពៅ (ក)
17. សាខា មាត់ទន្លេ (ក)
18. សាខា ភ្នំពេញថ្មី (ក)

## ខេត្តកណ្តាល

1. សាខា ខេត្តកណ្តាល (ក)
2. សាខា ស្រុកស្អាង - ឃុំស្វាយរលំ (ខ)
3. សាខា ស្រុកកោះធំ - ឃុំព្រែកថ្មី (ក)
4. សាខា ស្រុកកោះធំ - ឃុំសំពៅពូន (ខ)
5. សាខា ស្រុកកៀនស្វាយ - ឃុំគគីរ (ក)
6. សាខា ស្រុកកៀនស្វាយ - ឃុំសំរោងធំ (ខ)
7. សាខា ស្រុកស្អាង - ឃុំព្រែកគយ (ក)
8. សាខា ស្រុកស្អាង - ឃុំត្រើយស្លា (ខ)
9. សាខា ស្រុកអង្គស្នួល - ឃុំបែកចាន (ក)
10. សាខា ស្រុកកណ្តាលស្ទឹង - ឃុំបារគូ (ក)
11. សាខា ស្រុកកណ្តាលស្ទឹង - ឃុំបឹងខ្យាង (ខ)
12. សាខា ស្រុកមុខកំពូល - ឃុំព្រែកអញ្ចាញ (ក)
13. សាខា ស្រុកខ្សាច់កណ្តាល - ឃុំវិហារសួគ៌ (ក)
14. សាខា ស្រុកមុខកំពូល - ឃុំរកាកោងទី១ (ក)
15. សាខា ស្រុកអង្គស្នួល - ឃុំតំណាក់អំពិល (ក)
16. សាខា ស្រុកពញាឮ - ឃុំទំនប់ធំ (ខ)
17. សាខា ស្រុកស្អាង - ឃុំព្រែកអំបិល (ក)
18. សាខា ស្រុកល្វាឯម - ឃុំកោះរះ (ក)
19. សាខា ស្រុកពញាឮ - ឃុំវិហារហ្លួង (ក)

## ខេត្តសៀមរាប

1. សាខា ខេត្តសៀមរាប (ក)
2. សាខា ស្រុកបន្ទាយស្រី - ឃុំខ្នារសណ្តាយ (ខ)
3. សាខា ស្រុកពួក - ឃុំពួក (ក)
4. សាខា ស្រុកក្រឡាញ់ - ឃុំកំពង់ថ្កូវ (ក)
5. សាខា ស្រុកអង្គរជុំ - ឃុំចារឈូក (ក)
6. សាខា ស្រុកសូទ្រនិគម - ឃុំដំដែក (ក)
7. សាខា ស្រុកស្វាយលើ - ឃុំស្វាយលើ (ខ)
8. សាខា ស្រុកជីក្រែង - ឃុំកំពង់ក្តី (ក)
9. សាខា ស្រុកប្រាសាទបាគង - ឃុំរលួស (ក)
10. សាខា ក្រុងសៀមរាប (ក)
11. សាខា ស្រុកវ៉ារិន - ឃុំ ស្រែណូយ (ក)

## ខេត្តកំពង់ចាម

1. សាខា ខេត្តកំពង់ចាម (ក)
2. សាខា ស្រុកចំការលើ - ឃុំស្វាយទាប (ក)
3. សាខា ស្រុកស្ទឹងត្រង់ - ឃុំមេសរជ្រៃ (ក)
4. សាខា ស្រុកចំការលើ - ឃុំបុសខ្នុរ (ក)
5. សាខា ស្រុកព្រៃឈរ - ឃុំជ្រៃវៀន (ក)
6. សាខា ស្រុកកងមាស - ឃុំពាមជីកង (ខ)
7. សាខា ស្រុកព្រៃឈរ - ឃុំក្រូច (ខ)
8. សាខា ស្រុកជើងព្រៃ - ឃុំសូទិព្វ (ក)
9. សាខា ស្រុកជើងព្រៃ - ឃុំសំពងជ័យ (ខ)
10. សាខា ស្រុកបាធាយ - ឃុំផ្អាវ (ក)
11. សាខា ស្រុកបាធាយ - ឃុំតាំងក្រាំង (ក)
12. សាខា ស្រុកស្ទឹងត្រង់ - ឃុំព្រែកកក់ (ក)
13. សាខា ស្រុកស្ទឹងត្រង់ - ឃុំអារក្សត្នោត (ខ)
14. សាខា ស្រុកកោះសូទិន - ឃុំពាមប្រធ្នោះ (ខ)
15. សាខា ស្រុកកងមាស - ឃុំខ្ចៅ (ខ)
16. សាខា ស្រុកស្រីសន្ធរ - ឃុំព្រែកពោធិ (ក)

## ខេត្តត្បូងឃ្មុំ

1. សាខា ក្រុងសួង (ក)
2. សាខា ស្រុកត្បូងឃ្មុំ - ឃុំរកាពប្រាំ (ខ)
3. សាខា ស្រុកអូររាំងឪ - ឃុំអំពិលតាពក (ក)
4. សាខា ស្រុកមេមត់ - ឃុំមេមត់ (ក)
5. សាខា ស្រុកមេមត់ - ឃុំកំពាន់ (ខ)
6. សាខា ស្រុកតំបែរ - ឃុំតំបែរ (ខ)
7. សាខា ស្រុកក្រូចឆ្មារ - ឃុំក្រូចឆ្មារ (ខ)
8. សាខា ស្រុកពញាក្រែក - ឃុំកោងកាង (ក)
9. សាខា ស្រុកពញាក្រែក - ឃុំក្រែក (ក)

## ខេត្តបាត់ដំបង

1. សាខា ខេត្តបាត់ដំបង (ក)
2. សាខា ស្រុកថ្មគោល - ឃុំតាម៉ឺន (ក)
3. សាខា ស្រុកបវេល - ឃុំបវេល (ក)
4. សាខា ស្រុកមោងឫស្សី - ឃុំគារ (ក)
5. សាខា ស្រុកគាស់ក្រឡ - ឃុំគាស់ក្រឡ (ខ)
6. សាខា ស្រុកភ្នំព្រឹក - ឃុំពេជ្រចិន្តា (ក)
7. សាខា ស្រុកកំរៀង - ឃុំបឹងរាំង (ក)
8. សាខា ស្រុកសំពៅលូន - ឃុំសន្តិភាព (ក)
9. សាខា ស្រុករតនមណ្ឌល - ឃុំស្ដៅ (ក)
10. សាខា ស្រុកសំឡូត - ឃុំតាសាញ (ក)
11. សាខា ក្រុងបាត់ដំបង (ក)

## ខេត្តកំពង់ធំ

1. សាខា ខេត្តកំពង់ធំ (ក)
2. សាខា ស្រុកកំពង់ស្វាយ - ឃុំសាន់គ (ក)
3. សាខា ស្រុកសន្ទុក - ឃុំកំពង់ថ្ម (ក)
4. សាខា ស្រុកសន្ទុក - ឃុំតាំងក្រសាំង (ក)
5. សាខា ស្រុកបារាយណ៍ - ឃុំក្រវ៉ា (ក)
6. សាខា ស្រុកបារាយណ៍ - ឃុំទ្រៀល (ក)
7. សាខា ស្រុកបារាយណ៍ - ឃុំសូយោង (ក)
8. សាខា ស្រុកស្ទោង - ឃុំកំពង់ចិនជើង (ក)

## ខេត្តកំពង់ស្ពឺ

1. សាខា ខេត្តកំពង់ស្ពឺ (ក)
2. សាខា ស្រុកភ្នំស្រួច - ឃុំគិរីវន្ត (ខ)
3. សាខា ស្រុកឧដុង្គ - ឃុំក្រាំងចេក (ខ)
4. សាខា ស្រុកគងពិសី - ឃុំស្នំក្រពើ (ក)
5. សាខា ស្រុកគងពិសី - ឃុំស្រង់ (ខ)
6. សាខា ស្រុកបរសេដ្ឋ - ឃុំស្វាយរំពារ (ក)
7. សាខា ស្រុកភ្នំស្រួច - ឃុំត្រែងត្រយឹង (ក)

## ខេត្តកំពង់ឆ្នាំង

1. សាខា ខេត្តកំពង់ឆ្នាំង (ក)
2. សាខា ស្រុកបរិបូណ៌ - ឃុំពន្លៃ (ខ)
3. សាខា ស្រុកទឹកផុស - ឃុំអភិវឌ្ឍន៍ (ក)
4. សាខា ស្រុកកំពង់ត្រឡាច - ឃុំអូរឫស្សី (ក)
5. សាខា ស្រុកសាមគ្គីមានជ័យ - ឃុំស្វាយជុក (ខ)



## ខេត្តកំពត

1. សាខា ខេត្តកំពត (ក)
2. សាខា ស្រុកឈូក - ឃុំឈូក (ក)
3. សាខា ស្រុកជុំគិរី - ឃុំត្រពាំងរាំង (ខ)
4. សាខា ស្រុកកំពង់ត្រាច - ឃុំកំពង់ត្រាចខាងកើត (ក)
5. សាខា ស្រុកបន្ទាយមាស - ឃុំទូកមាសខាងលិច (ខ)
6. សាខា ស្រុកអង្គរជ័យ - ឃុំភ្នំកុង (ក)

## ខេត្តពោធិ៍សាត់

1. សាខា ខេត្តពោធិ៍សាត់ (ក)
2. សាខា ស្រុកក្រគរ - ឃុំអន្លង់ត្នោត (ខ)
3. សាខា ស្រុកភ្នំក្រវាញ - ឃុំលាច (ក)
4. សាខា ស្រុកបាកាន - ឃុំបឹងខ្នារ (ក)
5. សាខា ស្រុកបាកាន - ឃុំត្រពាំងជង (ខ)

## ខេត្តបន្ទាយមានជ័យ

1. សាខា ខេត្តបន្ទាយមានជ័យ (ក)
2. សាខា ស្រុកព្រះនេត្រព្រះ - ឃុំជប់វារី (ខ)
3. សាខា ស្រុកមង្គលបូរី - ឃុំឫស្សីក្រោក (ក)
4. សាខា ក្រុងប៉ោយប៉ែត (ក)
5. សាខា ក្រុងប៉ោយប៉ែត - សង្កាត់និមិត្ត (ខ)
6. សាខា ស្រុកថ្មពួក - ឃុំថ្មពួក (ក)
7. សាខា ស្រុកម៉ាឡៃ - ឃុំម៉ាឡៃ (ខ)
8. សាខា ស្រុកស្វាយចេក - ឃុំរលួស (ខ)

## ខេត្តព្រះសីហនុ

1. សាខា ខេត្តព្រះសីហនុ (ក)
2. សាខា ស្រុកស្ទឹងហាវ - ឃុំទំនប់រលក (ខ)
3. សាខា ស្រុកព្រៃនប់ - ឃុំវាលរេញ (ក)

## ខេត្តកែប

1. សាខា ខេត្តកែប (ខ)

## ខេត្តតាកែវ

1. សាខា ខេត្តតាកែវ (ក)
2. សាខា ស្រុកទ្រាំង - ឃុំស្មោង (ខ)
3. សាខា ស្រុកត្រាំកក់ - ឃុំអង្គតាសោម (ក)
4. សាខា ស្រុកគីរីវង់ - ឃុំព្រះបាទជាន់ជុំ (ក)
5. សាខា ស្រុកបាទី - ឃុំត្រពាំងសាប (ក)
6. សាខា ស្រុកព្រៃកប្បាស - ឃុំព្រៃល្វា (ក)

## ខេត្តព្រៃវែង

1. សាខា ខេត្តព្រៃវែង (ក)
2. សាខា ស្រុកស្វាយអន្ទរ - ឃុំស្វាយអន្ទរ (ខ)
3. សាខា ស្រុកពាមរក៍ - ឃុំព្រែកខ្សាយ ខ (ក)
4. សាខា ស្រុកបាភ្នំ - ឃុំឈើកាច់ (ខ)
5. សាខា ស្រុកព្រះស្ដេច - ឃុំអង្គររាជ្យ (ក)
6. សាខា ស្រុកកំពង់ត្របែក - ឃុំប្រាសាទ (ក)
7. សាខា ស្រុកមេសាង - ឃុំជីផុច (ក)
8. សាខា ស្រុកកំចាយមារ - ឃុំស្មោងខាងជើង (ក)
9. សាខា ស្រុកពារាំង - ឃុំរកា (ក)
10. សាខា ស្រុកកញ្ជៀច - ឃុំថ្មពូន (ក)

## ខេត្តស្វាយរៀង

1. សាខា ខេត្តស្វាយរៀង (ក)
2. សាខា ក្រុងបាវិត - សង្កាត់ច្រកម្ទេស (ខ)
3. សាខា ស្រុកកំពង់រោទិ៍ - ឃុំញរ (ខ)
4. សាខា ស្រុកស្វាយជ្រំ - ឃុំស្វាយជ្រំ (ខ)
5. សាខា ស្រុករមាសហែក - ឃុំកំពង់ត្រាច (ក)
6. សាខា ក្រុងបាវិត (ក)

## ខេត្តក្រចេះ

1. សាខា ខេត្តក្រចេះ (ក)
2. សាខា ស្រុកឆ្លូង - ឃុំឆ្លូង (ក)
3. សាខា ស្រុកស្នួល - ឃុំស្នួល (ក)

## ខេត្តរតនគិរី

1. សាខា ខេត្តរតនគិរី (ក)
2. សាខា ស្រុកវើនសៃ - ឃុំប៉ុង (ខ)
3. សាខា ស្រុកកូនមុំ - ឃុំត្រពាំងច្រេស (ក)
4. សាខា ស្រុកបរកែវ - ឃុំឡាមីញ (ក)
5. សាខា ស្រុកអូរយ៉ាដាវ - ឃុំលំជ័រ (ក)

## ខេត្តកោះកុង

1. សាខា ខេត្តកោះកុង (ក)
2. សាខា ស្រុកស្រែអំបិល - ឃុំស្រែអំបិល (ក)

## ខេត្តប៉ៃលិន

1. សាខា ខេត្តប៉ៃលិន (ក)

## ខេត្តស្ទឹងត្រែង

1. សាខា ខេត្តស្ទឹងត្រែង (ក)
2. សាខា ស្រុកសៀមបូក - ឃុំអូរឫស្សីកណ្ដាល (ខ)

## ខេត្តឧត្តរមានជ័យ

1. សាខា ខេត្តឧត្តរមានជ័យ (ក)
2. សាខា ស្រុកបន្ទាយអំពិល - ឃុំគោកមន (ខ)
3. សាខា ស្រុកអន្លង់វែង - ឃុំអន្លង់វែង (ក)
4. សាខា ស្រុកត្រពាំងប្រាសាទ - ឃុំត្រពាំងប្រាសាទ (ក)

## ខេត្តមណ្ឌលគិរី

1. សាខា ខេត្តមណ្ឌលគិរី (ក)
2. សាខា ស្រុកកែវសីមា - ឃុំស្រែខ្ទុម (ក)

## ខេត្តព្រះវិហារ

1. សាខា ខេត្តព្រះវិហារ (ក)
2. សាខា ស្រុកគូលែន - ឃុំគូលែនត្បូង (ក)
3. សាខា ស្រុករវៀង - ឃុំរបៀប (ក)

# ចក្ខុវិស័យ

“ គឺជាធនាគារដែលឈានមុខគេ និងគួរអោយ
ទុកចិត្តបំផុត ក្នុងការផ្តល់សេវាកម្មធនាគារពេញលេញ
ទូទាំងព្រះរាជាណាចក្រកម្ពុជា ”





# បេសកកម្ម

“ ជួយលើកកម្ពស់អាជីវកម្ម និងការរស់នៅរបស់ប្រជាជនតាមរយៈការផ្តល់សេវាកម្មធនាគារពេញលេញជាមួយនឹងបច្ចេកវិទ្យាទំនើបទូទាំងប្រទេស និងរួមចំណែកដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃព្រះរាជាណាចក្រកម្ពុជា ”





# សារពី ប្រធានក្រុមប្រឹក្សាភិបាល

នៅឆ្នាំ2018 យើងបានបន្តការប្តេជ្ញាចិត្តឥតឈប់ឈរក្នុងការបង្កើតគុណតម្លៃប្រកបដោយនិរន្តភាពសម្រាប់អតិថិជន ភាគីពាក់ព័ន្ធ និងសហគមន៍យើង។ នៅឆ្នាំទីបី ចាប់តាំងពីយើងបានបញ្ចូលក្រុមហ៊ុនជាមួយគ្នា យើងសម្រេចបានសមិទ្ធផលដ៏រឹងមាំជាថ្មីម្តងទៀតដោយទទួលបានកំណើន ប្រាក់ចំណេញ ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងការរីកចម្រើនដ៏រឹងមាំ។

ការប្រើប្រាស់ក្នុងស្រុក និងការនាំចេញដែលមានដំណើរការល្អបានជំរុញឱ្យមានកំណើនសេដ្ឋកិច្ចកម្ពុជា ទោះបីសេដ្ឋកិច្ចសកលលោកមានកំណើនក្នុងកម្រិតមធ្យម និងមានហានិភ័យ កើនឡើងក្តី។ អត្រាកំណើនត្រូវបានរំពឹងថានឹងកើនឡើងបន្តិចបន្តួចដល់ 7.1% នៅឆ្នាំ2018 បើធៀបជាមួយកំណើននៅឆ្នាំ2017 ដែលមានចំនួន 6.8%។ នៅក្នុងវិស័យហិរញ្ញវត្ថុ ការគំរាមកំហែងមានការប្រែប្រួល ដោយសារតែការប្រែប្រួលខ្លាំងនៃវិស័យសំណង់ និងអចលនទ្រព្យ។

ប៉ុន្តែ ទោះបីមានហានិភ័យខាងក្រៅ និងបញ្ហាប្រឈមផ្នែកអាជីវកម្មនៅក្នុងប្រទេសក្តី ក៏ធនាគារស្ថាបនាទទួលបានប្រាក់ចំណេញសុទ្ធចំនួន 23 លានដុល្លារអាមេរិកនៅដំណាច់ឆ្នាំនេះ ដោយមានកំណើនគួរឱ្យកត់សម្គាល់ 24% ដែលកាលពីឆ្នាំមុនមានតែ 18.6 លានដុល្លារអាមេរិកប៉ុណ្ណោះ។ ទ្រព្យសកម្មសរុបមានដល់ទៅ 1.304 ពាន់លានដុល្លារអាមេរិក ហើយផលលើមូលធន (ROE) មានចំនួន 13.03% ដែលខ្ពស់ជាងឆ្នាំមុន 12.05%។

លទ្ធផលហិរញ្ញវត្ថុយើងបានបង្ហាញពីភាពសមស្របនៃយុទ្ធសាស្ត្រ ភាពទាក់ទាញនៃផលិតផល និងការផ្តល់សេវាកម្មរបស់យើងព្រមទាំងកិច្ចខិតខំប្រឹងប្រែងធ្វើការ និងកិច្ចសហការនៅក្នុងក្រុមការងាររបស់ធនាគារស្ថាបនាផងដែរ។

ដើម្បីសម្រេចបេសកកម្មរបស់យើងនៅក្នុងការលើកកម្ពស់អាជីវកម្ម និងជីវភាពរបស់ប្រជាជនកម្ពុជា តាមរយៈសេវាធនាគារពេញលេញល្អបំផុត ដោយប្រើបច្ចេកវិទ្យាទំនើប យើងបានចាប់ផ្តើម និងខិតខំប្រឹងប្រែងក្នុងការកសាងម៉ាកសញ្ញាថ្មី និងការផ្លាស់ប្តូរប្រព័ន្ធឌីជីថលនៃធនាគារស្ថាបនា។

យើងជឿជាក់ថា ដើម្បីផ្តល់សេវាកាន់តែមានប្រសិទ្ធភាព និងកាន់តែល្អថែមទៀតដល់អតិថិជន ដែលចេះតែមានកំណើនកើនឡើង យើងត្រូវបន្តកិច្ចខិតខំប្រឹងប្រែងឱ្យបានខ្លាំងក្លាក្នុងការកសាង ម៉ាកសញ្ញាថ្មី និងអនុវត្តឱ្យបានពេញលេញនូវការផ្លាស់ប្តូរប្រព័ន្ធឌីជីថលនៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ បទពិសោធន៍អតិថិជន និងសេវាកម្មកាន់តែល្អប្រសើរនាំឱ្យអតិថិជនកាន់តែមាន ការចូលរួម និងមានភាពស្មោះស្ម័គ្រចំពោះសេវាកម្ម ដែលធ្វើឱ្យប្រាក់ចំណេញរបស់យើងមានការកើនឡើង។

ក្នុងដំណើរឆ្ពោះទៅមុខ យើងមិនដែលបោះបង់ស្មារតីដែលកំណត់ថា "អតិថិជនជាចម្បង" ឡើយ ហើយយើងប្តេជ្ញាយកចិត្តទុកដាក់ ចំពោះអតិថិជនរបស់យើងប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវជានិច្ច។

តាងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជន និងភាគីពាក់ព័ន្ធរបស់យើង ដែលមានភាពស្មោះស្ម័គ្រ និងជឿជាក់មកលើសេវាកម្មរបស់យើង។ ខ្ញុំសូមសម្តែងនូវការកោតសរសើរអស់ពីដួងចិត្ត ចំពោះបុគ្គលិកធនាគារស្ថាបនាចំនួនជាង 4,000 នាក់ដែលបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍធនាគាររបស់យើង។

ខ្ញុំជឿជាក់ថា យើងនឹងទទួលបានលទ្ធផលល្អប្រសើរនៅក្នុងឆ្នាំ2019 នេះក៏ដូចជាបណ្តាឆ្នាំខាងមុខៗ ទៀតផងដែរ។

ដោយក្តីគោរពអំពីខ្ញុំ



**បណ្ឌិត HAN Chang-Woo**
ប្រធានក្រុមប្រឹក្សាភិបាល



# សារពី ប្រធាននាយកប្រតិបត្តិ

សេដ្ឋកិច្ចសកលលោកបច្ចុប្បន្នមានការរីកច្រើនជាបន្តបន្ទាប់ ដោយសារការរីកចម្រើនយ៉ាងឆាប់រហ័ស ផ្នែកបច្ចេកវិទ្យាថ្មីៗ ជាពិសេសឌីជីថលភាវូបនីយកម្ម ដោយវិស័យហិរញ្ញវត្ថុ គឺជាវិស័យដែលបានប្រឈមនឹងបញ្ហារំខានពីបច្ចេកវិទ្យាទាំងនោះ។ បញ្ហាប្រឈមដែលកើតឡើងដោយសារបច្ចេកវិទ្យាហិរញ្ញវត្ថុ (fintech) បាននាំឱ្យមានភាពចាំបាច់ ដែលស្ថាប័ននានាដូចជាធនាគារត្រូវចូលរួមនៅក្នុងកម្មវិធីហិរញ្ញវត្ថុថ្មីខុសៗគ្នា ដែលអាចជួយតម្រង់ទិសនៅក្នុងផ្លាស់ប្តូរប្រព័ន្ធឌីជីថលឱ្យបានកាន់តែប្រសើរ។ ជាងនេះទៅទៀតឥរិយាបថផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដោយសារការប្រើប្រាស់យ៉ាងទូលំទូលាយនូវបច្ចេកវិទ្យា និងការប្រកួតប្រជែងយ៉ាងខ្លាំងក្លានៅក្នុងចំណោមធនាគារពាណិជ្ជ បាននាំមកនូវបញ្ហាប្រឈមសម្រាប់វិស័យធនាគារ និងឱកាសដ៏ល្អ សម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុធំៗ ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង 20 ឆ្នាំកន្លងមកនេះ ដូចជាធនាគារស្ថាបនាជាដើម។

អស់រយៈពេលជាងមួយឆ្នាំហើយ ដែលយើងបានចាប់ផ្តើមធ្វើការផ្លាស់ប្តូរដើម្បីកែលម្អគ្រឹះស្ថានធនាគារ និងគំរូអាជីវកម្មឱ្យកាន់តែប្រសើរឡើង ដើម្បីឱ្យយើងអាចដោះស្រាយបញ្ហាបច្ចុប្បន្នក៏ដូចជា អនាគត។

នៅឆ្នាំ2018 យើងយកចិត្តទុកដាក់ទៅលើការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដើម្បីអភិវឌ្ឍសមត្ថភាពកម្មវិធីបច្ចេកវិទ្យា ដែលនឹងបំពេញវិសាលភាពទាំងមូលនៃអាជីវកម្ម ដែលរីកធំជាងមុនរបស់យើង។ ចំណុចគួរកត់សម្គាល់នៃការអភិវឌ្ឍរបស់យើង គឺជាការដាក់ឱ្យដំណើរការនូវកម្មវិធី សេវាធនាគារតាមទូរស័ព្ទថ្មី ដែលមានគោលបំណងក្លាយជាកម្មវិធី សម្រាប់ការរស់នៅដែលមិនត្រឹមតែផ្តល់ប្រតិបត្តិការហិរញ្ញវត្ថុកាន់តែងាយស្រួល និងសុវត្ថិភាពជាងមុនប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ជូនអតិថិជនផងដែរនូវបទពិសោធន៍ប្រើប្រាស់ដ៏អស្ចារ្យ និងពិសេសជាងគេ។

ក្រៅពីសេវាធនាគារតាមទូរស័ព្ទ ធនាគារស្ថាបនាបានដាក់ឱ្យប្រើម៉ាស៊ីនដំណើរការសាច់ប្រាក់ (CRM) ដែលអតិថិជនអាចដាក់ប្រាក់ ដកប្រាក់ ផ្ទេរប្រាក់ ពិនិត្យសមតុល្យសាច់ប្រាក់ ផ្ទេរប្រាក់ទៅកាន់ភាគីទីបី បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទ និងសេវាផ្សេងទៀត តាមរយៈម៉ាស៊ីនអេធីអឹម។

បច្ចុប្បន្ននេះ ធនាគារស្ថាបនាមានលទ្ធភាពកាន់តែខ្ពស់ក្នុងការទទួលផលសេដ្ឋកិច្ចជាបន្តបន្ទាប់ របស់ប្រទេសកម្ពុជា។ យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សេដ្ឋកិច្ចកម្ពុជាបានកើនឡើងចំនួន 7.3% នៅ ឆ្នាំ2018 ហើយរំពឹងថានឹងមានកំណើន 7.1% នៅឆ្នាំ2019 ដែលនឹងមានការគាំទ្រមួយចំណែកធំពីវិស័យឧស្សាហកម្ម និងសេវាកម្ម។ ទន្ទឹមនឹងនេះដែរ អតិផរណាមានកម្រិត 2.5% ថេរ នៅឆ្នាំ2018 ហើយធនាគារកណ្តាលរំពឹងថានឹងកើនឡើង 0.1% នៅឆ្នាំ2019។

ដោយមានការប្តេជ្ញាចិត្ត និងការខិតខំបំពេញការងារពីបុគ្គលិកគ្រប់រូប រួមទាំងយុទ្ធសាស្ត្រសមស្រប យើងសូមបញ្ជាក់ថាធនាគារស្ថាបនាទទួលបានកំណើនប្រាក់ចំណេញសុទ្ធ 24% ដែលមានទឹកប្រាក់ 23.1 លានដុល្លារអាមេរិកនៅឆ្នាំ2018 និង 18.6 លានដុល្លារអាមេរិកនៅឆ្នាំ2017។ ទ្រព្យសកម្មសរុបបានកើនដល់ 1.3 ពាន់លានដុល្លារអាមេរិក នៅឆ្នាំ2018 បើធៀបទៅនឹងឆ្នាំ2017 មានតែ 1.02 ពាន់លានដុល្លារអាមេរិកប៉ុណ្ណោះ។ នៅឆ្នាំ2018 យើងទទួលបានអតិថិជនជាច្រើនបន្ថែមទៀតដែលនាំឱ្យមានកំណើនដាក់ប្រាក់បញ្ញើពីអតិថិជនចំនួន30% ពី 618.2 លានដុល្លារអាមេរិក នៅឆ្នាំ2017 ដល់ 804.70 លានដុល្លារអាមេរិកនៅឆ្នាំ2018។ កម្ចីកើនឡើង 27% រហូតដល់ 1.02 ពាន់លានដុល្លារអាមេរិកនៅឆ្នាំ2018 ដែលនៅឆ្នាំ2017 មានតែ 808 លានដុល្លារអាមេរិកប៉ុណ្ណោះ។ យើងបានដំឡើងផលលើមូលធន (ROE) ពី 12.05% នៅឆ្នាំ2017 ដល់ 13.03% នៅឆ្នាំ2018។ បច្ចុប្បន្ន ធនាគារស្ថាបនាមានបណ្តាញធំទូលាយ ដែលមានសាខាចំនួន 171 កន្លែង ម៉ាស៊ីនអេធីអឹម 151 ទីតាំង និងមានបុគ្គលិកចំនួន 4,000 នាក់។

ដោយសារយើងកំពុងបន្តផ្លាស់ប្តូរប្រព័ន្ធឌីជីថល ការពង្រីកបណ្តាញចែកចាយ និងកំណើនភាពជាដៃគូជាមួយគ្រឹះស្ថាន មិនមែនហិរញ្ញវត្ថុផ្សេងៗទៀត យើងមានជំនឿយ៉ាងមុតមាំថា នឹងអាចបំពេញតម្រូវការហិរញ្ញវត្ថុរបស់អតិថិជនយើងតាមរយៈសេវាផ្តោតលើអតិថិជនឈានមុខគេ ផលិតផល និងសេវាកម្មប្រកបដោយភាពច្នៃប្រឌិត និងផ្តោតលើគុណតម្លៃព្រមទាំងសាខា ដែលស្ថិតនៅក្នុងទីតាំង ដែលផ្តល់ភាពងាយស្រួលដល់អតិថិជនផងដែរ។ យើងក៏នឹងខិតខំរិះរកវិធីឱ្យកាន់តែប្រសើរថែមទៀត ដើម្បីផ្តល់សេវាចូលរួមចំណែក និងនាំមកនូវការរីកចម្រើនថ្មីនៅក្នុងសហគមន៍ ដែលយើងផ្តល់សេវា។

យើងតែងតែមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការចូលរួមបណ្តុះបណ្តាល និងបំពាក់បំប៉នដល់ក្រុមការងារយើង ដើម្បីសម្រេចបានសក្តានុភាពពេញលេញ និងគោលដៅការងាររបស់ខ្លួន។ យើងទទួលស្គាល់ថាយើងត្រូវតែធ្វើបដិវត្តន៍គំរូសេវាកម្មរបស់យើង ដើម្បីត្រៀមខ្លួនសម្រាប់អនាគតដ៏ខ្លីខាងមុខនេះ។ ដូចនេះបុគ្គលិករបស់យើងត្រូវចេះសម្របខ្លួនមានភាពស្ទាត់ជំនាញ និងត្រូវបំពាក់បំប៉នជំនាញ និងចំណេះដឹងថ្មីៗ ដើម្បីអាចមានភាពរីកចម្រើនល្អប្រសើរនៅក្នុងពិភពឌីជីថល។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះស្ថាប័ន និងភាគីពាក់ព័ន្ធនានា ដូចជា ធនាគារជាតិនៃកម្ពុជា ដែលបានដឹកនាំគាំទ្រ និងផ្តល់ការប្រឹក្សាដ៏ឈ្លាសវៃ ភាគីពាក់ព័ន្ធ ដៃគូអាជីវកម្ម និងអតិថិជនចំពោះការបន្តផ្តល់ទំនុកចិត្តភាពជឿជាក់ និងស្មោះស្ម័គ្រមកលើធនាគាររបស់យើង ក៏ដូចជាបុគ្គលិកទាំងអស់របស់យើងដែលបានខិតខំប្រឹងប្រែងបំពេញការងារ និងចូលរួមចំណែកដ៏មានតម្លៃផងដែរ។

ដោយក្តីគោរពអំពីខ្ញុំ



**លោក លឹម អូន**
ប្រធាននាយកប្រតិបត្តិ

# រចនាសម្ព័ន្ធ ធនាគារ

## គិតចាប់ពី ខែកុម្ភៈ ឆ្នាំ2019




គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ
គណៈកម្មការគ្រប់គ្រងហានិភ័យ
គណៈកម្មការទ្រព្យសកម្ម និងទ្រព្យអកម្ម
គណៈកម្មការធនធានមនុស្ស
គណៈកម្មការអចិន្ត្រៃយ៍ព័ត៌មានវិទ្យា
គណៈកម្មការលទ្ធកម្ម
នាយកប្រតិបត្តិហិរញ្ញវត្ថុ
នាយកដ្ឋានហិរញ្ញវត្ថុ
នាយកដ្ឋានរតនកិច្ច
នាយកដ្ឋានរដ្ឋបាល
នាយកដ្ឋានធនធានមនុស្ស
នាយកប្រតិបត្តិព័ត៌មានវិទ្យា
នាយកដ្ឋានកម្មវិធីបច្ចេកវិទ្យាព័ត៌មាន
នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ព័ត៌មាន
នាយកដ្ឋានសុវត្ថិភាពព័ត៌មានវិទ្យា
នាយកដ្ឋានគ្រប់គ្រងហានិភ័យ
នាយកដ្ឋាននីតិកម្ម និងប្រតិបត្តិតាម




# ក្រុមប្រឹក្សាភិបាល




01 លោកបណ្ឌិត **HAN Chang-Woo** ( ប្រធានក្រុមប្រឹក្សាភិបាល )

02 លោក **HAN Yu** ( អភិបាល )

03 លោក **HAN Ken** ( អភិបាល )

04 ឯកឧត្តម **SHINOHARA Katsuhiro** ( អភិបាលឯករាជ្យ )

05 ឯកឧត្តម គិម វ៉ាដា ( អភិបាលឯករាជ្យ )

06 លោក ហ៊ុន មុន្នីវណ្ណ ( អភិបាលឯករាជ្យ )

07 លោក លឹម អូន ( ប្រធាននាយកប្រតិបត្តិ )

# ក្រុមប្រឹក្សាភិបាល



**បណ្ឌិត HAN CHANG-WOO**
ប្រធានក្រុមប្រឹក្សាភិបាល

**លោកបណ្ឌិត HAN Chang-Woo** ជាស្ថាបនិក និងជាប្រធានក្រុមហ៊ុន MARUHAN Corporation ក្នុងប្រទេសជប៉ុន ដែលកំពុងធ្វើការផ្គត់ផ្គង់ និងរៀបចំសម្ភារៈកំសាន្តជាច្រើនប្រភេទ។ លោកបានបង្កើតក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ1957 និងបានធ្វើអោយអាជីវកម្មមួយនេះមានការរីវឌ្ឍយ៉ាងលឿន ដែលបានទទួលចំណូលសាច់ប្រាក់ក្នុងការលក់សរុបជាង 25ពាន់លានដុល្លារ ក្នុងមួយឆ្នាំ។ ក្រុមហ៊ុន MARUHAN Corporation ត្រូវបានស្គាល់ថា ជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យឧស្សាហកម្មក្នុងប្រទេសជប៉ុន។ អាជីវកម្មនៃក្រុមហ៊ុនរបស់លោកមានការរីកចំរើនលូតលាស់ និងទទួលបានជោគជ័យជាបន្តបន្ទាប់ គឺបានមកពីការខិតខំអស់ពីកម្លាំងកាយចិត្តរបស់លោកក្នុងការបំពេញតាមតម្រូវការរបស់អតិថិជន និងស្មារតីប្រកួតប្រជែងខ្ពស់របស់លោក។ បច្ចុប្បន្ន លោកកំពុងចូលរួមក្នុងសមាគមន៍មួយចំនួន និងកំពុងបម្រើការជាប្រធានរដ្ឋបាលរបស់ក្រុមហ៊ុន Han Chang-Woo Tetsu Cultural Foundation និងជាប្រធានសមាគមន៍ Kyoto UNESCO Association ជាមន្រ្តីរដ្ឋបាលរបស់សមាគមន៍ Kyoto Chapter United Nations Association of Japan និងជាប្រធាន Tokyo Philharmonic។ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចនយោបាយពីសាកលវិទ្យាល័យ HOSEI University ក្នុងឆ្នាំ1953។



**លោក HAN YU**
អភិបាល

**លោក HAN Yu** ជាប្រធាន និងជាប្រធាននាយកប្រតិបត្តិផ្នែកប្រតិបត្តិការក្រុមហ៊ុន MARUHAN Corporation ដែលបានដឹកនាំបុគ្គលិក 15.000នាក់ និងរក្សាក្រុមហ៊ុន MARUHAN Corporation ជាក្រុមហ៊ុនឈានមុខគេ ក្នុងវិស័យសេវាកម្មកំសាន្តលំដាប់ថ្នាក់ពិភពលោក។ លោកបានចូលបំរើការងារក្នុងក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ1990 ដោយបានបំរើការងារក្នុងតួនាទីសំខាន់ៗ មួយចំនួនដូចជានាយកប្រតិបត្តិផ្នែកជំនួញ និងជានាយកគ្រប់គ្រង។ លោកត្រូវបានតែងតាំងជានាយករងក្នុងឆ្នាំ2006 និងជានាយកក្នុងឆ្នាំ2008។ លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រផ្នែកសិល្បៈ ពីសាកលវិទ្យាល័យ HOSEI ក្នុងឆ្នាំ1988។



**លោក HAN KEN**
អភិបាល

**លោក HAN Ken** បានចូលរួមជាមួយក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ2000។ ចាប់តាំងពីលោកត្រូវបានតែងតាំងជាអភិបាល ក្នុងក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ2007 និងជានាយកប្រតិបត្តិនៅឆ្នាំ2014 កន្លងមក លោកទទួលបន្ទុកផ្នែកគណនេយ្យ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន MARUHAN Corporation ដែលបានពង្រីកប្រតិបត្តិការរបស់ខ្លួន នៅពាសពេញពិភពលោក។ លោកក៏បានបម្រើការក្នុងសកម្មភាព ក្រុមអាជីវកម្មនៅតាមបណ្តាប្រទេសអាស៊ានផងដែរ ក្នុងតួនាទីជា អភិបាល និងជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុន MARUHAN INVESTMENT ASIA PTE. LTD., ដែលមានការិយាល័យកណ្តាលរបស់ MARUHAN Japan ASEAN Financial Group ស្ថិតនៅក្នុងប្រទេស សិង្ហបុរី និងជាអភិបាលរបស់ Sathapana Limited Myanmar និងជាអភិបាល Maruhan Japan Bank Lao។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់ ពីសាកលវិទ្យាល័យ DOSHISHA ក្នុងឆ្នាំ1997។



ឯកឧត្តម SHINOHARA KATSUHIRO
អភិបាលឯករាជ្យ

**ឯកឧត្តម SHINOHARA Katsuhiro** ធ្លាប់មានប្រវត្តិជាមួយប្រទេសកម្ពុជាជាង 40ឆ្នាំកន្លងមកហើយ។ មុនពេលដែលលោកបានបម្រើការជាមន្ត្រីលេខាទូតប្រចាំស្ថានទូតជប៉ុននៅកម្ពុជា លោកបានមកដល់ប្រទេសកម្ពុជាមុនដំបូងនៅឆ្នាំ1967 ក្នុងនាមជា មន្ត្រីទូតរបស់ប្រទេស ជប៉ុន និងបានចំណាយពេល 2ឆ្នាំដំបូងក្នុងវត្តឧណ្ណាលោម ក្នុងរាជធានីភ្នំពេញ ដែលក្នុងនោះ លោកបានចំណាយពេល ៧ខែ បួសជាព្រះសង្ឃ ដើម្បីសិក្សាភាសា និងវប្បធម៌ខ្មែរ។ បន្ទាប់មកលោកបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាចំនួន២លើកទៀត ក្នុងនាមអគ្គទីប្រឹក្សាស្ថានទូតជប៉ុនក្នុងរយៈពេល 3ឆ្នាំម្តងៗ ( ពីឆ្នាំ 1991-1994 និង 2001-2004 )។ លោកបានបង្កើតចំណងមិត្តភាពជាមួយប្រទេសកម្ពុជាយ៉ាងរឹងមាំ ដោយបានបម្រើការជាឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជាចាប់ពីឆ្នាំ2007 រហូតដល់ឆ្នាំ2009។ បច្ចុប្បន្ន លោកជាអភិបាលឯករាជ្យរបស់ ម៉ារ៉ូហាន់ ធនាគារជប៉ុន ហើយលោកក៏ជាអនុប្រធានអង្គការ NGO CIESF Japan (Cambodia International Education Support Foundation) ដែលមានតួនាទីជាប្រធានការិយាល័យតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានទីតាំងនៅរាជធានីភ្នំពេញ។



ឯកឧត្តម គិម វ៉ាដា
អភិបាលឯករាជ្យ

**ឯកឧត្តម គិម វ៉ាដា** មានបទពិសោធន៍ការងាររយៈពេលជាង37ឆ្នាំ នៅធនាគារជាតិនៃកម្ពុជា ដោយចាប់ផ្តើមពីតំណែងជាប្រធានការិយាល័យនៅសាខាខេត្តកណ្តាលរបស់ធនាគារជាតិនៃកម្ពុជា រហូតក្លាយជាអគ្គនាយកនៃអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា។ ក្នុងអំឡុងពេលបំពេញការងារនៅធនាគារជាតិ ឯកឧត្តម បានទទួលបន្ទុក និងមុខតំណែងជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើនជាមួយនឹងបទពិសោធដ៏ទូលំទូលាយក្នុងវិស័យធនាគារ ដោយរួមបញ្ចូលទាំងផ្នែកគ្រប់គ្រងហានិភ័យ (ហានិភ័យទីផ្សារ ឥណទាន សន្ទនីយភាព និងប្រតិបត្តិការជាដើម) អភិបាលកិច្ចនិងយុទ្ធសាស្ត្រអាជីវកម្ម។ ឯកឧត្តម បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំប្រព័ន្ធធនាគារនៅកម្ពុជាឡើងវិញយ៉ាងជោគជ័យក្នុងអំឡុងទសវត្សន៍ឆ្នាំ2000 ក្នុងការបង្កើតឲ្យមានប្រព័ន្ធធនាគារមួយ ដែលមានលក្ខណៈប្រកួតប្រជែងនិងប្រកបដោយសុវត្ថិភាពក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងបានយ៉ាងល្អ ព្រមទាំងបានបង្កើតឲ្យមានការកេណ្ឌប្រមូលប្រាក់បញ្ញើយ៉ាងមានប្រសិទ្ធភាព សម្រាប់ផ្តល់ហិរញ្ញប្បទាន ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជា។ ឯកឧត្តម គិម វ៉ាដា ទទួលបានបរិញ្ញាបត្រច្បាប់ក្នុងឆ្នាំ1975 បរិញ្ញាបត្រធនាគារក្នុងឆ្នាំ1985 និងអនុបណ្ឌិត ផ្នែកគ្រប់គ្រងធុរៈកិច្ច ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យឆាលស្ទឺតប្រទេសអូស្ត្រាលីក្នុងឆ្នាំ2003។ ឯកឧត្តម គិម វ៉ាដា ធ្លាប់ធ្វើជាសាស្ត្រាចារ្យ និងជាវាគ្មិន នៅសាកលវិទ្យាល័យល្បីៗមួយចំនួន នៅប្រទេសកម្ពុជា។ លើសពីនេះ ក្នុងអំឡុងពេល 10ឆ្នាំ ចុងក្រោយនេះ ឯកឧត្តម បានចូលរួមយ៉ាងសកម្មក្នុងនាមជាវាគ្មិនក្នុងសន្និសីទ នឹងសិក្ខាសាលាជាតិ នឹងអន្តរជាតិជាច្រើន ដែលទាក់ទងនឹងក្របខណ្ឌបទប្បញ្ញត្តិត្រួតពិនិត្យ និងការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រមទាំងសេវាធនាគារចល័តក៏ដូចជាបរិយាប័ន្នហិរញ្ញវត្ថុ។ ចំពោះការងារអន្តរជាតិ ឯកឧត្តម បានទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមឥណទានកសិកម្ម និងជនបទតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) ពីខែកក្កដា ឆ្នាំ2012 ដល់ ខែមិថុនាឆ្នាំ2014 និងជាសមាជិកប្រតិបត្តិនៃសហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (AFI) ពីខែមករា ឆ្នាំ2015 ដល់ ខែមិថុនា ឆ្នាំ2017។



លោក ហ៊ុន មុន្នីវណ្ណ
អភិបាលឯករាជ្យ

**លោក ហ៊ុន មុន្នីវណ្ណ** បានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងជំនាញគណនេយ្យ ពីសាកលវិទ្យាល័យ វេទមហាឫស្សី (MVU) នៅឆ្នាំ1997។ បច្ចុប្បន្ន លោក មុន្នីវណ្ណ ជាប្រធានគណៈកម្មការ សវនកម្ម និងជាអភិបាលឯករាជ្យ នៃធនាគារស្ថាបនា ភីអិលស៊ី (Sathapana Bank Plc.) និងជាសមាជិកនៃវិទ្យាស្ថានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនអូស្ត្រាលី (AICD)។ លោក មុន្នីវណ្ណ មានបទពិសោធន៍វិជ្ជាជីវៈធុរៈកិច្ចជាង20ឆ្នាំ ដែលក្នុងនោះ ជិត15ឆ្នាំកន្លងមកនេះ លោកបានបំពេញការងារជាក្រុមប្រឹក្សាភិបាលសំរាប់ក្រុមហ៊ុនជាតិ និងអន្តរជាតិជាច្រើន។ លោក មុន្នីវណ្ណ បានចាប់ផ្តើមអាជីពការងាររបស់គាត់ជាសវនករ នៅក្រុមហ៊ុនសវនកម្ម អឺនអែន យ៉ាំងខេមបូឌា (E&Y Cambodia) អស់រយៈពេល៣ឆ្នាំ និង 8ឆ្នាំទៀត ជានាយកហិរញ្ញវត្ថុ និងជាក្រុមប្រឹក្សាភិបាលក្រុមហ៊ុនសិប្បកអង្គរ។ នៅឆ្នាំ2006 លោក មុន្នីវណ្ណ បានចាប់ផ្តើមការងារជាក្រុមប្រឹក្សាភិបារាជ្យ និងជាប្រធានគណៈកម្មការសវនកម្ម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត (Sathapana Limited) ដែល3ឆ្នាំក្រោយមក គាត់ត្រូវបានជ្រើសតាំងជាប្រធានក្រុមប្រឹក្សាភិបាល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត (SPN) មុនពេលដែល ស្ថាប័នមួយនេះ បានក្លាយជា ធនាគារ ស្ថាបនា ភីអិលស៊ី (Sathapana Bank Plc.) នៅឆ្នាំ2016។ ក្រៅពីនេះ លោក ហ៊ុន មុន្នីវណ្ណ បច្ចុប្បន្ន ក៏ជាក្រុមប្រឹក្សាភិបាលឯករាជ្យ និងជាប្រធានគណៈកម្មការសវនកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) ដែលជាក្រុមហ៊ុនបោះផ្សាយមូលប័ត្រ នៅលើទីផ្សារភាគហ៊ុនកម្ពុជា ជាប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន មេហ្គាលីស៊ីង ភីអិលស៊ី (Mega Leasing Plc.) ជាប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន អេផ្លឹសខនសាល់ធីង (APlus Consulting Co., Ltd.) ជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន អឹមវីយូ អិនវេសមេន ភីអិលស៊ី (MVU Investment Plc.) ជាអនុប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនស៊ីអាយស៊ី អិនវេសមេន ភីអិលស៊ី (CIC Investment Plc.) និងជាអនុប្រធានសភាពាណិជ្ជកម្មមណ្ឌលសៀមរាប ឧត្តរមានជ័យ។




# គណៈកម្មការប្រតិបត្តិ

01 លោក លឹម អូន
02 លោក KENJI KUROKI
03 លោក ស៊ឹយ ប៉ុណ្ណរតន៍
04 លោក រស់ សុខា
05 លោក អ៊ិត ប៊ុនថា

# គណៈកម្មការប្រតិបត្តិ



## លោក លឹម អូន
ប្រធាននាយកប្រតិបត្តិ

លោក លឹម អូន មានបទពិសោធន៍ការងារជាង 20ឆ្នាំ ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនសវនកម្មអន្តរជាតិ។ មុនពេលចូលបំរើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំ ស្ថាបនា លីមីតធីត លោក លឹម អូន ធ្លាប់បានបំរើការងារជាសវនករជាន់ខ្ពស់ នៅក្រុមហ៊ុន ខេភីអឹមជី ខេមបូឌៀ (KPMG Cambodia) ចាប់ពីឆ្នាំ1997 រហូតដល់ ឆ្នាំ2002 ដោយទទួលបានបទពិសោធន៍ការងារ ផ្នែកសវកម្មយ៉ាងទូលំទូលាយ និងបានបំពេញការងារនៅប្រទេសម៉ាឡេស៊ីរយៈពេលមួយឆ្នាំផងដែរ។ ក្នុងឆ្នាំ2002 លោក លឹម អូន បានចូលបំរើការងារនៅធនាគារ វឌ្ឍនៈ ដែលជាធនាគារពាណិជ្ជក្នុងស្រុកមួយ ដោយកាន់នូវមុខតំណែងជាច្រើនដូចជា ប្រធានសាខាជាន់ខ្ពស់នៃសាខាកណ្តាល នាយកនាយកដ្ឋានហិរញ្ញវត្ថុ នាយកនាយកដ្ឋានប្រតិបត្តិការ និងចុងក្រោយជាអគ្គនាយករង រហូតដល់ពេលលាលែងពីធនាគារវឌ្ឍនៈ ក្នុងខែវិច្ឆិកា ឆ្នាំ2002។

លោក លឹម អូន បានចូលបំរើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត ក្នុងនាមជានាយកប្រតិបត្តិ ប្រតិបត្តិការ នាខែធ្នូ ឆ្នាំ2012 និងត្រូវបានតម្លើងតំណែងជាអនុប្រធាននាយកប្រតិបត្តិក្នុងខែសីហា ឆ្នាំ2014 បន្ថែមលើតំណែងបច្ចុប្បន្នជានាយកប្រតិបត្តិ ប្រតិបត្តិការ។ បន្ទាប់ពីការគួបបញ្ចូលគ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត និងម៉ារូហាន់ ធនាគារ ជប៉ុន ក្នុងខែមេសា ឆ្នាំ2016 លោកនៅតែបន្តជាអនុប្រធាននាយកប្រតិបត្តិ និងជានាយកប្រតិបត្តិ ប្រតិបត្តិការ នៃធនគារ ស្ថាបនា រហូតដល់ ខែមករា ឆ្នាំ2019។ ចាប់ពីថ្ងៃទី01 ខែកុម្ភៈ ឆ្នាំ2019 មក លោក លឹម អូន ត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិ នៃធនាគារ ស្ថាបនា ភីអិលស៊ី។ លោកបានទទួលបានបរិញ្ញាបត្រផ្នែកគណនេយ្យពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ1998។



## លោក KENJI KUROKI
អនុប្រធាននាយកប្រតិបត្តិ

លោក Kuroki មានបទពិសោធន៍ការងារក្នុងវិស័យធនាគាររយៈពេលជិត 30ឆ្នាំ ចាប់តាំងពីពេលដែលលោកបានចាប់ផ្តើមអាជីពជាមួយធនាគារ The Sumitomo Bank Limited (បន្ទាប់មកត្រូវបានប្តូរឈ្មោះទៅជាធនាគារ Sumitomo Mitsui Banking Corporation, a.k.a SMBC) ក្នុងឆ្នាំ 1989។ ក្នុងអំឡុងពេលបម្រើការងារជាច្រើនឆ្នាំជាមួយធនាគារ SMBC លោកបានកាន់តំណែងជានាយក នាយកដ្ឋានរៀបចំផែនការនៃធនាគារ បុត្រសម្ព័ន្ធរបស់ SMBC នៅទីក្រុង ហ្សាកាតា ប្រទេសឥណ្ឌូនេស៊ីចាប់ពីឆ្នាំ1996 រហូតដល់ ឆ្នាំ2003 និងជាអគ្គនាយករងនៃធនាគារបុត្រសម្ព័ន្ធមួយទៀតរបស់ SMBC នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ចាប់ពីឆ្នាំ2008 រហូដល់ ឆ្នាំ2015។ លោកបានលាឈប់ពី ធនាគារ SMBC កាលពីខែឧសភា ឆ្នាំ2018 និងបានចូលបម្រើការងារជាមួយ MARUHAN Corporation ដែលជាម្ចាស់ភាគហ៊ុនរបស់ធនាគារស្ថាបនានៅខែមិថុនា ឆ្នាំ2018។ បន្ទាប់មកលោកត្រូវបានតែងតាំងជាអនុប្រធាននាយកប្រតិបត្តិនៃធនាគារ ស្ថាបនា នៅខែកុម្ភៈ ឆ្នាំ2019។ លោកបានបញ្ចប់បរិញ្ញាបត្រជំនាញ Indochinese studies ពី Tokyo University of Foreign Studies។

# គណៈកម្មការប្រតិបត្តិ



## លោក ស៊ឹយ ប៉ុណ្ណរតន៍
នាយកប្រតិបត្តិហិរញ្ញវត្ថុ

លោក ស៊ឹយ ប៉ុណ្ណរតន៍ មានបទពិសោធន៍ការងារជាង 16ឆ្នាំ ជាមួយក្រុមហ៊ុនអន្តរជាតិ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ។ មុនពេលចូលបម្រើការងារនៅក្នុងធនាគារ ស្ថាបនា លោកធ្លាប់ជានាយកចាត់ការទូទៅទទួលបន្ទុក ផ្នែកហិរញ្ញវត្ថុ និងព័ត៌មានវិទ្យានៃក្រុមហ៊ុន តូយ៉ូតា (ខេមបូឌា )។ លោកធ្លាប់ជានាយកប្រតិបត្តិហិរញ្ញវត្ថុនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយក្នុងប្រទេសកម្ពុជា មុនពេលដែលត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិនៃគ្រឹះស្ថាននោះ។ លោកមានបទពិសោធន៍ក្នុងការទំនាក់ទំនងជាមួយនឹងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិជាច្រើន ព្រមទាំងមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងគម្រោងផ្សេងៗ រួមមាន ERP, IT, IFRS និង Core Banking ហើយលោកត្រូវបានទទួលស្គាល់ថា ជាអ្នកជំនាញគ្រប់គ្រងគម្រោង (Project Management Professional) ដោយស្ថាប័នគ្រប់គ្រងគម្រោង (Project Management Institute) នៅសហរដ្ឋអាមេរិកក្នុងឆ្នាំ2017 និង ជា Professional Banker ពី Asian Institute of Chartered Bankers នៅប្រទេសម៉ាឡេស៊ី ហើយលោកក៏ជាសមាជិករបស់ Association of Chartered Certified Accountants (ACCA) នៃចក្រភពអង់គ្លេស។ លោកទទួលបានសញ្ញាបត្រអនុបណ្ឌិត ផ្នែកធុរៈកិច្ចអន្តរជាតិពី Audencia Business School នៅប្រទេសបារាំងក្នុងឆ្នាំ2011។ លោក ប៉ុណ្ណរតន៍ បានចូលបម្រើការងារនៅធនាគារ ស្ថាបនា ក្នុងតួនាទីជានាយកប្រតិបត្តិហិរញ្ញវត្ថុចាប់ពី ខែតុលា ឆ្នាំ2017។



## លោក រស់ សុខា
នាយកប្រតិបត្តិឌីជីថល

លោក រស់ សុខា មានបទពិសោធន៍ការងារជាង 17ឆ្នាំ ក្នុងវិស័យធនាគារ។ មុនពេលលោកចូលបម្រើការងារក្នុងធនាគារ ស្ថាបនា ជានាយកជាន់ខ្ពស់អភិវឌ្ឍន៍ផលិតផល និងបន្ទាប់មកត្រូវបានតែងតាំងជានាយកប្រតិបត្តិធនាគារ ឌីជីថល។ លោកចាប់ផ្តើមអាជីពជាដំបូងនៅសភាពាណិជ្ជកម្មរាជធានីភ្នំពេញ (Phnom Penh Chamber of Commerce) និងក្រោយមកលោកក៏ចាប់យកអាជីព លោកជាអ្នកគ្រប់គ្រងនៅធនាគារ Union Commercial Bank Plc ក្នុងនាយកដ្ឋានប័ណ្ណឥណទានវីសាទទួលបន្ទុកដំណើរការបង្កើតប័ណ្ណវីសាផ្លាទីនីម EMV (Europay, MasterCard, and Visa) ដំបូងបង្អស់ក្នុងប្រទេសកម្ពុជា។ លោកបានបន្តជម្រុញអាជីវកម្មប័ណ្ណ និងការទូទាត់មុនពេលលោកចូលរួមជាមួយធនាគារ ANZ Royal Bank ក្នុងឆ្នាំ2005 ដែលលោកបានធ្វើការជាមួយក្រុមការងារគម្រោងប្រចាំតំបន់ ដើម្បីរៀបចំរបៀបវារៈប្រចាំតំបន់ទាក់ទងនឹងសេវាកម្ម E-Banking ក្នុងគោលបំណងផ្លាស់ប្តូរ និងធ្វើទំនើបកម្មស្ថានភាពធនាគារនៅក្នុងប្រទេសនាពេលនោះ។ ក្រោយមកលោកបានបន្តបេសកម្មទៅធនាគារ ANZ Laos ដើម្បីដឹកនាំ និងផ្លាស់ប្តូរសេវាប័ណ្ណ និង E-Banking។ លោកក៏ជាវាគ្មិនមួយរូបក្នុងវេទិកានានាស្តីពីសេវាហិរញ្ញវត្ថុឌីជីថល (Digital Financial Services) និងទទួលបានការទទួលស្គាល់ និងរង្វាន់ពីស្ថាប័ន IDG សម្រាប់ស្ថាប័នរបស់លោកជាច្រើនផងដែរ។ លោក រស់ សុខា ទទួលបានបរិញ្ញាបត្រពាណិជ្ជកម្មពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងទទួលបានសញ្ញាបត្រអនុបណ្ឌិតពីវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (AIT) ដែលមានដៃគូជាមួយ EcoleSupérieure De Commerce Nantes Atlantique (ESCNA)។



## លោក អ៊ិត ប៊ុនថា
### នាយកប្រតិបត្តិ ប្រតិបត្តិការ

លោក អ៊ិត ប៊ុនថា មានបទពិសោធន៍ការងារជាង 15ឆ្នាំ ជាមួយធនាគារពាណិជ្ជក្នុងស្រុក និងតំបន់នៅប្រទេសកម្ពុជាលើផ្នែកជាច្រើនមានដូចជា ផ្នែកលក់ ឥណទាន និងប្រតិបត្តិការ។ លោក ប៊ុនថា បច្ចុប្បន្នមានមុខតំណែងជានាយកប្រតិបត្តិប្រតិបត្តិការនៅធនាគារ ស្ថាបនា ចាប់ពីខែកុម្ភៈ ឆ្នាំ2019។ លោកបានកាន់តំណែងជានាយកនាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្មនៅធនាគារ ស្ថាបនា ចាប់ពីខែឧសភា ឆ្នាំ2016 ដល់ខែមករា ឆ្នាំ2018។ មុននេះ លោកធ្លាប់បានបម្រើការងារជាមួយធនាគារ CIMB រយៈពេល 5ឆ្នាំ ចាប់ពីខែមេសា ឆ្នាំ2010 ដល់ខែមេសា ឆ្នាំ2016 ក្នុងមុខតំណែងជានាយក Preferred Banking នាយកផ្នែកលក់ និងចែកចាយ និងនាយកសាខា។ ចាប់ពីឆ្នាំ2004 ដល់ឆ្នាំ2009 លោកបានបម្រើការជាមន្ត្រីជាន់ខ្ពស់លើផ្នែកផ្សេងៗ ជាច្រើននៅធនាគារ វឌ្ឍនៈ បន្ទាប់មក លោកបានចូលរួមជាមួយធនាគារ ABA ក្នុងមុខតំណែងជានាយកសាខាក្នុងឆ្នាំ2009។ លោក ប៊ុនថា បាន បញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ មុខជំនាញគ្រប់គ្រងអាជីវកម្ម ពីសាកលវិទ្យាល័យន័រតុន ប្រទេសកម្ពុជា និងបានទទួលបរិញ្ញាបត្រសេដ្ឋកិច្ចជំនាញធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យដដែលនៅឆ្នាំ2002។ ក្នុងឆ្នាំ2013 លោកបានជាប់ជាបេក្ខជនឈានដល់វគ្គផ្តាច់ព្រាត់ សម្រាប់ពានរង្វាន់ Emerald Award as Best Middle Manager របស់ធនាគារ CIMB ហើយលោកក៏បានបញ្ចប់កម្មវិធី Middle Manager របស់ធនាគារ CIMB ដោយជោគជ័យផងដែរ ពោលគឺកម្មវិធី Accelerated Universal Banker (AUB) នៅ Nanyang Business School និង Nanyang Technologies University ក្នុងប្រទេសសិង្ហបុរី។

# របាយការណ៍ហិរញ្ញវត្ថុសង្ខេប

## 1. ទ្រព្យសកម្មសរុប
គិតជាលានដុល្លារអាមេរិក




## 2. មូលធនរបស់ភាគទុនិក
គិតជាលានដុល្លារអាមេរិក




## 3. ឥណទានផ្តល់ឲ្យអតិថិជន
គិតជាលានដុល្លារអាមេរិក




## 4. គុណភាពទ្រព្យសកម្ម
ឥណទានមិនដំណើរការ លើសឬស្មើ ៩០ ថ្ងៃ
ជាចំណែកនៃឥណទានសរុប




## 5. ប្រាក់បញ្ញើពីអតិថិជន
គិតជាលានដុល្លារអាមេរិក




## 6. ប្រាក់ចំណេញសុទ្ធ (ក្រោយបង់ពន្ធ)
គិតជាលានដុល្លារអាមេរិក



## 7. អតិថិជនឥណទាន

អតិថិជនឥណទានសរុបគិតជាពាន់នាក់




## 10. ការបង្វិលចំណូលលើទ្រព្យសកម្ម




## 8. អតិថិជនប្រាក់បញ្ញើ

អតិថិជនប្រាក់បញ្ញើសរុបគិតជាពាន់នាក់




## 11. ការបង្វិលចំណូលលើមូលនិធិម្ចាស់ហ៊ុន




## 9. អនុបាតសាធនភាព



# ព័ត៌មានសំខាន់ៗ អំពីអាជីវកម្ម ឆ្នាំ2018

ធនាគារស្ថាបនា ភីអិលស៊ី មានបំណងក្លាយជាធនាគារពាណិជ្ជឈានមុខគេដ៏ទុកចិត្តបំផុតនៅក្នុងប្រទេសកម្ពុជា ដើម្បីចូលរួមចំណែកលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា តាមរយៈការផ្តល់សេវាកម្មធនាគារពេញលេញនៅទូទាំងប្រទេស ដោយផ្អែកលើមូលដ្ឋានហិរញ្ញវត្ថុរឹងមាំ ប្រកបដោយអភិបាលកិច្ចសាជីវកម្មល្អ ការអនុវត្តតាមច្បាប់ និងតម្លាភាព។

ធនាគារនឹងបង្កើតឱ្យមានវប្បធម៌យុត្តិធម៌ ស្មោះត្រង់ និងតម្លាភាពនៅក្នុងធនាគារ ហើយរក្សាឱ្យបាននូវទំនាក់ទំនងល្អនៅក្នុងស្ថាប័នទាំងមូល ព្រមទាំងលើកទឹកចិត្តឱ្យមានការចូលរួមប្រកបដោយបុរេសកម្មពីបុគ្គលិកទាំងអស់ផងដែរ។







## ភាពងាយស្រួល

ការផ្តល់ភាពងាយស្រួលចំពោះអតិថិជនយើង គឺដើម្បីអាចឱ្យពួកគាត់ដកដាក់ប្រាក់បាន 24 ម៉ោង ក្នុងមួយថ្ងៃ និង 7ថ្ងៃ ក្នុងមួយសប្តាហ៍។ ដូច្នេះហើយ យើងបានទិញម៉ាស៊ីនអេធីអឹមថាច់ស្គ្រីនថ្មី ចំនួន 50 គ្រឿងដែលមានសមត្ថភាពដំណើរការសាច់ប្រាក់ល្អ ដែលសរុបទាំងអស់មានចំនួន 151 គ្រឿងត្រូវបានដាក់ដំណើរការនៅទូទាំងប្រទេស ដើម្បីឱ្យអតិថិជនយើងអាចដកដាក់ប្រាក់បានឆាប់រហ័ស និងមានសុវត្ថិភាព។ យើងយល់ថា ពេលខ្លះ អតិថិជនមានភាពមមាញឹកខ្លាំង ហើយមិនអាចមកជួបយើងបាននៅតាមសាខាបានទេ។ សេវាធនាគារឌីជីថលថ្មី ដែលមានឈ្មោះថា Sathapana Mobile ត្រូវបានដាក់ឱ្យដំណើរការកាលពីខែកញ្ញា ឆ្នាំ2018 ដើម្បីអាចឱ្យអតិថិជនចូលទៅកាន់គណនីរបស់ខ្លួន និងធ្វើប្រតិបត្តិការជាច្រើនប្រភេទបានគ្រប់ពេលវេលា ដោយគ្រាន់តែប្រើម្រាមដៃចុចប៉ុណ្ណោះ។

## អតិថិជនជាអាទិភាព

ក្នុងរយៈពេលបីឆ្នាំចុងក្រោយបន្ទាប់ពីរំលាយបញ្ចូលគ្នា ក្រុមការងាររបស់ធនាគារបានអនុវត្តយុទ្ធសាស្ត្រ ដើម្បីសម្រេចឱ្យបាននូវបទពិសោធន៍សេវាអតិថិជនល្អបំផុតនៅតាមសាខារបស់យើង។ យើងជឿជាក់ថា យើងសម្រេចបានជោគជ័យ ប៉ុន្តែយើងដឹងថា យើងមានការងារជាច្រើនដែលត្រូវអនុវត្ត ដើម្បីក្លាយជាធនាគារឈានមុខគេលើគូប្រកួតប្រជែងរបស់យើង។

## ជួយឱ្យអតិថិជនរបស់យើងរីកចម្រើន

យើងមានមោទនភាពយ៉ាងក្រៃលែង ដែលបានជួយអតិថិជនរបស់យើង ហើយអតិថិជនគឺជាចំណុចគោលដៅសំខាន់នៃការងាររបស់យើង។ អតិថិជនរបស់យើង គឺជាអាទិភាពចម្បង ហើយយើងមានទំនួលខុសត្រូវក្នុងការជួយពួកគាត់ឱ្យរីកចម្រើន។ កំណើននេះអាចមានអត្ថន័យផ្សេងៗគ្នាទៅតាមស្ថានភាពរស់នៅរបស់អតិថិជនម្នាក់ៗ។

# ផលិតផល និងសេវាកម្មរបស់យើងរួមមាន៖

## ប្រាក់បញ្ញើ



- គណនីបញ្ញើសន្សំ
- គណនីបញ្ញើចរន្ត
- គណនីរូបិយប័ណ្ណបរទេស
- គណនីបញ្ញើមានកាលកំណត់
- គណនីសន្សំអាជីវកម្ម

## ឥណទាន



- ឥណទានអាជីវកម្ម
- ឥណទានគេហដ្ឋាន
- ឥណទានបុគ្គល
- ឥណទានយានយន្ត
- ឥណទានវិបារូបវ៍
- ឥណទានទុនបង្វិលរយៈពេលខ្លី
- ហិរញ្ញប្បទានពាណិជ្ជកម្ម

## សេវាកម្ម



- ការផ្ទេរប្រាក់ក្នុងប្រទេស និងក្រៅប្រទេស
- សេវាប្តូរប្រាក់
- សេវាចាត់ចែងសាច់ប្រាក់
- សេវាហិរញ្ញប្បទាន

## បណ្តាញចែកចាយ



- អេធីអឹម express banking
- សេវាធនាគារតាមទូរសព្ទដៃ
- សេវាធនាគារតាមអ៊ីនធឺណេត
- សាខាធនាគារ
- សហការីទំនាក់ទំនង 24/7

# សមិទ្ធផលឆ្នាំ2018

ឆ្នាំ2018 គឺជាឆ្នាំដ៏ល្អប្រសើរ ដែលធនាគារស្ថាបនា ភីអិលស៊ី មានការរីកចម្រើនយ៉ាងរឹងមាំទៅដល់ចំណុចរបត់ថ្មីមួយ ដោយសម្រេចបានលើសពីគោលដៅហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន ជាពិសេស ឥណទាន និងប្រាក់ចំណេញ ដោយរក្សាបាននូវគុណភាពដ៏រឹងមាំនៃការគ្រប់គ្រងដ៏ប្រសើរលើឥណទានមិនដំណើរការ។

## ឥណទាន



នៅឆ្នាំ2018 ធនាគារស្ថាបនា ភីអិលស៊ីទទួលបានកំណើនសំណុំឥណទាន ដោយបានចុះបញ្ជីឥណទាន ដែលនៅសល់សរុបចំនួន 1.026 ពាន់លានដុល្លារអាមេរិក ដែលមានកំណើន 27% ពីឆ្នាំ2017។

កំណើនរឹងមាំអាចសម្រេចទៅបាន ដោយសារមានកត្តាសំខាន់ៗដូចជា ការពង្រីកសាខា ដែលមានការិយាល័យចំនួន 169 កន្លែងនៅទូទាំងប្រទេស ដោយតម្រូវការមានការកើនឡើងនៅក្នុងទីផ្សារ ដោយសារតែស្ថានភាពសេដ្ឋកិច្ចនៅក្នុងឆ្នាំ2018 មានភាពល្អប្រសើរ និងលក្ខខណ្ឌប្រកួតប្រជែង និងភាពទាក់ទាញនៃផលិតផល និងសេវាកម្មយើង ដោយសាធារណជនកាន់តែមានទំនុកចិត្តមកលើធនាគារស្ថាបនា ភីអិលស៊ី។

ដើម្បីជួយពង្រឹងអភិបាលកិច្ចសាជីវកម្ម ធនាគារស្ថាបនា ភីអិលស៊ី បានបន្តគោលការណ៍ប្រយ័ត្នប្រយែងរបស់ខ្លួន នៅក្នុងការវាយតម្លៃសកម្មភាពផ្តល់ឥណទាន ព្រមទាំងសកម្មភាពផ្តល់កម្ចីបុរេសកម្ម ដើម្បីទាក់ទាញអតិថិជនថ្មីៗ និងជួយអតិថិជនក្នុងការប្រើប្រាស់ទឹកប្រាក់របស់ខ្លួន ប្រកបដោយផលចំណេញផងដែរ។

ការគ្រប់គ្រងហានិភ័យឥណទានកំពុងមានស្ថានភាពល្អប្រសើរ។ ធនាគារស្ថាបនា ភីអិលស៊ី ជឿជាក់ថានឹងអាចបន្តគ្រប់គ្រង និងរក្សាបាននូវហានិភ័យឥណទានទាបបំផុត ដោយសារសំណុំឥណទានរបស់ខ្លួនលើសពី 98% មិនត្រូវចាត់ទុកថា បានផុតកាលកំណត់ ឬមិនបានសងឡើយ។ បន្ថែមពីនេះធនាគារមានដំណើរការជ្រើសរើស និងប្រមូលតឹងរ៉ឹងសម្រាប់ការពង្រីកឥណទានជូនដល់អតិថិជន។



## បញ្ញើ

ឆ្នាំ2018 មានកំណើនរឹងមាំនៃសំណុំប្រាក់បញ្ញើសម្រាប់ធនាគារស្ថាបនា ភីអិលស៊ី ដែលនាំឱ្យមានសាច់ប្រាក់ងាយស្រួលថេរ សម្រាប់ឆ្នាំ2018។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 បញ្ញើសរុបរបស់អតិថិជនត្រូវបានចុះបញ្ជីចំនួន 782 លានដុល្លារអាមេរិក ឬមានកំណើន 32% ពីឆ្នាំ2017 ដោយមានការផ្លាស់ប្តូរកំណើននៃបញ្ញើតាមតម្រូវការ និងបញ្ញើមានកាលកំណត់។

មានមូលហេតុបួនដែលចូលរួមចំណែកធ្វើឱ្យមានកំណើនបញ្ញើនៅក្នុងធនាគារ៖

1. បុគ្គលិកទាំងអស់ ដែលធ្វើការនៅធនាគារស្ថាបនាគិតចាប់ពីបេឡាធិការ រហូតដល់អ្នកគ្រប់គ្រងធនាគារមានការចាប់អារម្មណ៍ផ្ទាល់ខ្លួនក្នុងការផ្តល់សេវាធនាគារល្អប្រសើរ នៅក្នុងកម្រិតវិជ្ជាជីវៈ និងតម្លាភាពខ្ពស់បំផុត។ រាល់ប្រតិបត្តិការទាំងអស់សុទ្ធតែធ្វើឡើងដោយមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការផ្តល់ផលិតផលល្អបំផុត ដែលបំពេញតាមតម្រូវការទីផ្សារចុងក្រោយ សេវាដែលអាចទទួលបានដោយងាយស្រួល និងការគ្រប់គ្រងប្រតិបត្តិការល្អបំផុត ដោយមានជំនួយពីបច្ចេកវិទ្យាថ្មីបំផុតនៅក្នុងសម័យកាលឌីជីថល។
2. ទស្សនាទាន «អតិថិជនជាអាទិភាព» បានបង្កប់នៅក្នុងផ្នត់គំនិតរបស់គ្រប់បុគ្គលិក និងប្រធានគ្រប់គ្រងធនាគារស្ថាបនាទាំងអស់ ដែលជាកត្តាធ្វើឱ្យមានបរិយាកាសល្អក្នុងការផ្តល់សេវាជូនអតិថិជន ដែលរីកសាយភាយនៅគ្រប់សាខាទាំងអស់។
3. គោលគំនិតនេះបានជួយធនាគារស្ថាបនាឱ្យរក្សាបានអតិថិជនមានស្រាប់របស់ខ្លួន ព្រមទាំងបានទាក់ទាញអតិថិជនថ្មីៗផងដែរ។
4. ក្នុងនាមជាធនាគារពាណិជ្ជធំលំដាប់ទីពីរផ្នែកចំនួនបណ្តាញសាខានៅទូទាំងប្រទេសបានជួយធនាគារស្ថាបនាក្នុងពង្រីកខ្លួនកាន់តែខិតជិតអតិថិជន ជាពិសេសនៅក្នុងសហគមន៍ដាច់ស្រយាល ដែលឱ្យតម្លៃទៅលើដាក់ប្រាក់នៅធនាគារដែលខ្លួនអាចទុកចិត្តបាន។

ដោយសារការយល់ដឹង និងឥរិយាបថអតិថិជនចំពោះប្រាក់បញ្ញើកាន់តែមានភាពច្បាស់លាស់ ដោយសារអតិថិជនមើលឃើញអំពីសក្តានុពលនៃការដាក់ប្រាក់នៅធនាគារស្ថាបនា ព្រមទាំងការដាក់ឱ្យប្រើប្រាស់នូវផលិតផល និងសេវាកម្មថ្មី និងទំនើប ជាពិសេសផលិតផល ប្រតិបត្តិការ ធនាគារឌីជីថល ឧ. សេវាធនាគារតាមអ៊ីនធឺណេត និងសេវាធនាគារតាមទូរស័ព្ទ ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទានម៉ាស៊ីនទំនើបបន្ថែម ប្រាក់បញ្ញើ រំពឹងថានឹងបន្តកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

# ការអភិវឌ្ឍន៍អាជីវកម្ម

**ឆ្នាំ 2018 ជាឆ្នាំដ៏ល្អមួយទៀតដោយសម្រេចបាននូវផលិតផល និងសេវាកម្មសំខាន់ៗ ក៏ដូចជាការចាប់ដៃគូសហការគ្នាដើម្បីផ្តល់នូវភាពងាយស្រួល និងសំណើសុំតម្លៃសម្រាប់អតិថិជនរបស់យើងផងដែរ។**



## HITACHI
## ការដាក់ឱ្យប្រើប្រាស់ម៉ាស៊ីនអេធីអឹមដាក់ប្រាក់

ធនាគារបានដាក់ឱ្យប្រើប្រាស់ម៉ាស៊ីនអេធីអឹមថ្មីចំនួន 50 គ្រឿងនៅទូទាំងប្រទេស ដែលធ្វើឱ្យចំនួនសរុបនៃម៉ាស៊ីនអេធីអឹមរបស់ធនាគារស្ថាបនាកើនឡើងដល់ 150 គ្រឿងនៅឆ្នាំ2018។

ការវិនិយោគទៅលើបច្ចេកវិទ្យាថ្មីចុងក្រោយទាំងនេះ ដូចជាម៉ាស៊ីនអេធីអឹមដំណើរការសាច់ប្រាក់ នឹងផ្តល់ជូនអតិថិជននូវសេវា និងបទពិសោធន៍សេវាធនាគារងាយស្រួល ឆាប់រហ័ស និងមានសុវត្ថិភាពនៅទូទាំងប្រទេសដែលអតិថិជនអាចដាក់ប្រាក់បញ្ញើចូលទៅក្នុងគណនីរបស់ខ្លួននៅគ្រប់ពេលវេលារួមទាំងមុន និងក្រោយម៉ោងធ្វើការថ្ងៃចុងសប្តាហ៍ និងថ្ងៃបុណ្យជាតិផងដែរ។ ម៉ាស៊ីនថ្មីនេះអាចទទួលយកក្រដាសប្រាក់ចំនួនច្រើនបំផុតដោយប្រើបច្ចេកវិទ្យាស៊ិនស័រឆ្លាតវៃ។

ដោយប្រើម៉ាស៊ីនអេធីអឹម អតិថិជនពិតជាអាចដកប្រាក់ និងធ្វើការទូទាត់ប្រាក់ ព្រមទាំងធ្វើប្រតិបត្តិការផ្សេងៗទៀតផងដែរ។ ជាមួយគ្នានេះដែរម៉ាស៊ីនអេធីអឹមដំណើរការសាច់ប្រាក់ ជួយកាត់បន្ថយភាពញឹកញាប់នៃការដាក់បំពេញសាច់ប្រាក់ឡើងវិញ ដែលជួយបង្កើនប្រសិទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ។




## កិច្ចសហការជាមួយធនាគារ WING សម្រាប់ PAYMENT ECOSYSTEM

នៅខែមិថុនា ឆ្នាំ2018 ធនាគារស្ថាបនា និងធនាគារឯកទេស Wing (Cambodia) បានដាក់ឱ្យដំណើរការជាផ្លូវការនូវសេវាហិរញ្ញវត្ថុថ្មីសម្រាប់អតិថិជននៃធនាគារទាំងពីរ។ អតិថិជនធនាគារស្ថាបនាអាចចូលប្រើប្រាស់កម្មវិធីដែលផ្តល់ជូនដោយធនាគារស្ថាបនា និងធនាគារ Wing ដើម្បីធ្វើការផ្ទេរប្រាក់ និងទូទាត់សងឥណទានរបស់ខ្លួនបានកាន់តែងាយស្រួល។

ការផ្ទេរប្រាក់ពីគណនីធនាគារស្ថាបនាទៅគណនីធនាគារ WING និងពីគណនីធនាគារ WING មកគណនីធនាគារស្ថាបនាកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស។ អតិថិជនឥណទានរបស់ធនាគារស្ថាបនាអាចធ្វើការសងឥណទានតាមកាបូបប្រាក់ (Wallet) របស់ធនាគារ WING ដោយគ្រាន់តែធ្វើការផ្ទេរប្រាក់ទៅកាន់គណនីសន្សំ ឬគណនីចរន្តរបស់ធនាគារស្ថាបនា ដែលនឹងដំណើរការដោយស្វ័យប្រវត្តិ ចំពោះការសងឥណទាននេះ។

## កិច្ចសហការជាមួយ WESTERN UNION

កាលពីខែមិថុនា ឆ្នាំ2018 ធនាគារស្ថាបនាបានប្រកាសផ្តល់សេវាផ្ទេរប្រាក់ជុំវិញពិភពលោកតាម Western Union ដល់សាខារបស់ខ្លួននៅទូទាំងប្រទេស។ សេវានេះនឹងអាចឱ្យអតិថិជនផ្ញើ និងទទួលប្រាក់បានយ៉ាងឆាប់រហ័សនៅទូទាំងប្រទេសកម្ពុជា។

តាមរយៈកិច្ចសហការជាមួយ Western Union អតិថិជនរបស់ធនាគារស្ថាបនាអាចធ្វើការភ្ជាប់ ទំនាក់ទំនងជាមួយស្ទើរតែគ្រប់ប្រទេសនៅក្នុងពិភពលោកបានយ៉ាងឆាប់រហ័ស ងាយស្រួល និងមានទំនុកចិត្តពីសេវារបស់ Western Union។









## កិច្ចសហការផ្តាច់មុខជាមួយក្រុមហ៊ុន MANULIFE

នៅខែមិថុនា ឆ្នាំ2018 ក្រុមហ៊ុន Manulife Cambodia និងធនាគារស្ថាបនាបានចុះកិច្ចព្រមព្រៀងសហការធានារ៉ាប់រងរយៈពេល 15 ឆ្នាំ នៅក្នុងធនាគារដែលនឹងមានផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុន Manulife ផ្តល់ជូននៅគ្រប់សាខាធនាគារស្ថាបនានៅទូទាំងប្រទេស។

កិច្ចសហការថ្មីនេះបានដាក់បញ្ចូលគ្នានូវបណ្តាញសេវាធនាគារទូលំទូលាយរបស់ធនាគារស្ថាបនា និងឯកទេសធានារ៉ាប់រងរបស់ក្រុមហ៊ុន Manulife ដើម្បីផ្តល់ជូនអតិថិជននូវមជ្ឈមណ្ឌលហិរញ្ញវត្ថុច្រកចេញតែមួយសម្រាប់សេវាធនាគារ និងសេវាធានារ៉ាប់រង។

“កិច្ចសហការរយៈពេលវែងនេះឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរួមរបស់ក្រុមហ៊ុនទាំងពីរក្នុងការជួយការពារអនាគតហិរញ្ញវត្ថុនៃគ្រួសារកម្ពុជាឱ្យបានកាន់តែច្រើន ដោយផ្តល់ការការពារប្រាក់ចំណូលកម្រិតពិភពលោកប្រាក់សន្សំប្រាក់សម្រាប់ការសិក្សារបស់កូន និងដំណោះស្រាយក្រោយពេលចូលនិវត្តន៍។

## ការបើកសាខានៅផ្សារទំនើបអ៊ីអន II

កាលពីខែកក្កដា ឆ្នាំ2018 ធនាគារស្ថាបនាបានបើកសាខាថ្មីរបស់ខ្លួននៅផ្សារទំនើបអ៊ីអន II ក្នុង ខណ្ឌសែនសុខ ដែលធ្វើឱ្យសាខារបស់ធនាគារស្ថាបនាកើនឡើងដល់ចំនួន 169 កន្លែងនៅទូទាំងប្រទេស។

នេះគឺជាសមិទ្ធិផលដ៏គួរឱ្យកត់សម្គាល់មួយទៀតរបស់ធនាគារស្ថាបនា ដោយសារនេះគឺជាសាខាដំបូងបង្អស់នៅក្នុងផ្សារទំនើបក្នុងប្រទេសកម្ពុជាដែលផលិតផល និងសេវាកម្មប្រកួតប្រជែងបានផ្តល់ឱ្យម្ចាស់អាជីវកម្មនៅក្នុងផ្សារទំនើបអ៊ីអន II និងប្រជាជននៅក្នុងតំបន់នោះបានរយៈពេលកាន់តែយូរ និងរយៈពេលប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។




## កម្មវិធី SATHAPANA MOBILE

នៅខែកញ្ញា ឆ្នាំ2018 ធនាគារស្ថាបនាបានដាក់ឱ្យដំណើរការជាផ្លូវការនូវកម្មវិធីសេវាធនាគារតាមទូរសព្ទដៃថ្មី ដែលមានឈ្មោះ Sathapana Mobile ដែលជាសេវាចុងក្រោយសម្រាប់ស្ថានភាព ឌីជីថលដែលកាន់តែមានការកើនឡើងរបស់ធនាគារ។

កម្មវិធី Sathapana Mobile ដែលអាចទាញយកពី App Store និង Google Play ផ្តល់នូវច្រកសេវាធនាគារតាមទូរស័ព្ទដៃឆាប់រហ័ស ងាយស្រួល និងមានសុវត្ថិភាពដោយប្រើមុខងារប្រកបដោយប្រសិទ្ធភាព។ កម្មវិធីនេះអាចឱ្យអ្នកប្រើប្រាស់ពិនិត្យមើលសមតុល្យគណនី និងធ្វើប្រតិបត្តិការ គណនី បើកគណនីបញ្ញើ ផ្ទេរប្រាក់ បង់វិក្កយបត្រ និងបញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ ពិនិត្យមើលរបាយការណ៍ប័ណ្ណឥណទាន បង់ប័ណ្ណឥណទាន ដោយមានមុខងារសំខាន់ៗផ្សេងៗទៀត បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងនៅក្នុងពិភពលោក។




## កិច្ចសហការជាមួយក្រុមហ៊ុន Pi Pay

កាលពីខែកញ្ញា ឆ្នាំ2018 - ធនាគារស្ថាបនា ដែលជាធនាគារពាណិជ្ជឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា បានប្រកាសអំពីកិច្ចព្រមព្រៀងជាមួយ Pi Pay ដែលជាកម្មវិធីទូទាត់គ្មានសាច់ប្រាក់ដំបូងគេនៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់សេវាផ្ទេរប្រាក់ភ្លាមៗ និងងាយស្រួលដល់អតិថិជនរវាងគណនីធនាគារស្ថាបនា និងគណនីរបស់ Pi Pay ដោយប្រើកម្មវិធី Sathapana Mobile និង Pi Pay។

កិច្ចសហការដែលត្រូវបានប្រកាស និងរៀបចំចុះហត្ថលេខាជាផ្លូវការនៅផ្សារទំនើបអ៊ីអន ll ក្នុង ខណ្ឌសែនសុខ អាចឱ្យអតិថិជនធនាគារស្ថាបនាប្រើប្រាស់បានដោយពេញលេញនូវសេវារបស់ Pi Pay ហើយអ្នកប្រើប្រាស់សេវា Pi Pay អាចផ្ទេរប្រាក់ចូលទៅកាន់គណនីធនាគារស្ថាបនានៅទូទាំងប្រទេសបាន។

កិច្ចសហការជាមួយ Pi Pay គឺជាជម្រើសដ៏ងាយស្រួលមួយ ដោយសារក្រុមហ៊ុននេះឈានមុខគេលើការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សម្រាប់សេវាហិរញ្ញវត្ថុ។ ការផ្តល់សេវា Pi Pay ជូនដល់អតិថិជនរបស់យើង ដោយគ្រាន់តែចុចប៊ូតុងតាមរយៈកម្មវិធី Sathapana Mobile ដែលទើបតែបានដាក់ឱ្យប្រើប្រាស់កាលពីពេលថ្មីៗនេះ នឹងបង្ហាញដល់អតិថិជនភ្លាមៗ អំពីវិធីដែលកាន់តែងាយស្រួលឆាប់រហ័ស និងកាន់តែមានសុវត្ថិភាពក្នុងការប្រើប្រាស់សេវាធនាគារ និងផ្ទេរប្រាក់នៅក្នុងពិភពឌីជីថលបច្ចុប្បន្ននេះ។ ហើយការនាំយកសេវាធនាគារទំនើបជូនអតិថិជនដែលនៅកម្ពុជាគឺជាចំណុចគន្លឹះសំខាន់នៃបេសកកម្មរបស់ធនាគារស្ថាបនា។



## សេវាធនាគារឌីជីថល



កម្មវិធី Sathapana Mobile បង្ហាញពីអត្ថប្រយោជន៍ប្រកួតប្រជែងខ្លាំងក្លា។ កម្មវិធី Sathapana Mobile ប្រើកម្មវិធីបណ្តាញ omni សម្រាប់ទាំងសេវាធនាគារតាមអ៊ីនធឺណិត និងសេវាធនាគារតាមទូរស័ព្ទ ដោយមានលេខកូដប្រភពតែមួយរួមគ្នា។ អតិថិជនអាចចូលបណ្តាញទាំងពីរដោយរលូន។ អតិថិជនអាចមើលកាលវិភាគសងឥណទាន បើក/បិទបញ្ញើមានកាលកំណត់ សេវាប័ណ្ណឥណទានស្នើសុំផ្ទេរប្រាក់អន្តរធនាគារ និងផ្ទេរប្រាក់ក្រៅប្រទេស និងសេវាផ្សេងៗជាច្រើនទៀត។

| | លក្ខណៈពិសេស - កម្មវិធីទូរស័ព្ទដៃ ( Features – Mobile App ) | |
|---|---|---|
| សេវាធនាគារ | ពិនិត្យសមតុល្យ/ប្រវត្តិប្រតិបត្តិការ/ព័ត៌មានអំពីគណនី | √ |
| | ផ្ទេរប្រាក់នៅក្នុងធនាគារ | √ |
| | ផ្ទេរប្រាក់រវាងធនាគារ | √ |
| | ផ្ទេរតាម FAST | √ |
| | ផ្ទេរប្រាក់ទៅក្រៅប្រទេស | √ |
| | ផ្ទេរប្រាក់ទៅកាន់ PSP (Wing/Pi Pay) | √ |
| | បង់វិក្កយបត្រ | √ |
| | សេចក្តីសង្ខេបប័ណ្ណឥណទាន | √ |
| | បើកគណនីធនាគារ | √ |
| | រក្សាទុកទម្រង់ទូទាត់ | √ |
| | ការបញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទ | √ |
| | ការគ្រប់គ្រងសៀវភៅមូលប្បទានបត្រ | √ |
| សេវាផ្សេងៗ | ឧបករណ៍ស្វែងរកទីតាំងអេធីអឹម/សាខា | √ |
| | ម៉ាស៊ីនគិតអត្រាប្តូរប្រាក់ | √ |
| | ម៉ាស៊ីនគិតឥណទាន | √ |
| | ម៉ាស៊ីនគិតអត្រាការប្រាក់ | √ |
| | លើកកម្ពស់ការរស់នៅតាមទីតាំង | √ |
| មុខងារផ្សេងៗ | អាចប្រើប្រាស់ជាមួយទូរស័ព្ទ iOS និង Android | √ |
| | ប្រើប្រាស់ដោយឥតគិតថ្លៃ | √ |
| | ចុះឈ្មោះដោយខ្លួនឯង | √ |
| | ការចូលដោយប្រើស្នាមក្រយៅដៃ | √ |

## ម៉ាស៊ីនដាក់ប្រាក់ ( ATM Cash Recycling )



ជាមួយនឹងបណ្តាញដ៏ទូលំទូលាយនៃម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនដាក់ប្រាក់ លោកអ្នកអាចធ្វើប្រតិបត្តិការយ៉ាងលឿន ដូចជា ដាក់ប្រាក់ ដកប្រាក់ បញ្ចូលលុយទូរស័ព្ទដៃ ផ្ទេរប្រាក់ក្នុងធនាគារ និងឆ្លងធនាគារ និងផ្ទេរប្រាក់ទៅអ្នកដែលមិនមានគណនី ទាញយករបាយការណ៍សង្ខេប ប្តូរលេខកូដសំងាត់ ពិនិត្យសមតុល្យ និងសេវាផ្សេងៗ គ្រប់ពេលវេលា។

លោកអ្នកក៏អាចដាក់ប្រាក់ក្នុងមួយដងចំនួន200សន្លឹក តាមរយៈម៉ាស៊ីនដាក់ប្រាក់ផងដែរ។

ក្រៅពីភាពងាយស្រួល និងឆាប់រហ័ស ម៉ាស៊ីនដាក់ប្រាក់របស់យើងបំពាក់ដោយបច្ចេកទេសទំនើប ដែលអាចពិនិត្យសាច់ប្រាក់ពិតប្រាកដ និងការពារក្រដាសប្រាក់ក្លែងក្លាយ។

បន្ថែមពីនេះទៅទៀត បណ្តាញម៉ាស៊ីនអេធីអឹមអាចធ្វើប្រតិបត្តិការនូវកាត ធនាគារ ស្ថាបនា និងកាតរបស់ស្ថាប័នដទៃទៀតដែលមាននិមិត្តសញ្ញាវីសា ព្រមទាំងកាតរបស់ធនាគារផ្សេងៗ ដែលជាសមាជិក CSS។

# ការអភិវឌ្ឍន៍និយោជិត



ធនាគារស្ថាបនាផ្តោតលើការជំរុញសមិទ្ធផល គុណភាព និងការកែលម្អជាប្រចាំ។ យើងផ្តល់តម្លៃដល់ភាពចម្រុះនៅក្នុងក្រុមការងារ ហើយនឹងអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកយើង ដើម្បីឱ្យយើងអាចភ្ជាប់ទំនាក់ទំនងកាន់តែល្អប្រសើរជាមួយអតិថិជន និងផ្តល់ផលិតផល និងសេវាកម្មធនាគារប្រកបដោយជោគជ័យ។

ចំណុចគន្លឹះមួយ ដើម្បីធានាដល់ភាពជោគជ័យរបស់ធនាគារស្ថាបនាគឺអាស្រ័យទៅលើធនធានមនុស្សរបស់យើង។ ដូច្នេះ ធនាគារស្ថាបនាតែងតែធ្វើការជ្រើសរើស និងអភិវឌ្ឍបុគ្គលិកម្នាក់ៗស្របទៅតាមសក្តានុពល និងភាពសមស្របរបស់ពួកគាត់ចំពោះការងារ។

នៅដំណាច់ឆ្នាំ2018 បុគ្គលិករបស់យើងបានកើនឡើងដល់ 4,473 នាក់ (1,714 នាក់ជាបុគ្គលិកនារី)។ បុគ្គលិកថ្មីដែលយើងបានជ្រើសរើសមានចំនួនប្រមាណជា 780 នាក់។ មុខតំណែងភាគច្រើន ដែលបានជ្រើសរើសគឺនៅតែផ្តោតលើបុគ្គលិកផ្នែកលក់ និងមុខតំណែងជួរមុខ ដើម្បីបង្កើនចំនួនបុគ្គលិកមានស្រាប់ ឬដើម្បីជំនួសបុគ្គលិកដែលបានលាលែង ឬលាឈប់ពីធនាគារស្ថាបនា។

នៅឆ្នាំ2018 ផ្នែកធនធានមនុស្សបានផ្តោតលើការរៀបចំថ្មី និងការរៀបចំផែនការធនធាន ក៏ដូចជាការអភិវឌ្ឍន៍ដើម្បីធានាថា ការគ្រប់គ្រងធនធាន និងដំណើរការបន្តការអភិឌ្ឍន៍ប្រព្រឹត្តិទៅបានដោយរលូន។ យើងវិនិយោគ ដើម្បីជំរុញការរីកចម្រើន និងការអភិវឌ្ឍន៍របស់បុគ្គលិកយើង។ យើងមានកម្មវិធី និងគំនិតផ្តួចផ្តើមបណ្តុះបណ្តាល ដែលអាចឱ្យយើងកំណត់តួនាទី និងបុគ្គលម្នាក់ៗ ដែលមានសារសំខាន់ក្នុងការគាំទ្រដល់ការសម្រេចបានគោលបំណងយុទ្ធសាស្ត្ររបស់យើង។

យើងផ្តល់ឱកាសរៀនសូត្រ និងអភិវឌ្ឍខ្លួនដើម្បីគាំទ្រដល់គ្រប់ដំណាក់កាលនៃដំណើរការអភិវឌ្ឍន៍ សម្រាប់បុគ្គលិកដោយចាប់ផ្តើមពីថ្នាក់ដឹកនាំជាន់ទាបរហូតដល់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃអាជីវកម្មរបស់ យើងតាមរយៈកម្មវិធីបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយ។ យើងមានវិធីសាស្ត្រក្នុងការអភិវឌ្ឍន៍បុគ្គលិកដោយរួមបញ្ចូលបទពិសោធន៍នៅពេលកំពុងបំពេញការងារ ការចុះកម្មសិក្សាការរៀនតាមបុគ្គលិកផ្សេងទៀត និងកម្មវិធីបណ្តុះបណ្តាលខាងក្នុង និងខាងក្រៅជាផ្លូវការ។ នៅឆ្នាំ2018 យើងបានវិនិយោគអស់ទឹកប្រាក់ចំនួន 2 ម៉ឺនដុល្លារអាមេរិកដើម្បីអភិវឌ្ឍន៍បុគ្គលិក។

យើងនឹងធ្វើការរៀបចំកម្មវិធីបណ្តុះបណ្តាលចុះកម្មសិក្សាសម្រាប់បុគ្គលិកថ្មីចំនួន 520 នាក់ និងកម្មវិធីអភិវឌ្ឍន៍ជំនាញផ្សេងទៀត ព្រមទាំងកែប្រែកម្មវិធីបណ្តុះបណ្តាលដែលរួមមាន ការអភិវឌ្ឍបច្ចេកទេស ឥរិយាបថភាពជាអ្នកដឹកនាំដល់បុគ្គលិកចំនួន 7,907 នាក់ផងដែរ។

យើងបន្តបង្កើនកម្មវិធីការងារក្រៅប្រទេស ដែលផ្តល់ឱកាសដល់បុគ្គលិកមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍន៍អាជីពការងាររបស់ខ្លួនក្នុងតួនាទីជាអ្នកដឹកនាំជាន់ខ្ពស់នៅថ្ងៃអនាគត ដូចជា ប្រធាននាយកប្រតិបត្តិ នាយកប្រតិបត្តិហិរញ្ញវត្ថុ នាយកប្រតិបត្ត ប្រតិបត្តិការ ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា និងប្រធានតំបន់។ បច្ចុប្បន្ននេះ មានបុគ្គលិកចំនួន 10 នាក់ ហើយដែលត្រូវបានជ្រើសតាំងឱ្យទទួលយកតួនាទីជាអ្នកដឹកនាំជាន់ខ្ពស់នៅ SATHAPANA MFI ក្នុងប្រទេសមីយ៉ាន់ម៉ា និងនៅធនាគារ Maruhan Japan Bank ក្នុងប្រទេសឡាវ។

# ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចសាជីវកម្ម

ភាពជោគជ័យនៃយុទ្ធសាស្ត្រអាជីវកម្មអាចសម្រេចទៅបាន ដោយសារមានការគ្រប់គ្រងល្អទៅលើហានិភ័យ និងអភិបាលកិច្ចធនាគារត្រឹមត្រូវ។

យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យចាប់ផ្តើមពីក្រុមប្រឹក្សាភិបាល និងគណៈកម្មការ ក្រុមប្រឹក្សារបស់យើង ដែលរួមមានគណៈកម្មការគ្រប់គ្រងហានិភ័យ គណៈកម្មការសវនកម្ម និងគណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ។ គណៈកម្មការគ្រប់គ្រងហានិភ័យនៃក្រុមប្រឹក្សាភិបាលបានកំណត់ក្របខណ្ឌទទួលយកហានិភ័យ សម្រាប់ធនាគារ ដែលត្រូវដាក់បញ្ចូលទៅក្នុងគ្រប់គោលនយោបាយប្រតិបត្តិការ ការអនុវត្តតាមច្បាប់ និងឥណទានទាំងអស់របស់យើង។ ក្របខណ្ឌទទួលយកហានិភ័យកំណត់កត្តា ដែលសំខាន់បំផុតទៅលើរបៀបធ្វើអាជីវកម្មរបស់យើង និងដាក់បញ្ចូលនូវដែនកំណត់ផ្សេងៗដូចជា ការចូលរួមតែក្នុងសកម្មភាព ដែលបានអនុញ្ញាតកំណត់កម្រិតចាប់ផ្តើមផលបត្រនៅក្នុងវិស័យជាក់លាក់ គ្រប់គ្រងកម្រិត និងការទទួលយកហានិភ័យ ព្រមទាំងជួយដឹកនាំការងារក្នុងការសម្រេចគោលដៅប្រកបដោយចីរភាព។

ក្រៅពីគណៈកម្មការកំរិតក្រុមប្រឹក្សាភិបាល ធនាគារ ក៏មានគណៈកម្មការកំរិតប្រតិបត្តិ សម្រាប់តាមដាន និងត្រួតពិនិត្យ ដើម្បីគ្រប់គ្រងលើយុទ្ធសាស្ត្រហានិភ័យផងដែរ។ គណៈកម្មការទាំងនោះរួមមាន គណៈកម្មការទ្រព្យសកម្ម និងទ្រព្យអកម្ម គណៈកម្មការឥណទាន និងគណៈកម្មការផ្សេងៗទៀត ដែលគ្រប់គ្រង និងវាស់វែងហានិភ័យប្រតិបត្តិការ និងទីផ្សារ។

## ផ្នែកមុខងារហានិភ័យឯករាជ្យ

ធនាគារ ស្ថាបនា មានផ្នែកមុខងារហានិភ័យឯករាជ្យ ដែលព្យាយាមដាក់បញ្ចូលក្របខ័ណ្ឌហានិភ័យ និងរចនាសម្ព័ន្ធគោលនយោបាយសមស្របទៅក្នុងអាជីវកម្ម។ ផ្នែកមុខងារគ្រប់គ្រងហានិភ័យឯករាជ្យ គឺជាសមាសធាតុសំខាន់មួយនៃខ្សែការពារទីពីររបស់ធនាគារ។ មុខងារនេះទទួលខុសត្រូវក្នុងការត្រួតពិនិត្យសកម្មភាពទទួលយកហានិភ័យនៅក្នុងធនាគារទាំងមូល។ ផ្នែកមុខងារហានិភ័យឯករាជ្យ មានសិទ្ធិអំណាចនៅក្នុងធនាគារ ដើម្បីត្រួតពិនិត្យមើលរាល់សកម្មភាពគ្រប់គ្រងហានិភ័យរបស់ធនាគារ។ ផ្នែកគ្រប់គ្រងហានិភ័យត្រូវរាយការណ៍ ដោយផ្ទាល់ទៅគណៈកម្មាធិការក្រុមប្រឹក្សាហានិភ័យ និងសហការជាមួយក្រុមថ្នាក់គ្រប់គ្រង ដើម្បីបង្កើតដំណើរការដែលមានរចនាសម្ព័ន្ធ និងវិន័យក្នុងការគ្រប់គ្រង និងវាស់វែងហានិភ័យ។

ធនាគារជួបប្រទះហានិភ័យសំខាន់ៗដូចខាងក្រោម៖

- ហានិភ័យប្រតិបត្តិការ
- ហានិភ័យទីផ្សារ
- ហានិភ័យឥណទាន
- ហានិភ័យសាច់ប្រាក់ងាយស្រួល

### 1. ហានិភ័យប្រតិបត្តិការ

នេះគឺការហានិភ័យនៃការបាត់បង់ដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពីការខ្វះខាត ឬមិនដំណើរការនៃនីតិវិធីផ្ទក្នុង កត្តាមនុស្ស និងកត្តាប្រព័ន្ធ ឬបណ្តាលមកពីកត្តាខាងក្រៅ ដែលកើតចេញពីលក្ខខណ្ឌផ្លូវច្បាប់ និយ័តកម្ម និងស្តង់ដារ ដែលអាចទទួលយកបានជាទូទៅនៃឥរិយាបថសាជីវកម្ម ដោយមិនរាប់បញ្ចូលហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យសាច់ប្រាក់ងាយស្រួល។

ការគ្រប់គ្រងហានិភ័យប្រតិបត្តិការនៅក្នុងធនាគារនាំឱ្យមានការបង្កើតរចនាសម្ព័ន្ធធនាគារ តួនាទី និងគោលនយោបាយគ្រប់គ្រងច្បាស់លាស់។ គោលនយោបាយគ្រប់គ្រង និងវិធានការនានាត្រូវបានអនុវត្ត ដែលរួមមានការបង្កើតឱ្យមានសិទ្ធិចុះហត្ថលេខា ការកំណត់ការគ្រប់គ្រងប៉ារ៉ាម៉ែត្រប្រព័ន្ធការបញ្ជាបនីតិវិធី និងឯកសារ និងការអនុវត្តតាមលក្ខខណ្ឌតម្រូវនិយ័តកម្ម និងលក្ខខណ្ឌផ្លូវច្បាប់ផ្សេងទៀត។

ការគ្រប់គ្រងហានិភ័យប្រតិបត្តិការមិនមានគោលបំណងលុបបំបាត់រាល់ហានិភ័យទាំងអស់ឡើយ ប៉ុន្តែគឺដើម្បីធានាថាការគ្រប់គ្រង ដែលដាក់ឱ្យបានអនុវត្ត និងហានិភ័យប្រតិបត្តិការនៅសេសសល់របស់ធនាគារនៅតែស្ថិតក្នុងកម្រិតមួយដែលអាចទទួលយកបាន។

### 2. ហានិភ័យទីផ្សារ

ធនាគារប្រឈមនឹងហានិភ័យទីផ្សារដែលហានិភ័យទៅលើតម្លៃសមស្រប ឬលំហូរសាច់ប្រាក់អនាគតនៃឧបករណ៍ហិរញ្ញវត្ថុនឹងមានការប្រែប្រួលចុះឡើងដោយសារតែការផ្លាស់ប្តូរតម្លៃទីផ្សារ។

ហានិភ័យទីផ្សារកើតឡើងពីស្ថានភាពបើកចំហនៃអត្រាការប្រាក់ រូបិយប័ណ្ណ និងផលិតផលទ្រព្យម្ចាស់ ដែលទាំងអស់នេះទទួលឥទ្ធិពលពីចលនាទីផ្សារជាក់លាក់ និងការប្រែប្រួលនិងការប្រែប្រួលមិនទៀងទាត់នៃអត្រា ឬតម្លៃទីផ្សារដូចជា អត្រាការប្រាក់ វិសាលភាពទូទៅនៃឥណទាន អត្រាប្តូររូបិយប័ណ្ណបរទេស និងតម្លៃទ្រព្យម្ចាស់។

ហានិភ័យអត្រាប្តូររូបិយប័ណ្ណបរទេសត្រូវបានពិនិត្យតាមដានធៀបនឹងរូបិយប័ណ្ណមុខងារ តាមរយៈការតាមដានហានិភ័យអត្រាប្តូររូបិយប័ណ្ណបរទេសដោយប្រើប្រាស់ហានិភ័យស្រូបយកចំនួន 20% នៃតម្លៃសុទ្ធ ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ហានិភ័យលើអត្រាការប្រាក់សំដៅដល់ការប្រែប្រួលមិនទៀងទាត់នៃចំណូលការប្រាក់សុទ្ធ ដោយសារតែការប្រែប្រួលអត្រាការប្រាក់ និងការផ្លាស់ប្តូរសមាសភាពទ្រព្យសកម្ម និងទ្រព្យអសកម្ម។

ហានិភ័យលើអត្រាការប្រាក់អាចគ្រប់គ្រងបាន តាមរយៈការត្រួតពិនិត្យតាមដានយ៉ាងហ្មត់ចត់ ទៅលើចំណូលពីការបណ្តាក់ទុន តម្លៃទីផ្សារ តម្លៃដើមនៃមូលនិធិ និងតាមរយៈការវិភាគចន្លោះប្រែប្រួលអត្រាការប្រាក់។ សក្តានុពលនៃការធ្លាក់ចុះនូវចំណូលការប្រាក់សុទ្ធពីការប្រែប្រួលអត្រាការប្រាក់ខុសប្រក្រតីត្រូវបានត្រួតពិនិត្យ ដោយធៀបទៅនឹងកម្រិតហានិភ័យដែលកំណត់ថាអាចទទួលយកបាន។




## 3. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ហិរញ្ញវត្ថុចំពោះធនាគារ ប្រសិនបើអ្នកខ្ចី ឬសមភាគីមិនបំពេញតាមកាតព្វកិច្ចក្នុងកិច្ចសន្យារបស់ខ្លួន ហើយកើតឡើងជាចម្បងមកពីកម្ចីផ្តល់ជូនអតិថិជន។

សកម្មភាពផ្តល់កម្ចីរបស់យើងអនុវត្តតាមសេចក្តីថ្លែងទទួលយកហានិភ័យ (Risk Appetite Statement) ដែលមានកម្រិតចាប់ផ្តើមផលបត្រកម្រិតខ្ពស់ដោយផ្អែកលើយុទ្ធសាស្ត្រហានិភ័យរួម។ សេចក្តីថ្លែងនេះរួមមានវិធានការនានាដូចជាការមានការកម្រិតលើការផ្តោតលើឧស្សាហកម្ម និងម៉ាទ្រីសអនុវត្តផលបត្រ។

ធនាគារមានគោលនយោបាយផ្តល់កម្ចីគ្រប់ជ្រុងជ្រោយ ដែលរួមមានផលិតផលលម្អិត និងស្តង់ដារនៃការធានាឥណទាន។ គោលនយោបាយនេះត្រូវបានអនុម័តពីក្រុមប្រឹក្សាភិបាល ហើយមានប៉ារ៉ាម៉ែត្រផលិតផលជាក់លាក់ ដូចជាទីផ្សារគោលដៅ និងលក្ខខណ្ឌឯកសារ និងនីតិវិធីដែលនឹងត្រូវផ្តល់ផលិតផលឥណទានឱ្យ។ គោលនយោបាយនេះរួមមានកត្តាទ្រព្យបញ្ចាំ និង និងទ្រព្យធានា ហើយប្រព័ន្ធកំណត់ហានិភ័យ ដែលកំណត់កម្រិតហានិភ័យរបស់ភាគីម្ខាងទៀត។

សម្រាប់ការអនុម័តកម្ចីធំ គណៈកម្មាធិការឥណទាននៃធនាគារដែលរួមមានសមាជិក 6 រូបមកពីផ្នែកឥណទាន និងអាជីវកម្ម ព្រមទាំងមានការចូលរួមពីផ្នែកមុខងារហានិភ័យឯករាជ្យ អនុម័តលើកម្ចី និងលក្ខខណ្ឌសម្រាប់ការផ្តល់កម្ចីពាណិជ្ជកម្ម និងសាជីវកម្ម។ ការអនុវត្តនេះ គឺដើម្បីធានាឱ្យមានវិធីសាស្ត្រមានតុល្យភាពក្នុងការធ្វើការសម្រេចចិត្តផ្នែកឥណទាន។

## 4. ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យរបស់ធនាគារដែលមិនអាចបំពេញកាតព្វកិច្ចទូទាត់របស់ខ្លួនបាន ដែលពាក់ព័ន្ធទៅនឹងបំណុលហិរញ្ញវត្ថុរបស់ខ្លួន នៅពេលដែលបំណុលទាំងនោះដល់ពេលកំណត់ត្រូវសង និងត្រូវដាក់ប្រាក់បំពេញវិញ នៅពេលដែលប្រាក់ទាំងនោះត្រូវបានដក។ ផលវិបាកនៃហានិភ័យនេះអាចជាការមិនបានបំពេញកាតព្វកិច្ចក្នុងការសងអ្នកតម្កល់ប្រាក់ (depositors) និងបំពេញតាមការសន្យាក្នុងការផ្តល់កម្ចី។

ថ្នាក់គ្រប់គ្រងធនាគារត្រួតពិនិត្យតាមដានសាច់ប្រាក់ងាយស្រួលតារាងតុល្យភាព និងគ្រប់គ្រងបណ្តុំ និងប្រូហ្វាល់ឥណប្រតិទានបំណុល (debt maturities)។ ការត្រួតពិនិត្យតាមដាន និងការរាយការណ៍ត្រូវអនុវត្តទម្រង់នៃការត្រួតពិនិត្យលើជំហសាច់ប្រាក់ប្រចាំថ្ងៃ និងការព្យាករណ៍សម្រាប់ថ្ងៃ សប្តាហ៍ និងខែបន្ទាប់ ដោយសារទាំងនេះ គឺជាឆ្នាំសំខាន់សម្រាប់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល។ ថ្នាក់គ្រប់គ្រងត្រួតពិនិត្យតាមដានដំណើរការរបស់អ្នកដាក់ប្រាក់បញ្ញើ និងអ្នកផ្តល់កម្ចីសំខាន់ៗ និងការព្យាករណ៍ពីការដកប្រាក់របស់ពួកគាត់ផងដែរ។

# ចីរភាពបរិស្ថាន និងសង្គម

ធនាគារស្ថាបនា មានការប្តេជ្ញាធ្វើជាដៃគូមានទំនួលខុសត្រូវក្នុងការបង្កើតគុណតម្លៃរយៈពេលវែង សម្រាប់ភាគីពាក់ព័ន្ធប្រកបដោយចីរភាព។ យើងទទួលស្គាល់ថា ការសម្រេចចិត្តអាជីវកម្មអាចមានផលប៉ះពាល់នៅជុំវិញសហគមន៍ និងបរិស្ថាន។ ធនាគារជឿជាក់ថា ការរក្សាគុណភាពបរិស្ថាន និងសង្គមជាមួយអាទិភាពហិរញ្ញវត្ថុ គឺជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហានិភ័យសមស្រប និងជាផ្នែកស្នូលដ៏សំខាន់នៃទំនួលខុសត្រូវរបស់ធនាគារ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវរួមក្នុងការរក្សាចីរភាពនៅធនាគារស្ថាបនា និងគិតគូរលើបញ្ហាបរិស្ថាន និងសង្គមក្នុងការបង្កើតយុទ្ធសាស្ត្រធនាគារ។ នៅខែវិច្ឆិកា ឆ្នាំ2018 ក្រុមប្រឹក្សាភិបាលបានអនុម័តការអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា (Cambodian Sustainable Finance Principles)។ យើងគ្រប់គ្រងបញ្ហាចីរភាពដោយប្រើស្តង់ដារដូចខាងក្រោម៖

## ការផ្តល់ហិរញ្ញប្បទានដោយទទួលខុសត្រូវ

ការអនុវត្តការផ្តល់កម្ចីរបស់យើងអាចមានផលប៉ះពាល់លើបរិស្ថាន និងសង្គម (“ES”)។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ យើងប្តេជ្ញាចិត្តលើកកម្ពស់ឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការវាយតម្លៃអតិថិជនខ្ចីប្រាក់របស់យើងដោះស្រាយបញ្ហាសំខាន់ដូចជា ការដែលពួកគេធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងសង្គមនៅក្នុងឧបករណ៍វាយតម្លៃឥណទានរបស់យើង។ វិធីសាស្ត្រគ្រប់គ្រងហានិភ័យ បរិស្ថាន និងសង្គមស្របរបស់យើង គឺស្របតាមក្រមប្រតិបត្តិ និងក្រមសីលធម៌អាជីវកម្ម (Code of Conduct and Business Ethics) (“ក្រម”)។

ការប្តេជ្ញាចិត្តនេះមានបង្ហាញជូននៅក្នុងគោលនយោបាយឥណទានរបស់យើងសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងការអនុវត្តផ្តល់ឥណទានរបស់យើង។ គោលនយោបាយនេះត្រូវបានបំពេញបន្ថែម ដោយគោលនយោបាយ ស្តីពីចីរភាពបរិស្ថាន និងសង្គមដែលដាក់ចេញនូវស្តង់ដារអនុវត្ត និងប្រតិបត្តិហាមឃាត់ (បញ្ជីដកចេញ) ដើម្បីផ្តល់ការណែនាំដែលកាន់តែមានការរៀបចំ និងលម្អិតក្នុងការកំណត់ និងវាយតម្លៃហានិភ័យបរិស្ថាន និងសង្គមដែលអាចមានដែលជាផ្នែកមួយនៃដំណើរការវាយតម្លៃឥណទាន។

វិធីសាស្ត្រវាយតម្លៃហានិភ័យបរិស្ថាន និងសង្គមត្រូវយកចិត្តទុកដាក់នៅក្រោមអង្គភាពវាយតម្លៃឥណទាននៃផ្នែកប្រតិបត្តិការឥណទាន ដើម្បីធានាថាបញ្ហាបរិស្ថាន និងសង្គមសំខាន់ៗត្រូវបានលើកមកពិចារណាសម្រាប់ការស្នើសុំឥណទាន និងការត្រួតពិនិត្យមើលជាទៀងទាត់ទាំងអស់។ ប្រសិនបើអតិថិជនខ្ចីប្រាក់ត្រូវបានសង្ស័យថា មានអាជីវកម្មដែលពាក់ព័ន្ធនឹងសកម្មភាពដែលអាចនាំឱ្យមានបញ្ហាបរិស្ថាន និងសង្គម ឬត្រូវចាត់ចូលទៅក្នុងបញ្ជីដកចេញ នោះក្រុមវាយតម្លៃឥណទាននឹងឱ្យមន្ត្រីទទួលបន្ទុកផ្នែកបរិស្ថាន និងសង្គមរបស់ផ្នែកគ្រប់គ្រងហានិភ័យចូលរួមភ្លាមៗ ដើម្បីធ្វើការពិគ្រោះយោបល់។ ប្រសិនបើអតិថិជនខ្ចីប្រាក់មិនមានបំណងចាត់វិធានការគ្រប់គ្រងឱ្យបានគ្រប់គ្រាន់ និងបន្ធូរបន្ថយបញ្ហាបរិស្ថាន និងសង្គមដែលបានកំណត់ទេ នោះយើងនឹងមិនទទួលយកសំណើសុំឥណទានឡើយ ហើយនឹងវាយតម្លៃឡើងវិញនូវទំនាក់ទំនងសេវាធនាគារ ប្រសិនបើមាន។

## សូចនាករអនុវត្តបរិស្ថានថាមពល៖

| ការប្រើប្រាស់ថាមពល | 2016 | 2017 | 2018 |
|---|---|---|---|
| អគ្គិសនីគិតជា kwh/FTE | 1,033 | 1,095 | 1038 |
| ប្រេងសាំង និងប្រេងម៉ាស៊ូត គិតជា L/FTE | 102 | 110 | 116 |

ការប្រើប្រាស់អគ្គិសនីសម្រាប់បុគ្គលិកពេញម៉ោងម្នាក់បានថយចុះ 5.2% នៅឆ្នាំ2018 បើធៀបទៅនឹងឆ្នាំ2017 ដោយសារធនាគារបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រងការចំណាយ តាមរយៈការអប់រំបុគ្គលិកឱ្យយល់ពីរបៀបសន្សំសំចៃការប្រើប្រាស់អគ្គិសនីជារៀងរាល់ថ្ងៃ។ ការប្រើប្រាស់ប្រេងសាំង និងប្រេងម៉ាស៊ូតបានថយចុះ 5.45% កាលពីឆ្នាំ2018 កន្លងទៅ ដោយសារយើងបានផ្តល់រថយន្តដល់សាខាមួយចំនួន ដើម្បីជាជំនួយដល់អាជីវកម្ម និងប្រតិបត្តិការសេវាធនាគារ ហើយយើងបានទិញម៉ូតូបន្ថែម សម្រាប់ភ្នាក់ងារឥណទានថ្មីៗ និង SME នៅតាមសាខាខេត្តផងដែរ ព្រមទាំងយើងបានទិញម៉ាស៊ីនភ្លើង សម្រាប់សាខានៅពេលមានការដាច់ចរន្តអគ្គិសនី។

## ការប្រើប្រាស់ក្រដាស និងក្រដាសអនាម័យ

| ការប្រើប្រាស់ក្រដាស | 2016 | 2017 | 2018 |
|---|---|---|---|
| ក្រដាសគិតជា kg/FTE | 20.4 | 29.9 | 13 |
| ក្រដាសអនាម័យគិតជា kg/FTE | 4.5 | 5.4 | 4.47 |

ធនាគារបានបង្កើតផែនការទិន្នន័យមិនប្រើក្រដាស និងអេឡិចត្រូនិក ដើម្បីចូលរួមចំណែកក្នុងការអភិរក្សបរិស្ថាន ដោយយើងបានរៀបចំប្រព័ន្ធ e-Appraisal, e-Leave, e-Pay, e-Provident Fund, e-Medical និង Intranet ដើម្បីធ្វើការចែករំលែកព័ត៌មានរវាងសាខានៅទូទាំងប្រទេស និងទីស្នាក់ការកណ្តាល។

## ទឹក

| ការប្រើប្រាស់ទឹក | 2016 | 2017 | 2018 |
|---|---|---|---|
| ទឹកគិតជា m3/FTE | 42 | 40 | 38 |

ការប្រើប្រាស់ទឹកបានថយចុះបន្តិចបន្តួចចំនួន 5% ដោយសារមិនមានការអនុញ្ញាតឱ្យលាងសម្អាតរថយន្តនៅក្នុងបរិវេណសាខាធនាគារ កាលពីឆ្នាំ2018 កន្លងទៅ ហើយសាខាមួយចំនួនប្រើទឹកអណ្តូងជំនួសវិញ ដើម្បីលាងសម្អាតម៉ូតូ។

# ទំនួលខុសត្រូវសង្គម






## ការចូលរួមបរិច្ចាគឈាមពីសំណាក់បុគ្គលិក

យុទ្ធនាការប្រចាំឆ្នាំ ដើម្បីគាំទ្រដល់វិស័យសុខាភិបាលនៅកម្ពុជា

ធនាគារ ស្ថាបនា តែងតែប្តេជ្ញាចិត្តជួយសង្គម និងសហគមន៍ដែលយើងធ្វើប្រតិបត្តិការណ៍ ។ នៅក្នុងឆ្នាំ2018 ដោយមានការគាំទ្រពីមជ្ឈមណ្ឌលជាតិផ្តល់ឈាម ធនាគារ ស្ថាបនា បានធ្វើការរៀបចំយុទ្ធនាការបរិច្ចាគឈាម។ គោលបំណងនៃកម្មវិធីនេះ គឺដើម្បីចូលរួមចំណែកទ្រទ្រង់វិស័យសុខាភិបាលនៅកម្ពុជា តាមរយៈសកម្មភាពស្ម័គ្រចិត្តរបស់បុគ្គលិកក្នុងការបរិច្ចាគឈាមជូនដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម។

យុទ្ធនាការនេះ ពិតជាបានជួយសង្គ្រោះអាយុជីវិតមនុស្ស ដែលត្រូវការឈាមជាចាំបាច់ និងជួយបង្កើនបរិមាណឈាមក្នុងស្តុករបស់មជ្ឈមណ្ឌលជាតិផ្តល់ឈាម សម្រាប់ទុកប្រើប្រាស់នាពេលអនាគត។

នេះគឺជាលើកទី11 ដែលធនាគារ ស្ថាបនា បានប្រារព្ធកម្មវិធីបរិច្ចាគឈាម។ ជាមួយនឹងពាក្យស្លោក «បរិច្ចាគឈាម ជួយសង្គ្រោះជីវិត» ដែលត្រូវបានប្រព្រឹត្តឡើង 4 ទីតាំងផ្សេងៗ ពីគ្នារួមមាន ការិយាល័យកណ្តាល សាខាខេត្តសៀមរាប សាខាខេត្តកំពង់ចាម និងសាខាខេត្តបាត់ដំបង។

បើយោងតាមការសិក្សាឈាមមួយថ្លោកដែលមនុស្សម្នាក់បានបរិច្ចាគ គឺអាចជួយសង្គ្រោះអាយុជីវិតមនុស្សបានចំនួន 3 នាក់។

ក្រៅពីការបរិច្ចាគឈាម ធនាគារ ស្ថាបនា ក៏បានរួមចំនែកក្នុងការគាំទ្រកម្មវិធីផ្សេងៗទៀត ដូចជា សន្និបាតបញ្ញវន្តពិភពលោកលើកទី 4 ពិធីបុណ្យគីហ្សូណា និងមហោស្រពបុងអូដូរី ជាដើម។

## គម្រោងសំអាតទីក្រុង

នៅក្នុងខែវិច្ឆិកា 2018 ធនាគារ ស្ថាបនា បានចូលរួមការងារសង្គម គឺគម្រោងសម្អាតទីក្រុង ដោយមានការរៀបចំឡើងដោយក្រសួងបរិស្ថាន សហការណ៍ជាមួយស្ថានទូត ជប៉ុន និងសាលាក្រុង។

បុគ្គលិកស្ថាបនាជាច្រើននាក់ដែលមានសញ្ជាតិខ្មែរនិងជប៉ុន បានស្ម័គ្រចិត្តចូលរួមសំអាតទីក្រុង ដែលប្រព្រឹត្តទៅនៅទីតាំងផ្សេងៗគ្នា ដូចជា ដងវិថីមាត់ទន្លេ និងមុខព្រះបរមរាជវាំង នៅខាងមុខសួនច្បារនាគបាញ់ទឹក និងសួនច្បារសម្តេចមហាសេនាបតី តេជោ ហ៊ុន សែន។

គោលបំណងនៃការចូលរួមសំអាតទីក្រុងនេះ គឺដើម្បីលើកសម្រស់ទីក្រុងខ្យល់បរិសុទ្ធ និងប្រជាពលរដ្ឋរស់នៅប្រកបដោយផាសុខភាព។ ហើយនិងជាការបង្ហាញ រឺបញ្ជាក់អោយឃើញថា បុគ្គលគ្រប់រូបអាចចូលរួមធ្វើអោយទីក្រុងស្អាត។

# ផ្នែកសវនកម្ម និងការត្រួតពិនិត្យផ្ទៃក្នុង

ផ្នែកសវនកម្មផ្ទៃក្នុង ជាជំនួយការឯករាជ្យនៃគណគ្រប់គ្រងរបស់ធនាគារ និងជាជំនួយការរបស់ក្រុមប្រឹក្សាភិបាលក្នុងការបំពេញទំនួលខុសត្រូវផ្នែកអភិបាលកិច្ច ដែលទាក់ទងនឹងការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យ។ ក្រុមសវនករផ្ទៃក្នុង មានទំនួលខុសត្រូវធ្វើសវនកម្មលើប្រតិបត្តិការហិរញ្ញវត្ថុ ប្រតិបត្តិការធនាគារទូទៅផ្នែកអនុវត្តន៍តាមផ្នែកពត៌មានវិទ្យា ព្រមទាំងផ្នែកដទៃទៀត ដើម្បីឆ្លុះបញ្ចាំងអំពីបញ្ហា និងកង្វះខាតផ្នែកប្រព័ន្ធត្រួតពិនិត្យ។ របាយការណ៍នៃសវនកម្មនឹងត្រូវចេញជូនគណៈគ្រប់គ្រងពាក់ពន្ធ័ និងក្រុមប្រឹក្សាភិបាល។

សវនកម្មនិមួយៗ ត្រូវផ្តោតលើការវាយតំលៃជាបឋមថា តើនិតិវិធី និងប្រព័ន្ធត្រួតពិនិត្យមានភាពត្រឹមត្រូវរឺយ៉ាងណា៖

| | | | |
|---|---|---|---|
| តើដំណើរការនៃការអនុវត្តមានប្រសិទ្ធភាពរឺទេ | តើវាបានឆ្លើយតបទៅនឹងវត្ថុបំណងនៃការដាក់ចេញការអនុវត្តនោះរឺទេ | តើបានអនុលោមតាមបញ្ញត្តិច្បាប់ និងគោលការណ៍រឺទេ | តើមានការបាត់បង់រឺការប្រើប្រាស់ខុសគោលដៅរឺទេ |

ផ្នែកសវនកម្មផ្ទៃក្នុង ជាភ្នាក់ងារឯករាជ្យដែលត្រូវរាយការណ៍ជូនដោយឯករាជ្យទៅគណៈកម្មការសវនកម្មនៃក្រុមប្រឹក្សាភិបាល។

ក្នុងឆ្នាំ2018 ក្រុមសវនករបានអនុវត្តន៍ការងារសវនកម្មរបស់ខ្លួនបាន 116 សាខាទូទាំងប្រទេស បាន8នាយកដ្ឋាន និងបាន5សវនកម្មលើការងារសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យា។ សវនករបានចេញរបាយការណ៍ជូន ភាគីពាក់ព័ន្ធ និងគណៈកម្មការសវនកម្ម។

### សំរាប់ឆ្នាំ2019 សវនករយើងនឹងផ្តោតការយកចិត្តទុកដាក់បន្ថែមលើ៖

1. បន្តអភិវឌ្ឍសមត្ថភាពបុគ្គលិក តាមរយៈការបញ្ញៀបពីសហការីខាងក្នុង និងការចូលរួមសិក្សានៅខាងក្រៅ។
2. បន្តបង្កើនប្រសិទ្ធភាពការងារសវនកម្មរបស់ខ្លួន តាមរយៈការត្រួតពិនិត្យនីតិវិធីឡើងវិញជាប្រចាំ និងបំពេញបន្ថែម។
3. បន្តទាក់ទាញ និងពង្រឹងការយល់ដឹកពីភាគីពាក់ព័ន្ធ និងបញ្ញៀបការគិតនានាដោយភ្ជាប់ជាមួយហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យជាចាំបាច់។
4. បន្តពង្រឹងបន្ថែម ដើម្បីអោយប្រាកដថាការងារសវនកម្មគឺស្របតាមច្បាប់ទំលាប់ និងបទដ្ឋាននានា។

# របាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 និងរបាយការណ៍របស់សវនករឯករាជ្យ

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ស្ថាបនា ភីអិលស៊ី («ធនាគារ») មានសេចក្តីសោមនស្សរីករាយបង្ហាញជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

## ព័ត៌មានអំពីធនាគារ

ស្ថាបនា លីមីតធីត ហៅកាត់ថា («គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ») ត្រូវបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាមួយក្រសួងពាណិជ្ជកម្ម នាថ្ងៃទី19 ខែកុម្ភៈ ឆ្នាំ2003 ដែលកើតចេញពីលក្ខន្តិកៈចុះថ្ងៃទី27 ខែធ្នូ ឆ្នាំ2002 រវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ1996 និងបុគ្គលិករបស់ធនាគារ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិជាធនាគារមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី23 ខែមេសា ឆ្នាំ2003។ ក្រោមអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឲ្យផ្តល់ឥណទាន និងសេវាផ្តល់ប្រាក់សន្សំដល់ក្រុមគ្រួសារក្រីក្រមានចំណូលទាប និងសហគ្រិនធុនតូច ដែលធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា។

ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណអចិន្ត្រៃយ៍ នាថ្ងៃទី19 ខែមេសា ឆ្នាំ2006។ នៅថ្ងៃទី22 ខែមករា ឆ្នាំ2009 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់សេវាកម្មទទួលប្រាក់បញ្ញើ។ នៅថ្ងៃទី11 ខែកុម្ភៈ ឆ្នាំ2014 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានទទួលអាជ្ញាប័ណ្ណរយៈពេល 3ឆ្នាំ ដើម្បីផ្តល់សេវាកម្មប្តូរប្រាក់។

នៅថ្ងៃទី19 ខែតុលា ឆ្នាំ2012 ធនាគារ ម៉ារូហាន់ ជប៉ុន ភីអិលស៊ី (“MJB”) បានចុះកិច្ចសន្យាទិញ លក់ ជាមួយ Stichting Triodos-Doen (“ST”), Nederlandse Financierings-Maatschapij Voor Ontwikellingslanden N.V. (“NFVO”) DWM Funds S.C.A - SICAV SIF (“DWM”), Cambodia Community Building (CCB) និង Sathapana Employee Investment Limited (“SEI”) ដើម្បីទិញភាគហ៊ុនចំនួន 95.1% ពីស្ថាបនា លីមីតធីត។ ដំណើរការនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី5 ខែធ្នូ ឆ្នាំ2012។ លើសពីនេះទៅទៀត ក្រសួងពាណិជ្ជកម្មបានអនុម័តទៅលើការប្តូរកម្មសិទ្ធិនៃដើមទុននៅថ្ងៃទី17 ខែធ្នូ ឆ្នាំ2012។

នៅថ្ងៃទី8 ខែកុម្ភៈ ឆ្នាំ2016 ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងជាមួយ CCB ក្រុមប្រឹក្សាភិបាលរបស់ធនាគារបានសម្រេចចិត្តថា ភាគីពុំមានប្រយោជន៍គ្រប់គ្រងធនាគារ ដែលបានទិញភាគហ៊ុននៅសល់ចំនួន 4.9% ពីធនាគារ។ ភាគហ៊ុននេះតំណាងអោយភាគហ៊ុនរបស់ភាគីពុំមានប្រយោជន៍គ្រប់គ្រងធនាគារចំនួនទឹកប្រាក់សរុប 6.02 លានដុល្លារអាមេរិកនៃចំណែកភាគតិចនៃភាគហ៊ុនរបស់ធនាគារ។ ប្រតិបត្តិការត្រូវបានបញ្ចប់នៅថ្ងៃទី17 ខែមីនា ឆ្នាំ2016។

នៅដើមឆ្នាំ2015 ធនាគារ ម៉ារូហាន់ ធនាគារ ជប៉ុន ភីអិលស៊ី និងស្ថាបនា លីមីតធីត បានយល់ព្រមរួមបញ្ចូលធនាគារទាំងពីរជាធនាគារតែមួយ ដោយមានឈ្មោះថ្មីជាធនាគារ ស្ថាបនា ភីអិលស៊ី ដែលទទួលបានការអនុម័តជាផ្លូវការពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី28 ខែមីនា ឆ្នាំ2016។ នៅថ្ងៃទី29 ខែមីនា ឆ្នាំ2016 ធនាគារជាតិបានផ្តល់អាជ្ញាប័ណ្ណធនាគារអចិន្ត្រៃយ៍ដល់ធនាគារស្ថាបនាភីអិលស៊ី។ រាល់ទ្រព្យសកម្មនិងបំណុលទាំងអស់របស់ MJB បានផ្ទេរទៅឲ្យធនាគារ នៅថ្ងៃទី1 ខែមេសា ឆ្នាំ2016។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ធនាគារមានដូចខាងក្រោម៖

- ផ្តល់ឥណទាន មីក្រូឥណទានខ្នាតតូច និងមធ្យម
- ផ្តល់សេវាកម្ម ដាក់ប្រាក់បញ្ញើ
- ផ្តល់សេវាកម្មផ្ទេរលុយ ក្នុងស្រុក និងក្រៅស្រុក
- ផ្តល់សេវាកម្ម ATM និង សេវាធនាគារ តាមប្រព័ន្ធអ៊ីនធឺណេត
- ផ្តល់សេវាកម្មទាក់ទងនឹងធនាគារនិងហិរញ្ញវត្ថុផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## ទីតាំង

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ 83 មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារ មានប្រតិបត្តិការអាជីវកម្មរបស់ខ្លួនក្នុង25 ខេត្ត ក្រុង ដែលមានបណ្តាញសាខាចំនួន 169 សាខា។

## បុគ្គលិក

នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ធនាគារមានបុគ្គលិកចំនួន 4,456 នាក់ (ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2017: 4,339 នាក់)។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 មានដូចខាងក្រោម៖

| | 2018 | 2017 |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ប្រាក់ចំណេញមុនបង់ពន្ធ | 28,233,400 | 23,805,608 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (5,139,203) | (5,219,569) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **23,094,197** | **18,586,039** |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ - ពាន់រៀល** | **92,792,484** | **75,031,840** |

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនបានស្នើឲ្យមានការបែងចែកភាគលាភណាមួយ សម្រាប់ការិយបរិច្ឆេទធ្វើសវនកម្មនេះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ដើមទុន

គ្មានការផ្លាស់ប្តូរ និងបន្ថែមដើមទុនរបស់ធនាគារសម្រាប់ការិយបរិច្ឆេទនេះទេ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលចេញពីបញ្ជីផ្តល់អោយឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនសមស្របត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់ សម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃការលុបចេញពីបញ្ជីឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

## ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មក្រៅពីបំណុល ដែលសន្និដ្ឋានថាមិនអាចប្រមូលមកវិញបានតាមតម្លៃ ដែលបានកត់ត្រានៅក្នុងបញ្ជីនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានភាពពុំត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងហើយប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រ ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះពុំមាន៖

(ក) បន្ទុកណាមួយលើទ្រព្យសកម្មណាមួយរបស់ធនាគារ ដែលកើតឡើងក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក និង

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារ ចាប់តាំងពីចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលធនាគារត្រូវបង្ខំឲ្យសង ឬទាមទារឲ្យសងក្នុងអំឡុងពេល 12ខែ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ ដែលនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

## ការប្រែប្រួលសភាពការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារពុំបានពិនិត្យឃើញសភាពការណ៍ណាមួយ ដែលមិនបានរៃរាប់នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹងបណ្តាលឲ្យមានតួលេខណាមួយ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ធាតុមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាលលទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយធាតុសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានតម្លៃជាសារវន្ត និងមានលក្ខណៈមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះពុំមានធាតុសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការចាប់តាំងពីថ្ងៃដែលចេញរបាយការណ៍មុន រួមមាន៖

| | |
|---|---|
| **បណ្ឌិត Han Chang-Woo** | ប្រធានក្រុមប្រឹក្សាភិបាល (មិនប្រតិបត្តិ) |
| **លោក Han Yu** | អភិបាលមិនប្រតិបត្តិ |
| **លោក Han Ken** | អភិបាលមិនប្រតិបត្តិ |
| **ឯកឧត្តម Shinohara Katsuhiro** | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| **ឯកឧត្តម គឹម វ៉ាដា** | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| **លោក ហ៊ុន មុន្នីវណ្ណ** | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| **លោក Norihiko Kato** | អភិបាលប្រតិបត្តិ (លាលែងពីតំណែងនៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2018) |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

មិនមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ធនាគារដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនោះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ មិនមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃ។

ចាប់តាំងពីថ្ងៃចុងក្រោយនៃការិយបរិច្ឆេទកន្លងទៅ ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់របស់ធនាគារបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបទទួលបាន ឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយក្រុមហ៊ុនពាក់ព័ន្ធដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយធនាគារដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះ លើកលែងតែត្រូវបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(i) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

(ii) គោរពតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញនូវភាពត្រឹមត្រូវ ការប្រាសចាកទាំងនេះ ត្រូវតែបង្ហាញពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(iv) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យលើកលែងតែគណៈគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ឬផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ, និង

(v) ត្រួតពិនិត្យ និងដឹកនាំធនាគារឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំតំណាងឲ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយនេះ ថាបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគទុនិក

**លោក លឹម អួន**
ប្រធាននាយកប្រតិបត្តិ

**លោក ស៊ឹយ ប៉ុណ្ណរតន៍**
នាយកប្រតិបត្តិហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2019

# របាយការណ៍របស់សវនករឯករាជ្យ

**ជូនចំពោះភាគទុនិកនៃធនាគារ ស្ថាបនា ភីអិលស៊ី**

## មតិយោបល់សវនករ

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ ស្ថាបនា ភីអិលស៊ី ហៅកាត់ថា (“ធនាគារ”) ដែលរួមមានតារាងតុល្យការ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 របាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុដែលរួមមានគោលនយោបាយគណនេយ្យសង្ខេបសំខាន់ៗ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពពិតប្រាកដ និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដារទាំងនោះត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ”ការទទួលខុសត្រូវរបស់ សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ”ដែលមាននូវក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីធនាគារ ដោយអនុលោមតាមអនុក្រឹតស្តីពីក្រមសីលធម៌ សម្រាប់គណនេយ្យករវិជ្ជាជីវៈ និងសនវករវិជ្ជាជីវ ដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើដទៃទៀត ដែលតម្រូវដោយក្រមសីលធម៌នេះដែរ។ យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## បញ្ហាផ្សេងៗទៀត

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2017 ត្រូវបានធ្វើសវនកម្មដោយសវនករដទៃទៀត ដែលបានបង្ហាញគំនិតមិនទាន់កែប្រែលើរបាយការណ៍ទាំងនោះ នៅថ្ងៃទី26 ខែមីនា ឆ្នាំ2018។

**ព័ត៌មានផ្សេងៗក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងសវនកម្ម**

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញ នៅទំព័រទី40 ដល់ទី43។

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំ មិនផ្តល់នូវអំណះអំណាងសន្និដ្ឋានណាមួយទៅលើព័ត៌មាននេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះមានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំទទួលបាននៅក្នុងពេលធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។ ប្រសិនបើ ផ្អែកលើការអានព័ត៌មានផ្សេងៗ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

គណៈគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពពិតប្រាកដត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា បទប្បញ្ញត្តិ និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធ ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម និងទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើមានបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យលើកលែងតែគណៈគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។ អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យនីតិវិធីរៀបចំហិរញ្ញវត្ថុរបស់ធនាគារ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺស្វែងរកនូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានកំហុសឆ្គងជាសារវន្តដោយសារតែការក្លែងបន្លំ ឬការភ័ន្តច្រលំ និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវកំហុសឆ្គងសារវន្តដែលបានកើតឡើងនោះទេ។ កំហុសឆ្គងជាសារវន្តអាចកើតឡើង ដោយសារការក្លែងបន្លំ ឬការភ័ន្តច្រលំហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាអាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវចម្ងល់និយមក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬការភ័ន្តច្រលំ និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តន៍នូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវកំហុសឆ្គងខុសជាសារវន្ត ដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការរាយការណ៍មិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ស្វែងយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណង ដើម្បីរៀបចំនូវនីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណង ដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ។
- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលធនាគារបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធ ដែលបានធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាព អាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់គណៈគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានធ្វើការសន្និដ្ឋានថា តើភាពមិនច្បាស់លាស់សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬកាលៈទេសៈដែលអាចធ្វើឲ្យមានការសង្ស័យជាសារវន្តលើលទ្ធភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានភាពមិនច្បាស់លាស់កើតឡើងជាសារវន្តនោះ យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគតអាចធ្វើឲ្យធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថា តើរបាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីបញ្ហាផ្សេងទៀតដូចជា វិសាលភាព និងពេលវេលា ដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញសំខាន់ៗជាសារវន្តផ្សេងទៀត ដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការត្រួតពិនិត្យផ្ទៃក្នុង ដែលយើងបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។



**Maria Cristina M. Calimbas**
Partner
Ernst & Young (Cambodia) Ltd.
ក្រុមហ៊ុនគណនេយ្យករជំនាញ និង សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ធ្វើនៅថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2019

# តារាងតុល្យការ

**នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018**

| | កំណត់សម្គាល់ | 2018 | | 2017 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 4 | 67,916,384 | 272,888,031 | 43,744,709 | 176,597,390 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 5 | 168,970,016 | 678,921,524 | 124,540,739 | 502,770,963 |
| សមតុល្យនៅធនាគារផ្សេងៗ | 6 | 7,792,978 | 31,312,186 | 19,095,480 | 77,088,453 |
| ឥណទានផ្តល់ឲ្យអតិថិជន | 7 | 1,007,139,509 | 4,046,686,547 | 794,125,991 | 3,205,886,626 |
| ទ្រព្យ និងបរិក្ខារ | 10 | 10,238,649 | 41,138,892 | 8,016,784 | 32,363,757 |
| ទ្រព្យសកម្មអរូបី | 11 | 1,463,686 | 5,881,090 | 943,246 | 3,807,884 |
| ការវិនិយោគផ្សេងៗ | 12 | 50,000 | 200,900 | 50,000 | 201,850 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 17 (ក) | 4,903,785 | 19,703,408 | 3,048,924 | 12,308,506 |
| តម្លៃកេរ្តិ៍ឈ្មោះ | 9 | 17,380,030 | 69,832,961 | 17,380,030 | 70,163,181 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 18,771,988 | 75,425,848 | 16,848,396 | 68,016,975 |
| **ទ្រព្យសកម្មសរុប** | | **1,304,627,025** | **5,241,991,387** | **1,027,794,299** | **4,149,205,585** |
| **បំណុល និង មូលធនរបស់ភាគទុនិក បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | | 804,699,381 | 3,233,282,113 | 618,172,252 | 2,495,561,381 |
| ប្រាក់កម្ចី | 14 | 253,817,389 | 1,019,838,269 | 214,788,333 | 867,100,500 |
| បំណុលបន្ទាប់បន្សំ | 15 | 30,000,000 | 120,540,000 | 13,000,000 | 52,481,000 |
| មូលនិធិសោធននិវត្តន៍ | 16 | 12,923,876 | 51,928,134 | 10,378,502 | 41,898,013 |
| បំណុលពន្ធលើប្រាក់ចំណេញ | 17 (ខ) | 5,705,331 | 22,924,020 | 4,444,141 | 17,940,997 |
| បំណុលផ្សេងៗ | 18 | 20,207,444 | 81,193,510 | 12,831,664 | 51,801,428 |
| **បំណុលសរុប** | | **1,127,353,421** | **4,529,706,046** | **873,614,892** | **3,526,783,319** |
| **មូលធនរបស់ភាគទុនិក** | | | | | |
| ដើមទុន | 19 | 120,000,000 | 482,160,000 | 120,000,000 | 484,440,000 |
| ប្រាក់ចំណេញរក្សាទុក | | 57,273,604 | 230,125,341 | 34,179,407 | 137,982,266 |
| **មូលធនរបស់ភាគទុនិកសរុប** | | **177,273,604** | **712,285,341** | **154,179,407** | **622,422,266** |
| **បំណុល និងមូលធនរបស់សរុប ភាគទុនិកសរុប** | | **1,304,627,025** | **5,241,991,387** | **1,027,794,299** | **4,149,205,585** |

កំណត់សំគាល់ពី1 ដល់ 29 ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍លទ្ធផល

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

| | កំណត់សម្គាល់ | 2018 | | 2017 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **ចំណូលប្រតិបត្តិការ** | | | | | |
| ចំណូលពីការប្រាក់ | 20 | 130,966,956 | 526,225,229 | 115,992,555 | 468,261,945 |
| ចំណាយលើការប្រាក់ | 21 | (51,616,010) | (207,393,128) | (49,463,241) | (199,683,104) |
| **ចំណូលពីការប្រាក់សុទ្ធ** | | **79,350,946** | **318,832,101** | **66,529,314** | **268,578,841** |
| ចំណូលកម្រៃ និងជើងសារសុទ្ធ | 22 | 7,444,028 | 29,910,105 | 5,370,725 | 21,681,617 |
| ចំណូលប្រតិបត្តិការផ្សេងៗ | | 1,486,694 | 5,973,536 | 660,511 | 2,666,483 |
| **ចំណេញពីប្រតិបត្តិការ** | | **88,281,668** | **354,715,742** | **72,560,550** | **292,926,941** |
| សំវិធានធនលើសមតុល្យនៅធនាគារផ្សេងៗឥណទាននិងបុរេប្រទាន និងកាតព្វកិច្ចឥណទាន/ហិរញ្ញវត្ថុ និងការធានាហិរញ្ញវត្ថុ សំវិធានធនលើសមតុល្យលើធនគារ | 6, 7, 18 | (7,626,415) | (30,642,935) | (4,871,366) | (19,665,705) |
| ចំណាយប្រតិបត្តិការផ្សេងៗ | 23 | (52,421,853) | (210,631,005) | (43,883,576) | (177,157,996) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | | **28,233,400** | **113,441,802** | **23,805,608** | **96,103,240** |
| ចំណាយពន្ធលើប្រាក់ចំណេញ | 17 | (5,139,203) | (20,649,318) | (5,219,569) | (21,071,400) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **23,094,197** | **92,792,484** | **18,586,039** | **75,031,840** |

កំណត់សំគាល់ពី1 ដល់ 29 ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018**

| | ដើមទុន ដុល្លារអាមេរិក | បុព្វលាភដើមទុន ដុល្លារអាមេរិក | ប្រាក់ចំណេញ រក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|
| នាថ្ងៃទី1 ខែមករា ឆ្នាំ2018 | 120,000,000 | - | 34,179,407 | 154,179,407 |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 23,094,197 | 23,094,197 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | **120,000,000** | **-** | **57,273,604** | **177,273,604** |
| **( សមមូលពាន់រៀល - កំណត់សម្គាល់ 3 )** | **482,160,000** | **-** | **230,125,341** | **712,285,341** |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2017 | 120,000,000 | - | 15,593,368 | 135,593,368 |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 18,586,039 | 18,586,039 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | **120,000,000** | **-** | **34,179,407** | **154,179,407** |
| **( សមមូលពាន់រៀល - កំណត់សម្គាល់ 3 )** | **484,440,000** | **-** | **137,982,266** | **622,422,266** |

កំណត់សំគាល់ពី1 ដល់ 29 ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍លំហូរសាច់ប្រាក់

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018**

| | | 2018 | | 2017 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់3) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | **24** | **(32,163,814)** | **(129,234,206)** | **(152,091,243)** | **(613,992,348)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | 10 | (5,214,074) | (20,950,149) | (3,647,943) | (14,726,746) |
| ការទិញទ្រព្យសកម្មអរូបី | 11 | (624,028) | (2,507,345) | (262,001) | (1,057,698) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | | 33,416 | 134,265 | 454 | 1,833 |
| សកម្មភាពវិនិយោគ | | **(5,804,686)** | **(23,323,229)** | **(3,909,490)** | **(15,782,611)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ប្រាក់ទទួលបានពីប្រាក់កម្ចី | | 153,213,539 | 615,612,000 | 104,500,000 | 421,866,500 |
| ការទូទាត់សងប្រាក់កម្ចី | | (95,184,484) | (382,451,257) | (60,433,015) | (243,968,082) |
| ការទូទាត់សងបំណុលបន្ទាប់បន្សំ | | (2,000,000) | (8,036,000) | (3,313,217) | (13,375,456) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | **56,029,055** | **225,124,743** | **40,753,768** | **164,522,962** |
| **ការកើនឡើង/(ថយចុះ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **18,060,555** | **72,567,308** | **(115,246,965)** | **(465,251,997)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី1 ខែមករា | | 78,602,584 | 315,825,183 | 193,849,549 | 782,570,629 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី31 ខែធ្នូ** | **4** | **96,663,139** | **388,392,492** | **78,602,584** | **317,318,632** |

កំណត់សំគាល់ពី1 ដល់ 29 ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018**

## ១. មូលដ្ឋាននៃការរៀបចំ

### *១.១. របាយការណ៍អនុលោមភាព*

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ដែលពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានអនុម័ត និងផ្តល់សិទ្ធិផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2019។

### *១.២. មូលដ្ឋាននៃការវាស់វែង*

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើមដំបូង។

### *១.៣.រូបិយប័ណ្ណសម្រាប់មុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ*

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ធនាគារ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀត ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុនឹងបំណុលរូបិយវត្ថុ ដែលជារូបិយប័ណ្ណផ្សេងទៀតក្រៅពីប្រាក់ដុល្លារអាមេរិក នាកាលបរិច្ឆេទរបាយការណ៍ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើអត្រានាកាលបរិច្ឆេទនោះ។ លម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ធនាគារ។ តួលេខទាំងអស់ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុតបើមិនដូច្នេះទេលុះត្រាតែមានការបង្ហាញផ្សេងពីនោះ។

### *១.៤. ការប៉ាន់ស្មាន និងការវិនិច្ឆ័យ*

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តន៍នូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្មបំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើប៉ាន់ស្មាននៃគណនេយ្យត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទ ដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែ និងនាការិយបរិច្ឆេទអនាគតដែលប៉ះពាល់ដោយការកែប្រែនេះ។

ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យចម្បងត្រូវបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ រួមមានការប៉ាន់ស្មាននូវចំនួនដែលអាចប្រមូលបានមកវិញពីឥណទានផ្តល់ឲ្យអតិថិជន ដែលបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យ ដោយឡែកក្នុងកំណត់សំគាល់ទី2.7។

## ២. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ដោយធនាគារ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះមានដូចខាងក្រោម។ គោលនយោបាយទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់គ្រប់ការិយបរិច្ឆេទទាំងអស់ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ប្រកបដោយសង្គតិភាព លើកលែងតែចំណុចដែលបានបញ្ជាក់។

### *២.១. មូលដ្ឋាននៃការប្រមូលផ្តុំ*

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគាររួមមាន របាយការណ៍ហិរញ្ញវត្ថុរបស់ការិយាល័យកណ្តាល និងសាខារបស់ធនាគារ។ រាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាត្រូវបានលុបចោល។

### *២.២.ឧបករណ៍ហិរញ្ញវត្ថុ*

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ធនាគាររួមមាន សាច់ប្រាក់ និងសាច់ប្រាក់សមមូល ការផ្តល់ឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើ គណនីត្រូវទទួលផ្សេងៗ បំណុល និងគណនីត្រូវទូទាត់ផ្សេងៗ។ គោលនយោបាយគណនេយ្យស្តីពីការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះ ត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកពីគ្នា។

### *២.៣.សាច់ប្រាក់ និងសាច់ប្រាក់សមមូល*

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគារ នៅធនាគារជាតិនៃកម្ពុជា ប្រាក់បញ្ញើចរន្តនៅធនាគារហិរញ្ញវត្ថុដទៃទៀត និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល 3ខែ ឬតិចជាង និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

### *២.៤. សមតុល្យនៅធនាគារជាតិនៃកម្ពុជា*

សមតុល្យធនាគារជាតិនៃកម្ពុជា ដែលរួមមានប្រាក់បញ្ញើតម្កល់តាមច្បាប់ត្រូវបានកត់ត្រាតាមតម្លៃដើម។

ប្រាក់បញ្ញើតម្កល់តាមច្បាប់ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីធនាគារ ធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមារបស់ធនាគារ និងប្រាក់បញ្ញើរបស់អតិថិជន ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

### *២.៥. សមតុល្យនៅធនាគារផ្សេងៗ*

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពតម្លៃ សម្រាប់ចំនួនណាដែលមិនអាចប្រមូលវិញបាន។

### *២.៦. ឥណទានផ្តល់ឲ្យអតិថិជន*

ឥណទានផ្តល់ឲ្យអតិថិជន ត្រូវបានកត់ត្រានៅក្នុងតារាងតុល្យការតាមប្រាក់ដើមដកចេញចំនួនទាំងឡាយណា ដែលបានជម្រះបញ្ជី និងសំវិធានធនលើឥណទានជាក់លាក់ និងទូទៅជាប់សង្ស័យ។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ២. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ២.៧. សំវិធានធនលើសមតុល្យនៅធនាគារផ្សេងៗ, ឥណទាន និងបុរេប្រទាន និងភាគច្រើនកិច្ចឥណទាន/ហិរញ្ញវត្ថុ និងការធានាហិរញ្ញវត្ថុ

អនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា វាល់ហ្វាស៊ីលីធី ត្រូវបានចាត់ចំណាត់ថ្នាក់ ដោយយោងទៅតាមលទ្ធភាពនៃការទូទាត់សងរបស់បដិភាគី។ លទ្ធភាពនៃការទូទាត់សងនេះត្រូវបានវាយតម្លៃ ដោយផ្អែកទៅតាមបទពិសោធន៍នៃការទូទាត់សងពីមុន ស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល ស្ថានភាពអាជីវកម្ម និងលំហូរសាច់ប្រាក់ព្យាករណ៍ លទ្ធភាព និងឆន្ទៈនៃសងត្រលប់របស់កូនបំណុល បរិយាកាសហិរញ្ញវត្ថុ និងគុណភាពនៃឯកសារ។

លើសពីនេះ នៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសលេខ ធ7-017-344 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន និងសារាចរណែនាំលេខធ7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីការអនុវត្តន៍ប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ដែលតម្រូវឲ្យធនាគារ និងហិរញ្ញវត្ថុ («ធនាគារ») ទាំងអស់ធ្វើការវាស់វែងលើអ៊ីមភែរមិន និងផ្តល់សំវិធានធនគ្រប់គ្រាន់លើហ្វាស៊ីលីធីទាំងអស់ ដោយផ្អែកលើចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនថ្មីមានដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់សង | សំវិធានធន |
|---|---|---|
| **ឥណទានរយៈពេលខ្លី( តិចជាង ឬស្មើ 1ឆ្នាំ)** | | |
| ឥណទានធម្មតា/ស្តង់ដារ | ≤14 ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | 15 ថ្ងៃ - 30 ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដារ | 31 ថ្ងៃ - 60 ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | 61ថ្ងៃ - 90 ថ្ងៃ | 50% |
| ឥណទានបាត់បង់ | ≥ 91 ថ្ងៃ | 100% |
| **ឥណទានរយៈពេលវែង (ច្រើនជាង1ឆ្នាំ)** | | |
| ឥណទានធម្មតា/ស្តង់ដារ | <30 ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | ≥ 30 ថ្ងៃ - 89 ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដារ | ≥ 90 ថ្ងៃ - 179 ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | ≥ 180 ថ្ងៃ - 359 ថ្ងៃ | 50% |
| ឥណទានបាត់បង់ | 359ថ្ងៃ ឬលើស | 100% |

ការកំណត់សំវិធានធនខាងលើនេះ ត្រូវបានធ្វើឡើងដោយមិនគិតពីតម្លៃនៃទ្រព្យបញ្ចាំទេ លើកលែងតែទ្រព្យបញ្ចាំជាសាច់ប្រាក់ ដែលបានតម្កល់នៅធនាគារ។ ក្នុងករណីដែលឥណទានត្រូវបានធ្វើចំណាត់ថ្នាក់ជា «ឥណទានបាត់បង់» ទ្រព្យបញ្ចាំទាំងអស់ត្រូវបានប្រើប្រាស់តាមតម្លៃទីផ្សារ ដែលអនុម័តដោយធនាគារជាតិនៃកម្ពុជា។

ភាពគ្រប់គ្រាន់នៃសំវិធានធន សម្រាប់ហ្វាស៊ីលីធីទាំងអស់ ត្រូវបានវាយតម្លៃជាទៀងរាល់ខែ ដោយគណៈគ្រប់គ្រង។ កត្តាដែលជំរុញក្នុងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃសំវិធានធនរួមមាន ទំហំនៃសំពៅឥណទានបទពិសោធន៍នៃការបាត់បង់ពីមុនៗមកលក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុរបស់អតិថជននឹងស្ថានភាពឥណទានទៅតាមលក្ខខណ្ឌនៃពេលកិច្ចសន្យា។

ហ្វាស៊ីលីធីមិនអាចទារបាន ឬចំណែកនៃហ្វាស៊ីលីធី ដែលបានចាត់ថ្នាក់ជាហ្វាស៊ីលីធីអាក្រក់នឹងត្រូវជម្រះបញ្ជី បន្ទាប់ពីមានការគិតគូរទៅលើតម្លៃលក់បាននៃទ្រព្យបញ្ចាំ ហើយប្រសិនបើនៅពេលដែលគណៈគ្រប់គ្រងវិនិច្ឆ័យឃើញថា ពុំមានសង្ឃឹមនឹងទារបាននូវហ្វាស៊ីលីធីទាំងនោះមកវិញទេ។

ការប្រមូលមកវិញនូវហ្វាស៊ីលីធីផ្តល់ឲ្យអតិថិជន ដែលបានជម្រះបញ្ជី និងការបញ្ច្រាសមកវិញនូវសំវិធានធនពីមុនត្រូវបានបង្ហាញជាចំណូលផ្សេងៗនៅក្នុងរបាយការណ៍លទ្ធផល។

### ២.៨. ការប្រាក់ជាប់សង្ស័យ

ការប្រាក់ជាប់សង្ស័យ ជាការប្រាក់របស់ឥណទាន ដែលមិនមានដំណើរការ ដែលត្រូវបានកត់ត្រាជាសំវិធានធនជាជាងចំណូលរហូតដល់ទទួលបានជាសាច់ប្រាក់ពិតប្រាកដ។

ការប្រាក់ជាប់សង្ស័យត្រូវបានបង្ហាញ ដោយដកចេញពីការប្រាក់ដែលត្រូវទទួល។

### ២.៩. ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗត្រូវបានកត់ត្រាទៅតាមតម្លៃដើមដកសំវិធានធនខាតបង់។

### ២.១០.ទ្រព្យ និងបរិក្ខារ ទ្រព្យអរូបី និងតម្លៃកេរ្តិ៍ឈ្មោះ

(i) ផ្នែកនៃទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពតម្លៃបង្គរ ប្រសិនបើមាន។ នៅពេលដែលធាតុសំខាន់ៗនៃទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នារបស់ទ្រព្យ និងបរិក្ខារ។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018**

## ២. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ii) ការចំណាយបន្ទាប់ ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ធនាគារ លើសពីស្តង់ដារដើម។ រាល់ការចំណាយបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

(iii) ចំណេញ ឬខាតពីការឈប់ប្រើ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលនាថ្ងៃឈប់ប្រើ ឬលក់ចេញ។

(iv) ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃ ដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល។

(v) ទ្រព្យសកម្មអរូបី ដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ និងអាជ្ញាប័ណ្ណកម្មវិធីធនាគារស្នូលត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ប្រសិនបើមាន។ ការទិញកម្មវិធីកុំព្យូទ័រ ត្រូវធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលកើតឡើងពាក់ព័ន្ធទៅនឹងការទិញកម្មវិធីកុំព្យូទ័រជាក់លាក់ ហើយដែលអាចដាក់ប្រើប្រាស់បាន។

(vi) តម្លៃកេរ្តិ៍ឈ្មោះត្រូវបានទិញ នៅពេលមានការរួមបញ្ចូលគ្នានៃអាជីវកម្ម គឺត្រូវបានវាស់វែងជាលើកដំបូងតាមតម្លៃដើម ដែលលើសពីតម្លៃដើមនៃការរួមបញ្ចូលនៃអាជីវកម្មជាងការប្រាក់នៃតម្លៃទីផ្សារសុទ្ធនៃទ្រព្យសកម្ម បំណុល និងបំណុលយថាហេតុដែលអាចកត់សំគាល់បាន យោងតាមការទទួលស្គាល់លើកដំបូងតម្លៃកេរ្តិ៍ឈ្មោះត្រូវបានវាស់វែងទៅតាមថ្លៃដើមនៃការបាត់បង់ឱនភាព (សូមទៅមើលនៅគោលការណ៍គណនេយ្យនៃឱនភាពនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុ)។

### ២.១១. ចំនាយរំលស់ទ្រព្យបរិក្ខារ និងទ្រព្យអរូបី

ក្នុងឆ្នាំ2018 ធនាគារបានផ្លាស់ប្តូរវិធីសាស្រ្តរំលស់ទ្រព្យ និងបរិក្ខារបស់ខ្លួនពីវិធីសាស្រ្តរំលស់ថយចុះទៅវិធីសាស្រ្តថេរ។ ការផ្លាស់ប្តូរវិធីសាស្រ្តរំលស់នេះ គឺដើម្បីឆ្លុះបញ្ចាំងពីលំហូរសេដ្ឋកិច្ចនៃការប្រើប្រាស់ទ្រព្យនិងបរិក្ខារ និងទ្រព្យអរូបីដូចខាងក្រោម៖

| | 2018 | 2017 |
|---|---|---|
| | អាយុកាលនៃវិធីសាស្រ្តរំលស់ថេរ | ភាគរយនៃវិធីសាស្រ្តរំលស់ថយចុះ |
| ទ្រព្យអរូបី | 10 | 10% |
| បរិក្ខារកុំព្យូទ័រ និងបរិក្ខារបន្ទាប់បន្សំ | 3 | 50% |
| បរិក្ខារកុំព្យូទ័រ និងម៉ាស៊ីនព្រីន | 5 | 50% |
| ប្រព័ន្ធកុំព្យូទ័រមេ | 7 | 50% |
| ម៉ាស៊ីនដក/ដាក់ប្រាក់ | 7 | 50% |
| បរិក្ខារឧបករណ៍ការិយាល័យ | 4 | 25% |
| គ្រឿងសង្ហារឹមការិយាល័យ | 6 | 25% |
| រថយន្ត | 10 | 25% |
| ទោចក្រយានយន្ត | 5 | 25% |
| ការកែលម្អលើទ្រព្យជួល | 5 | 20% |
| បរិក្ខារផ្សេង | 4 | 20% |

ការផ្លាស់ប្តូរវិធីសាស្រ្តរំលស់នេះ មិនមានផលប៉ះពាល់ជាសារវន្តទេចំពោះធនាគារ។

ទ្រព្យ និងបរិក្ខារកំពុងសាងសង់ មិនត្រូវបានធ្វើរំលស់រហូតដល់ពេលដែលទ្រព្យ និងបរិក្ខារពាក់ព័ន្ធត្រូវបានបញ្ចប់ និងដាក់ឱ្យដំណើរការប្រើប្រាស់ដោយគណៈគ្រប់គ្រង។

### ២.១២. ឱនភាពនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដែលមានអាយុកាលច្បាស់លាស់ត្រូវបានត្រួតពិនិត្យឡើងវិញ នៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយ ដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃ ដែលអាចប្រមូលបានវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។ សម្រាប់ទ្រព្យអរូបី ដែលមានអាយុកាលច្បាស់លាស់ ការតេស្តឱនភាពប្រចាំឆ្នាំ គឺត្រូវបានធ្វើឡើង។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃទីផ្សារដកចំណាយ ដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់លំហូរសាច់ប្រាក់នាពេលអនាគតត្រូវបានបញ្ចុះទៅតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្នលើតម្លៃពេលវេលានៃសាច់ប្រាក់ និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។ សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានចាត់ថ្នាក់ជាក្រុមតូចៗនៃទ្រព្យសកម្ម ដែលអាចបង្កើតលំហូរសាច់ប្រាក់ពីការបន្តការប្រើប្រាស់ដោយមិនពឹងផ្អែកខ្លាំងលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀតហៅកាត់ថា (“ឯកតាបង្កើតសាច់ប្រាក់”)។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មមួយ ឬឯកតាបង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃ ដែលអាចប្រមូលមកបានវិញ។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

### ២.១៣. ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារហិរញ្ញវត្ថុនានា

ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារហិរញ្ញវត្ថុនានាត្រូវបានបង្ហាញក្នុងតម្លៃថ្លៃដើម។

### ២.១៤. ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានបង្ហាញក្នុងតម្លៃថ្លៃដើមដែលនៅសល់។ កម្រៃជើងសារដែលបានបង់ក្នុងដំណើរការ បង្កើតប្រាក់កម្ចីត្រូវធ្វើមូលធនកម្ម និងធ្វើរំលស់ថេរ តាមរយៈពេលនៃប្រាក់កម្ចី។

ថ្លៃដើមប្រាក់កម្ចី (ចំណាយលើការប្រាក់) ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលកើតឡើង លើកលែងតែការប្រាក់នោះកើតឡើងពីការទិញ ការសាងសង់ ការផលិតទ្រព្យសកម្ម ដែលត្រូវធ្វើមូលធនកម្មជាផ្នែកនៃតម្លៃរបស់ទ្រព្យសកម្មនោះ។

### ២.១៥. បំណុលបន្ទាប់បន្សំ

បំណុលបន្ទាប់បន្សំ ត្រូវបានចាត់ទុកជាបំណុលហិរញ្ញវត្ថុនៅពេលដែលធនាគារមានកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុដល់អង្គភាពដទៃទៀត ឬដើម្បីដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយនឹងអង្គភាពមួយទៀត ក្រោមលក្ខខណ្ឌដែលមិនសូវអំណោយផលដល់ធនាគារ។ បំណុលបន្ទាប់បន្សំដែលបានអនុម័ត ដោយធនាគារជាតិនៃកម្ពុជាត្រូវបានដាក់បញ្ចូលជាដើមទុនថ្នាក់ទី2 ដើម្បីគណនាមូលនិធិផ្ទាល់សុទ្ធ ដោយអនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ បំណុលបន្ទាប់បន្សំត្រូវបានបង្ហាញក្នុងតម្លៃថ្លៃដើម។

បំណុលបន្ទាប់បន្សំត្រូវបានបង្ហាញតម្លៃថ្លៃដើម

### ២.១៦. សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការ នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាទំនងថា មានតម្រូវការលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ ដោយការបញ្ចុះតម្លៃលំហូរសាច់ប្រាក់ នាពេលអនាគតតាមអត្រាមុនបង់ពន្ធ ព្រោះឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្នលើតម្លៃពេលវេលានៃសាច់ប្រាក់ និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។

### ២.១៧. អត្ថប្រយោជន៍បុគ្គលិក

ប្រាក់បៀវត្ស ការឈប់សម្រាកប្រចាំឆ្នាំ និងពេលឈឺមានប្រាក់បៀវត្ស ប្រាក់លើកទឹកចិត្ត និងអត្ថប្រយោជន៍មិនមែនហិរញ្ញវត្ថុត្រូវបានកត់ត្រាបង្គរទុកក្នុងការិយបរិច្ឆេទ ដែលពាក់ព័ន្ធសេវាកម្មដែលបានបំពេញដោយបុគ្គលិកនៃធនាគារ។

ក្នុងឆ្នាំ2018 ធនាគារបានកត់ត្រាបង្គរទុកនូវប្រាក់បំណាច់អតីតភាពការងារតាមច្បាប់តម្រូវសម្រាប់ឆ្នាំ2018 និងឆ្នាំកន្លងមក ដោយអនុលោមតាមប្រកាសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ443 ចុះថ្ងៃទី21 ខែកញ្ញា ឆ្នាំ2018 ស្តីពីការអនុវត្តនៃការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ ប្រកាសនេះតម្រូវឲ្យប្រតិសកម្មការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ដែលស្មើនឹងប្រាក់ឈ្នួលរបស់បុគ្គលិកចំនួន 15ថ្ងៃ ក្នុងមួយឆ្នាំ ដែលត្រូវបើកឲ្យបុគ្គលិករៀងរាល់ឆ្នាំ ក្នុងកម្រិតអតិបរមា10ឆ្នាំ (មិនលើសពី ៦ខែ នៃប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមតាមឆ្នាំនីមួយៗ) ដែលស្មើ និងចាប់ផ្តើមទូទាត់ដូចខាងក្រោម៖

- ប្រាំពីរថ្ងៃកន្លះត្រូវបើកចាប់ពីខែមិថុនានៅឆ្នាំបន្ទាប់
- ប្រាំពីរថ្ងៃកន្លះត្រូវបើកចាប់ពីខែធ្នូនៅឆ្នាំបន្ទាប់

ធនាគារបានកត់ត្រាបង្គរទុកប្រាក់បំណាច់អតីតភាពការងារ ចំនួន 2,412,054 ដុល្លារអាមេរិក ជាផ្នែកនៃចំណាយបុគ្គលិក និងចំណាយពាក់ព័ន្ធ ដែលបង្ហាញនៅក្នុងចំណាយប្រតិបត្តិការផ្សេងៗ នៃរបាយការណ៍លទ្ធផល។

### ២.១៨. មូលនិធិសោធននិវត្តន៍

ធនាគារ បានផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកតាមគោលការណ៍មូលនិធិសោធននិវត្តន៍។ បុគ្គលិក ដែលបានបញ្ចប់ឆ្នាំសាកល្បង មានជម្រើសក្នុងការចូលរួមក្នុងគម្រោងមូលនិធិសោធននិវត្តន៍។ មូលនិធិសោធននិវត្តន៍ត្រូវបានផ្តល់មូលនិធិដូចខាងក្រោម៖

- បុគ្គលិកចូលរួមចំណែករហូតដល់ 5.0% នៃប្រាក់បៀវត្សប្រចាំខែរបស់បុគ្គលិក ហើយធនាគារចូលរួមចំណែកពីរដងនៃចំនួននោះ។ ការចូលរួមចំណែកនោះ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល។
- ធនាគារចូលរួមចំណែកផ្តល់ការប្រាក់លើសមតុល្យមូលនិធិសោធននិវត្តន៍បង្គរ ដោយគណនាតាមអត្រា 6.5% ក្នុងមួយឆ្នាំ។ ការចូលរួមចំណែកនោះ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល។

មូលនិធិសោធននិវត្តន៍នឹងបង់ជូនបុគ្គលិក (ដែលបានចូលរួមចំណែក) នៅពេលដែលចូលនិវត្តន៍លាឈប់ ឬបញ្ចប់កិច្ចសន្យាការងារ។

នៅពេលចូលនិវត្តន៍ ឬលាឈប់ការចូលរួមចំណែករបស់បុគ្គលិក និងការប្រាក់ត្រូវបើកឲ្យទាំងអស់លើកលែងការចូលរួមចំណែករបស់ធនាគារ និងការប្រាក់ពាក់ព័ន្ធត្រូវបើកអនុលោមតាមលក្ខខណ្ឌដូចខាងក្រោម៖

| ចំនួនឆ្នាំដែលបានបំពេញសេវាកម្ម | ភាគរយនៃការចូលរួមពីធនាគារ |
|---|---|
| ស្មើនឹង ឬតិចជាង 1ឆ្នាំ | - |
| យ៉ាងតិច 1ឆ្នាំ | 20% |
| យ៉ាងតិច 2ឆ្នាំ | 40% |
| យ៉ាងតិច 3ឆ្នាំ | 60% |
| យ៉ាងតិច 4ឆ្នាំ | 80% |
| យ៉ាងតិច 5ឆ្នាំ | 100% |

បុគ្គលិក ដែលបានបញ្ឈប់ដោយកំហុសវិជ្ជាជីវៈធ្ងន់ធ្ងរ អាចទទួលបានតែការចូលរួមចំណែករបស់ខ្លួន និងការប្រាក់តែប៉ុណ្ណោះ ទោះបីជាបានបំពេញការងារជាមួយធនាគាររយៈពេលយូរប៉ុនណាក៏ដោយ។

មូលនិធិសោធននិវត្តន៍ត្រូវបានបង្ហាញក្នុងតម្លៃថ្លៃដើម។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ២. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ២.១៩. ការទទួលស្គាល់ប្រាក់ចំណូល

ចំណូលការប្រាក់ពីឥណទានដំណើរការត្រូវបានទទួលស្គាល់ ដោយផ្អែកលើមូលដ្ឋានបង្គរជារៀងរាល់ថ្ងៃ។ នៅពេលដែលគណនីត្រូវបានចាត់ថ្នាក់ជាឥណទានមិនដំណើរការនោះ ការប្រាក់នឹងត្រូវបានកត់ត្រាជាការប្រាក់ជាប់សង្ស័យ លុះត្រាតែទទួលបានជាសាច់ប្រាក់សុទ្ធ។ ចំណូលពីសកម្មភាពផ្សេងៗ របស់ធនាគារត្រូវបានបង្គរ ដោយប្រើប្រាស់មូលដ្ឋានដូចខាងក្រោម៖

- កម្រៃលើការចាត់ចែងផ្តល់ឥណទាន និងកម្រៃជើងសារលើសេវាកម្ម និងឥណទានដែលបានផ្តល់ទៅឲ្យអតិថិជនត្រូវបានទទួលស្គាល់ក្នុងអំឡុងពេលបំពេញសេវាកម្ម និងឥណទាន។
- កម្រៃលើកិច្ចសន្យា និងកម្រៃការធានាលើសេវាកម្មផ្សេងៗ និងឧបករណ៍ហិរញ្ញវត្ថុនានា ដែលផ្តល់ឲ្យអតិថិជនត្រូវបានទទួលស្គាល់ជាចំណូលនៅពេលប្រតិបត្តិការកើតឡើង។
- កម្រៃសេវាកម្ម និងកម្រៃរត់ការត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានបំពេញ។

### ២.២០. ចំណាយការប្រាក់

ចំណាយលើការប្រាក់ទៅលើប្រាក់បញ្ញើ ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ។

### ២.២១. ភតិសន្យាប្រតិបត្តិការ

ថ្លៃឈ្នួលដែលត្រូវទូទាត់លើភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្ររំលស់ថេរទៅតាមថេរវេលានៃភតិសន្យា។ ការសន្យាភតិសន្យា មិនត្រូវបានទទួលស្គាល់ជាបំណុលទេរហូតដល់ពេល ដែលធនាគារមានកាតព្វកិច្ចត្រូវទូទាត់។

### ២.២២. ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ ឬខាតក្នុងការិយបរិច្ឆេទរួមមាន ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែក្នុងករណីដែលទាក់ទងទៅនឹងសមាសធាតុ ដែលត្រូវទទួលស្គាល់ជាផ្នែកមួយនៃមូលធនភាគទុនិកក្នុងករណីនេះ វាក៏ត្រូវបានកំណត់បង្ហាញជាផ្នែកមួយនៃមូលធនភាគទុនិកផងដែរ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងទុកថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធក្នុងការិយបរិច្ឆេទ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅនាកាលបរិច្ឆេទរាយការណ៍ជាមួយនឹងនិយ័តកម្មណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

ពន្ធពន្យារ ត្រូវបានកត់ត្រាតាមវិធីសាស្ត្រតារាងតុល្យការទៅលើភាពលំអៀងជាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងប្រើសម្រាប់ការគិតពន្ធ។ តម្លៃនៃប្រាក់ពន្ធពន្យារ ដែលបានកំណត់នោះគឺផ្អែកលើលក្ខណៈនៃការជឿជាក់នឹងទទួលបាន ឬការទូទាត់ដែលនឹងកើតឡើងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលដោយប្រើអត្រាពន្ធកំណត់នៅនាកាលបរិច្ឆេទរាយការណ៍។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់ ដើម្បីអាចប្រើប្រាស់តែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលអាចប្រើប្រាស់ជាមួយនឹងទ្រព្យសកម្មបាន។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានកាត់បន្ថយក្នុងករណី ដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍នៃពន្ធ ដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន។

### ២.២៣. សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិរបស់ធនាគារ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើភាគីមួយទៀត ឬមានឥទ្ធិពលយ៉ាងខ្លាំងទៅលើភាគីនេះក្នុងការធ្វើសេចក្តីសម្រេចលើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬដូចគ្នានេះដែរប្រសិនបើធនាគារ និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលរួម។ សម្ព័ន្ធញាតិអាចជា រូបវន្តបុគ្គល ឬនីតិបុគ្គល និងរួមបញ្ចូលនូវរូបវន្តបុគ្គលណាម្នាក់នៃសមាជិកគ្រួសារ ដែលជិតស្និទ្ធក៏ត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិដែរ។

នៅក្រោមច្បាប់ស្តីពីធនាគារធនាគារ និងហិរញ្ញវត្ថុនិយមន័យរបស់សម្ព័ន្ធញាតិ គឺជាភាគីដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលយ៉ាងតិច 10% នៃដើមទុន ឬសិទ្ធិបោះឆ្នោត ព្រមទាំងរូបវន្តបុគ្គលណាម្នាក់ ដែលរួមចំណែកក្នុងការអភិបាល ការដឹកនាំ ការគ្រប់គ្រង ឬការបង្កើត និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

## ៣. ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលត្រូវបានធ្វើឡើង ដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើអត្រាប្តូរប្រាក់ជាផ្លូវការ ប្រកាសដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018 ដែល 1 ដុល្លារអាមេរិក ស្មើនឹង 4,018 រៀល (2017: 1 ដុល្លារអាមេរិក ស្មើនឹង 4,037 រៀល)។ តួលេខជាប្រាក់រៀលនេះ គឺមិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## ៤. សាច់ប្រាក់ក្នុងដៃ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| សាខា | 67,916,377 | 272,888,003 | 43,744,709 | 176,597,390 |
| ការិយាល័យកណ្តាល | 7 | 28 | - | - |
| | **67,916,384** | **272,888,031** | **43,744,709** | **176,597,390** |

សាច់ប្រាក់ក្នុងដៃតាមរូបិយប័ណ្ណមានដូចខាងក្រោម៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ប្រាក់ដុល្លារអាមេរិក | 46,519,200 | 186,914,146 | 29,261,852 | 118,130,096 |
| ប្រាក់ខ្មែររៀល | 20,080,024 | 80,681,536 | 13,650,000 | 55,105,050 |
| ប្រាក់ថៃបាត | 1,250,892 | 5,026,084 | 757,241 | 3,056,982 |
| ប្រាក់អឺរ៉ូ | 49,105 | 197,304 | 8,124 | 32,797 |
| ប្រាក់ដោន | 7,395 | 29,713 | 5,782 | 23,342 |
| ប្រាក់ដុល្លារអូស្ត្រាលី | 7,048 | 28,319 | 5,919 | 23,895 |
| ប្រាក់យ៉េនជប៉ុន | 1,785 | 7,172 | 55,300 | 223,246 |
| ប្រាក់យ័នចិន | 825 | 3,315 | 491 | 1,982 |
| ប្រាក់ដុល្លារសិង្ហបុរី | 110 | 442 | - | - |
| | **67,916,384** | **272,888,031** | **43,744,709** | **176,597,390** |

សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់សាច់ប្រាក់ក្នុងដៃនិងសាច់ប្រាក់សមមូលមានដូចខាងក្រោម៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| សាច់ប្រាក់ក្នុងដៃ | 67,916,384 | 272,888,031 | 43,744,709 | 176,597,390 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 20,875,343 | 83,877,128 | 15,762,395 | 63,632,789 |
| សមតុល្យនៅធនាគារនានា | 7,871,412 | 31,627,333 | 19,095,480 | 77,088,453 |
| | **96,663,139** | **388,392,492** | **78,602,584** | **317,318,632** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ( ត )

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ៥. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) |
| គណនីចរន្ត | 20,875,342 | 83,877,124 | 15,762,393 | 63,632,781 |
| ប្រាក់បញ្ញើរយៈពេលខ្លី | 17,010,000 | 68,346,180 | 3,839,485 | 15,500,001 |
| ប្រាក់តម្កល់ធានាលើដើមទុន | 12,000,000 | 48,216,000 | 12,000,000 | 48,444,000 |
| ប្រាក់បម្រុងកាតព្វកិច្ច | 119,084,674 | 478,482,220 | 92,938,861 | 375,194,181 |
| | **168,970,016** | **678,921,524** | **124,540,739** | **502,770,963** |

ប្រាក់បញ្ញើរយៈពេលខ្លី មានកាលកំណត់ 6ខែ និង 12ខែ មានអត្រាការប្រាក់ពី 0.90% ទៅ 0.95% និងពី 1.11% ទៅ 1.25% ក្នុងមួយឆ្នាំ (2017 : 1.68% ក្នុងមួយឆ្នាំ )។

***ប្រាក់តម្កល់ធានាលើដើមទុន***

យោងតាមប្រកាសលេខ ធ7-01-136 ប្រ.ក ចុះថ្ងៃទី15 ខែតុលា ឆ្នាំ2001 ធនាគារតម្រូវឲ្យតម្កល់ប្រាក់បញ្ញើបម្រុងកាតព្វកិច្ចចំនួន 10% នៃដើមទុនចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់ធានានេះមិនសម្រាប់ប្រើក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ហើយនឹងត្រូវបង្វិលជូនធនាគារវិញ នៅពេលធនាគារស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ធនាគារទទួលបានការប្រាក់ប្រចាំឆ្នាំក្នុងអត្រា 0.62% (2017 : 0.36%)។

***ប្រាក់បម្រុងកាតព្វកិច្ច***

តាមប្រកាសលេខ ធ7-012-140 ប្រ.ក របស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2012 ធនាគារតម្រូវឲ្យតម្កល់ប្រាក់បញ្ញើបម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជា តាមអត្រាការប្រាក់ 8% និង 12.5% នៃប្រាក់បញ្ញើរបស់អតិថិជនជាប្រាក់រៀល និងប្រាក់បញ្ញើរបស់អតិថិជនជារូបិយប័ណ្ណក្រៅពីប្រាក់រៀល។ 4.5% នៃប្រាក់បញ្ញើបម្រុងកាតព្វកិច្ចនេះ ចំពោះរូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀលទទួលបានការប្រាក់ 1/2 នៃអត្រា Libor ក្នុងមួយខែ ហើយប្រាក់បញ្ញើបម្រុងកាតព្វកិច្ច 8% ផ្សេងទៀត និងប្រាក់បញ្ញើបម្រុងកាតព្វកិច្ចជាប្រាក់រៀលពុំមានការប្រាក់ទេ។

ធនាគារជាតិនៃកម្ពុជាចេញប្រកាសលេខ ធ7-018-282 ចុះថ្ងៃទី29 ខែសីហា ឆ្នាំ2018 ជំនួសឲ្យប្រកាសខាងលើដែលផ្តល់ការប្រាក់ 1/2 នៃអត្រា Libor ក្នុងមួយខែនៃប្រាក់បញ្ញើបម្រុងកាតព្វកិច្ច។

## ៦. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) |
| គណនីសន្សំ | 57,259 | 230,066 | 199,131 | 803,892 |
| គណនីចរន្ត | 7,814,153 | 31,397,267 | 8,896,349 | 35,914,561 |
| ប្រាក់បញ្ញើរយៈពេលខ្លី | - | - | 10,000,000 | 40,370,000 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានាដុល | 7,871,412 | 31,627,333 | 19,095,480 | 77,088,453 |
| សំវិធានធនលើប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | (78,434) | (315,147) | - | - |
| | **7,792,978** | **31,312,186** | **19,095,480** | **77,088,453** |

គណនីសន្សំទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំពី 1.5% (2017: 0.5% ទៅ 1.50% ក្នុងមួយឆ្នាំ ) ចំណែកឯគណនីចរន្តមិនទទួលបានអត្រាការប្រាក់។ ក្នុងឆ្នាំ2017 ប្រាក់បញ្ញើរយៈពេលខ្លី ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំពីអត្រា 3.0% ទៅ 5.0%។

## ៧. ឥណទាន ផ្តល់ឲ្យអតិថិជន

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ឥណទានឯកជន | 1,025,992,973 | 4,122,439,766 | 808,940,050 | 3,265,690,982 |
| ឥណទានជាក្រុម | 16,097 | 64,678 | 18,743 | 75,665 |
| **ឥណទាន ផ្តល់ឲ្យអតិថិជនដុល** | **1,026,009,070** | **4,122,504,444** | **808,958,793** | **3,265,766,647** |
| សំវិធានធនលើឥណទានអាក្រក់ | | | | |
| ជាក់លាក់ | (8,788,273) | (35,311,282) | (6,910,403) | (27,897,296) |
| ទូទៅ | (10,081,288) | (40,506,615) | (7,922,399) | (31,982,725) |
| | **(18,869,561)** | **(75,817,897)** | **(14,832,802)** | **(59,880,021)** |
| **ឥណទានផ្តល់ឲ្យអតិថិជនសុទ្ធ** | **1,007,139,509** | **4,046,686,547** | **794,125,991** | **3,205,886,626** |

បម្រែបម្រួលសំវិធានធនលើឥណទានផ្តល់ឲ្យអតិថិជនអាក្រក់ និងជាប់សង្ស័យមានដូចខាងក្រោម៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| នាថ្ងៃទី1 ខែមករា | 14,832,802 | 59,598,198 | 11,234,730 | 45,354,605 |
| សំវិធានធនបន្ថែមក្នុងការិយបរិច្ឆេទ | 7,149,332 | 28,726,016 | 4,871,366 | 19,665,705 |
| ឥណទានជម្រះបញ្ជី | (3,117,475) | (12,526,015) | (1,273,294) | (5,140,289) |
| ការវាយតម្លៃឡើងវិញនូវរូបិយប័ណ្ណ | 4,902 | 19,698 | - | - |
| **នាថ្ងៃទី31 ខែធ្នូ** | **18,869,561** | **75,817,897** | **14,832,802** | **59,880,021** |

ការវិភាគបន្ថែមទៅលើឥណទាន ផ្តល់ឲ្យអតិថិជនមានដូចខាងក្រោម៖

*(ក) ប្រភេទឥណទាន:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **ឥណទាន ពាណិជ្ជកម្ម** | | | | |
| ឥណទានរយៈពេលខ្លី | 11,954,919 | 48,034,865 | 8,804,917 | 35,545,450 |
| ឥណទានវិបារូបណ៍ | 3,542,553 | 14,233,979 | 1,789,228 | 7,223,113 |
| ឥណទានរយៈពេលវែង | 624,694,240 | 2,510,021,454 | 534,481,308 | 2,157,701,040 |
| **ឥណទាន អ្នកប្រើប្រាស់** | | | | |
| ឥណទានឯកបុគ្គល | 345,386,591 | 1,387,763,321 | 233,770,384 | 943,731,040 |
| ឥណទានគេហដ្ឋាន | 17,976,177 | 72,228,281 | 9,596,119 | 38,739,532 |
| ឥណទានបុគ្គលិក | 22,454,590 | 90,222,543 | 20,516,837 | 82,826,472 |
| **ឥណទានសរុបដុល** | **1,026,009,070** | **4,122,504,443** | **808,958,793** | **3,265,766,647** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ៧ ឥណទាន ផ្តល់ឲ្យអតិថិជន (ត)

*(ខ) ចំណាត់ថ្នាក់ឥណទាន:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **ឥណទានរយៈពេលខ្លី** | | | | |
| ឥណទានស្តង់ដារ | | | | |
| មានវត្ថុបញ្ចាំ | 13,511,454 | 54,289,022 | 9,360,093 | 37,786,695 |
| គ្មានវត្ថុបញ្ចាំ | 3,920,050 | 15,750,761 | 3,334,257 | 13,460,396 |
| ឥណទានឃ្លាំមើល | | | | |
| មានវត្ថុបញ្ចាំ | 2,031 | 8,161 | 161 | 650 |
| ឥណទានក្រោមស្តង់ដារ | | | | |
| មានវត្ថុបញ្ចាំ | - | - | 989 | 3,993 |
| ឥណទានជាប់សង្ស័យ | | | | |
| មានវត្ថុបញ្ចាំ | 332 | 1,334 | 98 | 396 |
| ឥណទានបាត់បង់ | | | | |
| មានវត្ថុបញ្ចាំ | 20,136 | 80,905 | 34,194 | 138,041 |
| **សរុបរង** | **17,454,003** | **70,130,183** | **12,729,792** | **51,390,171** |
| **ឥណទានរយៈពេលវែង** | | | | |
| ឥណទាន ស្តង់ដារមានវត្ថុបញ្ចាំ | 965,763,220 | 3,880,436,618 | 761,078,903 | 3,072,475,531 |
| គ្មានវត្ថុបញ្ចាំ | 24,934,051 | 100,185,017 | 18,466,719 | 74,550,145 |
| ឥណទានឃ្លាំមើលមានវត្ថុបញ្ចាំ | 1,273,112 | 5,115,364 | 5,926,675 | 23,925,987 |
| គ្មានវត្ថុបញ្ចាំ | 2,096 | 8,422 | - | - |
| ឥណទានក្រោមស្តង់ដារមានវត្ថុបញ្ចាំ | 5,643,769 | 22,676,664 | 1,944,385 | 7,849,482 |
| ឥណទានជាប់សង្ស័យមានវត្ថុបញ្ចាំ | 6,675,734 | 26,823,099 | 5,006,079 | 20,209,540 |
| គ្មានវត្ថុបញ្ចាំ | 103 | 414 | - | - |
| ឥណទានបាត់បង់មានវត្ថុបញ្ចាំ | 4,262,982 | 17,128,662 | 3,806,240 | 15,365,791 |
| **សរុបរង** | **1,008,555,067** | **4,052,374,260** | **796,229,001** | **3,214,376,476** |
| **សរុបដុល** | **1,026,009,070** | **4,122,504,443** | **808,958,793** | **3,265,766,647** |

*(គ) សម្រាប់ការវិភាគលើឥណទានតាមកាលវសាន្ត សូមមើលកំណត់សំគាល់ 27 (iv) ស្តីពីហានិភ័យសាច់ប្រាក់ងាយស្រួល។*

*(ឃ) តាមនិវាសនដ្ឋានៈ*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **និវាសនជន** | **1,026,009,070** | **4,122,504,443** | **808,958,793** | **3,265,766,647** |
| *(ង) តាមទំនាក់ទំនងៈ* | | | | |
| ឥណទានបុគ្គលិក | 652,377 | 2,621,252 | 702,362 | 2,835,435 |
| មិនមែនសម្ព័ន្ធញាតិ | 1,025,356,693 | 4,119,883,191 | 808,256,431 | 3,262,931,212 |
| | **1,026,009,070** | **4,122,504,443** | **808,958,793** | **3,265,766,647** |
| *(ច) តាមរូបិយប័ណ្ណៈ* | | | | |
| ប្រាក់ដុល្លារអាមេរិក | 939,301,141 | 3,774,111,981 | 753,605,245 | 3,042,304,374 |
| ខ្មែររៀល | 78,942,127 | 317,189,468 | 48,576,279 | 196,102,438 |
| ថៃបាត | 7,765,802 | 31,202,994 | 6,777,269 | 27,359,835 |
| | **1,026,009,070** | **4,122,504,443** | **808,958,793** | **3,265,766,647** |

*(ឆ) តាមប្រភេទអាជីវកម្ម*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| លក្ខណៈគ្រួសារ | 319,052,775 | 1,281,954,051 | 205,943,616 | 831,394,378 |
| ពាណិជ្ជកម្ម | 298,037,921 | 1,197,516,367 | 241,772,177 | 976,034,279 |
| កសិកម្ម | 185,593,418 | 745,714,355 | 166,483,930 | 672,095,625 |
| សេវាកម្ម | 55,352,624 | 222,406,842 | 45,299,738 | 182,875,042 |
| សំណង់ | 39,471,096 | 158,594,863 | 49,332,396 | 199,154,883 |
| ផ្សេងៗ | 128,501,236 | 516,317,965 | 100,126,936 | 404,212,440 |
| | **1,026,009,070** | **4,122,504,443** | **808,958,793** | **3,265,766,647** |

*អត្រាការប្រាក់ប្រចាំឆ្នាំ មានដូចតទៅៈ*

| | 2018 | 2017 |
|---|---|---|
| អតិថិជនខាងក្រៅ | 8.0% to 36.0% | 8.0% to 36% |
| បុគ្គលិក | 6.50% | 6.50% |

## ៨. ទ្រព្យសកម្មផ្សេងៗ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ប្រាក់បុរេប្រទាន | 10,329,304 | 41,503,143 | 9,431,818 | 38,076,249 |
| ការប្រាក់ត្រូវទទួល | 8,442,684 | 33,922,705 | 7,416,578 | 29,940,726 |
| | **18,771,988** | **75,425,848** | **16,848,396** | **68,016,975** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ( ត )

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018**

## ៩. តម្លៃកេរ្តិ៍ឈ្មោះ

តម្លៃកេរ្តិ៍ឈ្មោះកើតចេញពីការរួមបញ្ចូលគ្នាតាមផ្លូវច្បាប់រវាង MJB និង ស្ថាបនាលីមីតធីត នៅថ្ងៃទី1 ខែមេសា ឆ្នាំ2016 ដែលដំបូងតម្លៃកេរ្តិ៍ឈ្មោះកើតចេញទិញភាគហ៊ុននៃស្ថាបនា លីមីតធីតនៅថ្ងៃទី17 ខែធ្នូ ឆ្នាំ2012។

## ១០. ទ្រព្យ និងបរិក្ខារ

| 2018 | សង្ហារឹម និងបរិក្ខារការិយាល័យ | កុំព្យូទ័រ | យានយន្ត | ការកែលើទ្រព្យជួល | ទ្រព្យ និងបរិក្ខារកំពុងសាងសង់ | | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់3 ) |
| **តម្លៃដើម** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2018 | 4,884,048 | 6,958,823 | 7,563,150 | 1,485,201 | 727,136 | 21,618,358 | 86,862,562 |
| ការទិញបន្ថែម | 726,969 | 3,151,657 | 171,000 | 145,170 | 1,019,278 | 5,214,074 | 20,950,149 |
| ការផ្ទេរ | 15,593 | 611,774 | - | - | (670,112) | (42,745) | (171,749) |
| ការលក់ចេញ | (29,800) | - | (56,100) | (12,760) | - | (98,660) | (396,416) |
| ការជម្រះបញ្ជី | (153,152) | (211,326) | - | (20,582) | - | (385,060) | (1,547,171) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | **5,443,658** | **10,510,928** | **7,678,050** | **1,597,029** | **1,076,302** | **26,305,967** | **105,697,375** |
| **ដកៈរំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2018 | 3,007,399 | 5,469,705 | 4,510,135 | 613,405 | - | 13,600,644 | 54,647,388 |
| រំលស់ក្នុងឆ្នាំ | 1,073,098 | 738,163 | 767,543 | 319,270 | - | 2,898,074 | 11,644,461 |
| ការលក់ចេញ | (16,879) | - | (42,390) | (10,038) | - | (69,307) | (278,476) |
| ការជម្រះបញ្ជី | (136,285) | (206,352) | - | (19,457) | - | (362,093) | (1,454,890) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | **3,927,333** | **6,001,516** | **5,235,288** | **903,180** | **-** | **16,067,318** | **64,558,483** |
| តម្លៃយោង | | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | **1,516,325** | **4,509,412** | **2,442,762** | **693,849** | **1,076,302** | **10,238,649** | **41,138,892** |

| 2017 | សង្ហារឹម និងបរិក្ខារ ការិយាល័យ | កុំព្យូទ័រ | យានយន្ត | ការកែលើ ទ្រព្យជួល | ទ្រព្យ និងបរិក្ខារ កំពុងសាងសង់ | សរុប | |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់3) |
| **តម្លៃដើម** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2017 | 4,073,149 | 6,653,871 | 6,646,044 | 1,157,108 | 194,062 | 18,724,234 | 75,589,733 |
| ការទិញបន្ថែម | 668,780 | 897,298 | 967,050 | 387,679 | 727,136 | 3,647,943 | 14,726,746 |
| ការផ្ទេរ | 23,144 | 35,988 | - | 125,000 | (194,062) | (9,930) | (40,087) |
| ការលក់ចេញ | (1,250) | - | - | - | - | (1,250) | (5,046) |
| ការជម្រះបញ្ជី | (240,918) | (292,139) | (49,944) | (159,811) | - | (742,812) | (2,998,732) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | **4,522,905** | **7,295,018** | **7,563,150** | **1,509,976** | **727,136** | **21,618,185** | **87,272,614** |
| **ដក: រំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2017 | 2,360,713 | 4,882,369 | 3,668,106 | 604,308 | - | 11,515,496 | 46,488,057 |
| រំលស់ក្នុងឆ្នាំ | 514,707 | 1,180,954 | 888,692 | 180,747 | - | 2,765,100 | 11,162,709 |
| ការលក់ចេញ | (1,066) | - | - | - | - | (1,066) | (4,303) |
| ការជម្រះបញ្ជី | (189,420) | (283,828) | (49,944) | (154,937) | - | (678,129) | (2,737,606) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | **2,684,934** | **5,779,495** | **4,506,854** | **630,118** | **-** | **13,601,401** | **54,908,857** |
| **តម្លៃយោងសុទ្ធ** | | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | **1,837,971** | **1,515,523** | **3,056,296** | **879,858** | **727,136** | **8,016,784** | **32,363,757** |

## ១១. ទ្រព្យសកម្មអរូបី

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **តម្លៃដើម** | | | | |
| នាថ្ងៃទី1 ខែមករា | 4,946,405 | 19,874,655 | 4,685,569 | 18,915,642 |
| ការទិញបន្ថែម | 624,028 | 2,507,345 | 262,001 | 1,057,698 |
| ការផ្ទេរ | 42,746 | 171,753 | 9,930 | 40,087 |
| ការជម្រះបញ្ជី | (199) | (799) | (10,922) | (44,092) |
| **ថ្ងៃទី31 ខែធ្នូ** | **5,612,980** | **22,552,954** | **4,946,578** | **19,969,335** |
| **ដក រំលស់បង្គរ** | | | | |
| នាថ្ងៃទី1 ខែមករា | 4,004,088 | 16,088,426 | 3,218,708 | 12,993,924 |
| រំលស់ក្នុងឆ្នាំ | 145,385 | 584,157 | 795,546 | 3,211,619 |
| ការជម្រះបញ្ជី | (179) | (720) | (10,922) | (44,092) |
| **ថ្ងៃទី31 ខែធ្នូ** | **4,149,294** | **16,671,864** | **4,003,332** | **16,161,451** |
| **តម្លៃយោងសុទ្ធ** | | | | |
| **ថ្ងៃទី31 ខែធ្នូ** | **1,463,686** | **5,881,090** | **943,246** | **3,807,884** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ១២. ការវិនិយោគផ្សេងៗ

ការវិនិយោគផ្សេងៗរួមមាន មូលនិធិភាគហ៊ុន ដែលវិនិយោគនៅក្នុងសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) ទឹកប្រាក់ 25,000 ដុល្លារអាមេរិក និងមូលនិធិភាគហ៊ុន ដែលវិនិយោគនៅក្នុងសមាគមន៍ធនាគារនៅកម្ពុជាទឹកប្រាក់ 25,000 ដុល្លារអាមេរិក។ តម្លៃទីផ្សារនៃការវិនិយោគនេះ មិនអាចកំណត់បាន ដោយសារមិនអាចកំណត់លំហូរសាច់ប្រាក់នាពេលអនាគត និងខ្វះខាតវិធីសាស្ត្រសមស្រប ដើម្បីវាយតម្លៃរកតម្លៃទីផ្សារ ដែលអាចទុកចិត្តបាន។ ការវិនិយោគនេះត្រូវទទួលស្គាល់ និងកត់ត្រាតាមថ្លៃដើម។

## ១៣. ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារហិរញ្ញវត្ថុផ្សេងៗ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ប្រាក់បញ្ញើសន្សំ | 137,000,496 | 550,467,993 | 119,404,226 | 482,034,860 |
| ប្រាក់បញ្ញើតាមតម្រូវការ | 28,780,837 | 115,641,403 | 16,829,167 | 67,939,347 |
| ប្រាក់បញ្ញើមានកាលកំណត់ | 638,918,048 | 2,567,172,717 | 481,938,859 | 1,945,587,174 |
| | **804,699,381** | **3,233,282,113** | **618,172,252** | **2,495,561,381** |

ប្រាក់បញ្ញើរបស់អតិថិជនខាងលើនេះ ត្រូវបានវិភាគដូចខាងក្រោម៖

*(ក) តាមប្រភេទអតិថិជន:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **គណនីបញ្ញើតាមតម្រូវការ** | | | | |
| ឯកត្តជន | 2,183,804 | 8,774,524 | 2,902,268 | 11,716,456 |
| សហគ្រាស | 16,865,116 | 67,764,036 | 7,262,176 | 29,317,405 |
| ធនាគារហិរញ្ញវត្ថុនានា | 9,731,917 | 39,102,843 | 6,664,722 | 26,905,483 |
| **គណនីសន្សំ** | | | | |
| ឯកត្តជន | 92,005,780 | 369,679,224 | 74,357,580 | 300,181,550 |
| សហគ្រាស | 36,574,150 | 146,954,935 | 44,899,350 | 181,258,676 |
| ធនាគារហិរញ្ញវត្ថុនានា | 8,420,566 | 33,833,834 | 147,297 | 594,638 |
| **គណនីមានកាលកំណត់** | | | | |
| ឯកត្តជន | 539,075,804 | 2,166,006,580 | 422,055,294 | 1,703,837,222 |
| សហគ្រាស | 77,558,820 | 311,631,339 | 35,845,480 | 144,708,203 |
| ធនាគារហិរញ្ញវត្ថុនានា | 22,283,424 | 89,534,798 | 24,038,085 | 97,041,748 |
| | **804,699,381** | **3,233,282,113** | **618,172,252** | **2,495,561,381** |

*(ខ) តាមនិវាសនដ្ឋាន:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| និវាសនជន | 729,527,349 | 2,931,240,888 | 540,913,759 | 2,183,668,845 |
| អនិវាសនជន | 75,172,032 | 302,041,225 | 77,258,493 | 311,892,536 |
| | **804,699,381** | **3,233,282,113** | **618,172,252** | **2,495,561,381** |

*(គ) តាមរូបិយប័ណ្ណ:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ប្រាក់ដុល្លារអាមេរិក | 673,903,862 | 2,707,745,718 | 513,384,706 | 2,072,534,058 |
| ប្រាក់រៀល | 98,551,792 | 395,981,100 | 72,459,416 | 292,518,662 |
| ប្រាក់បាតថៃ | 2,823,745 | 11,345,807 | 3,696,288 | 14,921,915 |
| ប្រាក់យ៉េនជប៉ុន | 29,419,512 | 118,207,599 | 28,631,351 | 115,584,764 |
| ផ្សេងៗ | 470 | 1,889 | 491 | 1,982 |
| | **804,699,381** | **3,233,282,113** | **618,172,252** | **2,495,561,381** |

*(ឃ) តាមទំនាក់ទំនង:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| សម្ព័ន្ធញាតិ | 387,213 | 1,555,822 | 446,221 | 1,801,394 |
| មិនមែនសម្ព័ន្ធញាតិ | 804,312,168 | 3,231,726,291 | 617,726,031 | 2,493,759,987 |
| | **804,699,381** | **3,233,282,113** | **618,172,252** | **2,495,561,381** |

*(ង) តាមកាលកំណត់:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| រយៈពេល 1ខែ | 184,023,331 | 739,405,745 | 149,854,939 | 604,964,389 |
| ចន្លោះពី 1ខែ ទៅ 3ខែ | 14,912,953 | 59,920,245 | 25,063,012 | 101,179,379 |
| លើសពី 3ខែ | 605,763,097 | 2,433,956,123 | 443,254,301 | 1,789,417,613 |
| | **804,699,381** | **3,233,282,113** | **618,172,252** | **2,495,561,381** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2018

## ១៣. ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារហិរញ្ញវត្ថុផ្សេងៗ (ត)

*(ច) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ):*

| | 2018 | 2017 |
|---|---|---|
| ធនាគារ និងធនាគារមីក្រូហិរញ្ញវត្ថុ | | |
| ប្រាក់បញ្ញើមានកាលកំណត់ | 1.25% - 3.25% | 1.00% to 3.50% |
| ឯកត្តជន | | |
| ប្រាក់បញ្ញើសន្សំ | 1.00% - 1.50% | 1.50% to 2.00% |
| ប្រាក់បញ្ញើមានកាលកំណត់ | 3.00% - 8.00% | 3.50% to 8.00% |
| សហគ្រាស | | |
| ប្រាក់បញ្ញើសន្សំ | 1.00% - 1.50% | 1.00% |
| ប្រាក់បញ្ញើមានកាលកំណត់ | 3.00% - 8.00% | 3.00% to 8.00% |

## ១៤. ប្រាក់កម្ចី

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| សម្ព័ន្ធញាតិ: | | | | |
| Maruhan Investment Asia (“MIA”) | 14,990,000 | 60,229,820 | 18,330,000 | 73,998,210 |
| មិនមែនសម្ព័ន្ធញាតិ: | | | | |
| Nederlandse Financierings – Maatschappij voor Ontwik-kelingslanden N.V (‘FMO”) | 11,250,000 | 45,202,500 | 22,500,000 | 90,832,500 |
| Symbiotics | 4,500,000 | 18,081,000 | 8,500,000 | 34,314,500 |
| DEG | 5,000,000 | 20,090,000 | 7,500,000 | 30,277,500 |
| Micro-Finance Enhancement | 5,500,000 | 22,099,000 | 13,500,000 | 54,499,500 |
| ResponsAbility SICAV | 1,500,000 | 6,027,000 | 3,000,000 | 12,111,000 |
| ICBC | 37,000,000 | 148,666,000 | 37,000,000 | 149,369,000 |
| Norfund | 10,000,000 | 40,180,000 | 10,000,000 | 40,370,000 |
| Triodos – Doen | - | - | 5,250,000 | 21,194,250 |
| Cathay United Bank (Cambodia) Corporation Limited | 625,000 | 2,511,250 | 875,000 | 3,532,375 |
| First Commercial Bank | 11,666,667 | 46,876,668 | 23,333,333 | 94,196,665 |
| DWM Funds S.C.A | 15,000,000 | 60,270,000 | 15,000,000 | 60,555,000 |
| MIZUHO Bank Ltd | 95,835,000 | 385,065,030 | 50,000,000 | 201,850,000 |
| Aozora Bank Ltd | 30,000,000 | 120,540,000 | - | - |
| NBC (LPCO) | 10,950,722 | 44,000,001 | - | - |
| | **253,817,389** | **1,019,838,269** | **214,788,333** | **867,100,500** |

ប្រាក់កម្ចីមិនមានវត្ថុធានា។

ប្រាក់កម្ចីខាងលើនេះ ត្រូវបានវិភាគដូចខាងក្រោម៖

*(ក) តាមរូបិយប័ណ្ណ:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ប្រាក់ដុល្លារអាមេរិក | 242,866,667 | 975,838,268 | 214,788,333 | 867,100,500 |
| ប្រាក់រៀល | 10,950,722 | 44,000,001 | - | - |
| | **253,817,389** | **1,019,838,269** | **214,788,333** | **867,100,500** |

*(ខ) តាមកាលកំណត់:*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| រយៈពេល 1ខែ | 3,611,561 | 14,511,252 | - | - |
| ចន្លោះពី 1ខែ ទៅ 3ខែ | 8,000,000 | 32,144,000 | 3,000,000 | 12,111,000 |
| ចន្លោះពី 3ខែ ទៅ 12ខែ | 51,880,828 | 208,457,167 | 24,250,000 | 97,897,250 |
| លើសពី 1ឆ្នាំ ដល់ 5ឆ្នាំ | 190,325,000 | 764,725,850 | 187,538,333 | 757,092,250 |
| | **253,817,389** | **1,019,838,269** | **214,788,333** | **867,100,500** |

*តាមអត្រាការប្រាក់ប្រចាំឆ្នាំ:*

| | 2018 | 2017 |
|---|---|---|
| ប្រាក់ដុល្លារអាមេរិក | 2.6% - 10.65% | 3.44% - 10.65% |
| ប្រាក់រៀល | 2.86% - 3.06% | - |

## ១៥. បំណុលបន្ទាប់បន្សំ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| DEG - Deutsche Investitions | 6,000,000 | 24,108,000 | 8,000,000 | 32,296,000 |
| Maruhan Investment Asia Pte. Ltd. | 5,000,000 | 20,090,000 | 5,000,000 | 20,185,000 |
| Maruhan Corporation | 10,000,000 | 40,180,000 | - | - |
| BlueOrchard Microfinance Ltd. | 9,000,000 | 36,162,000 | - | - |
| | **30,000,000** | **120,540,000** | **13,000,000** | **52,481,000** |

### DEG

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 ធនាគារជាតិនៃកម្ពុជាបានអនុម័តលើបំណុលបន្ទាប់បន្សំរបស់ធនាគារពី DEG ចំនួន 10,000,000 ដុល្លារអាមេរិក។ ធនាគារបានទូទាត់សងបំណុលបន្ទាប់បន្សំលើប្រាក់ដើមចំនួន 2,000,000 ដុល្លារអាមេរិក នៅថ្ងៃទី15 ខែធ្នូ ឆ្នាំ2017។ បំណុលបន្ទាប់បន្សំនេះមានកាលកំណត់រយៈពេល 7ឆ្នាំ នឹងផុតកំណត់ នៅថ្ងៃទី15 ខែធ្នូ ឆ្នាំ2021 និងមានអត្រាការប្រាក់ថេរ 10.65% ក្នុងមួយឆ្នាំ។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ( ត )

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ១៥. បំណុលបន្ទាប់បន្សំ ( ត )

### Maruhan Investment Asia Pte. Ltd

នាថ្ងៃទី10 ខែតុលា ឆ្នាំ2013 ធនាគារជាតិនៃកម្ពុជា បានអនុម័តលើបំណុលបន្ទាប់បន្សំរបស់ធនាគារពី Maruhan Investment Asia ចំនួន 5,000,000 ដុល្លារអាមេរិក។ ធនាគារបានដកប្រាក់ចំនួន 5,000,000 ដុល្លារអាមេរិក នៅថ្ងៃទី12 ខែសីហា ឆ្នាំ2013។ បំណុលបន្ទាប់បន្សំនេះ មានកាលកំណត់រយៈពេល 7ឆ្នាំ និងផុតកំណត់នៅថ្ងៃទី12 ខែសីហា ឆ្នាំ2020 និងមានអត្រាការប្រាក់ដុល 10.4651% ក្នុងមួយឆ្នាំ។

### Maruhan Corporation

នាថ្ងៃទី26 ខែធ្នូ ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានអនុម័តលើបំណុលបន្ទាប់បន្សំរបស់ធនាគារពី Maruhan Corporation ចំនួន 10,000,000 ដុល្លារអាមេរិក។ ធនាគារ បានដកប្រាក់នៅថ្ងៃទី05 ខែវិច្ឆិកា ឆ្នាំ2018 ចំនួន10,000,000ដុល្លារអាមេរិក។ បំណុលបន្ទាប់បន្សំនេះ មានកាលកំណត់រយៈពេល 7ឆ្នាំ និងផុតកំណត់នៅថ្ងៃទី5 ខែវិច្ឆិកា ឆ្នាំ2025 និងមានអត្រាការប្រាក់ដុល 10.4651% ក្នុងមួយឆ្នាំ។

### BlueOrchard Microfinance Ltd

នាថ្ងៃទី6 ខែសីហា ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានអនុម័តលើបំណុលបន្ទាប់បន្សំរបស់ធនាគារពី BlueOrchard Microfinance Ltd ចំនួន 9,000,000 ដុល្លារអាមេរិក។ ធនាគារ បានដកប្រាក់នៅថ្ងៃទី23 ខែកក្កដា ឆ្នាំ2018 ចំនួន 9,000,000 ដុល្លារអាមេរិក។ បំណុលបន្ទាប់បន្សំនេះ មានកាលកំណត់រយៈពេល 7ឆ្នាំ និងផុតកំណត់នៅថ្ងៃទី23 ខែកក្កដា ឆ្នាំ2025 និងមានអត្រាការប្រាក់ដុល 10.4651% ក្នុងមួយឆ្នាំ។

## ១៦. មូលនិធិសោធននិវត្តន៍

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) |
| នាថ្ងៃទី1 ខែ មករា | 10,378,502 | 41,700,821 | 7,645,507 | 30,864,912 |
| ការបន្ថែមក្នុងឆ្នាំ | | | | |
| ការចូលរួមរបស់និយោជក | 2,167,017 | 8,707,074 | 1,905,098 | 7,690,881 |
| ការចូលរួមរបស់និយោជិត | 1,192,322 | 4,790,750 | 1,005,252 | 4,058,203 |
| ការប្រាក់ | 640,313 | 2,572,778 | 501,524 | 2,024,652 |
| ទូទាត់ក្នុងឆ្នាំ | (1,454,278) | (5,843,289) | (678,879) | (2,740,635) |
| **នាថ្ងៃទី31 ខែធ្នូ** | **12,923,876** | **51,928,134** | **10,378,502** | **41,898,013** |

# ១៧. ពន្ធលើប្រាក់ចំណេញ

(ក) ពន្ធពន្យារ -សុទ្ធ

ពន្ធពន្យារជាទ្រព្យសកម្មបានមកពី៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| មូលនិធិសោធននិវត្តន៍របស់និយោជិក | 2,238,099 | 8,992,682 | 1,417,985 | 5,724,405 |
| សំវិធានធនលើឥណទានសង្ស័យ (*) | 2,023,921 | 8,132,115 | 1,620,041 | 6,540,106 |
| ទ្រព្យ និងបរិក្ខារ | 476,824 | 1,915,879 | (71,646) | (289,235) |
| សំវិធានធនសំរាប់ការសន្យាក្រៅតារាងតុល្យការនិង សាច់ប្រាក់នៅធនាគារនានា | 95,417 | 383,386 | - | - |
| ខាតលើអត្រាប្តូរប្រាក់មិនទាន់ទទួលស្គាល់ | 66,402 | 266,802 | 74,368 | 300,223 |
| ប្រាក់ចំណូលមិនទាន់កើតឡើង | 3,122 | 12,544 | 8,176 | 33,007 |
| | **4,903,785** | **19,703,408** | **3,048,924** | **12,308,506** |

(*) ពន្ធពន្យារជាទ្រព្យសកម្មនេះកើតឡើងពីសំវិធានធនទូទៅ និងជាក់លាក់លើឥណទានជាប់សង្ស័យរហូតដល់ឥណទានឃ្លាំមើល ដែលជាចំណាយមិនអាចកាត់កងបាន សម្រាប់ការគណនាពន្ធលើប្រាក់ចំណេញ ដោយអនុលោមតាមប្រកាសថ្មីលេខ 1535 សហវ ប្រ.ក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី23 ខែធ្នូ ឆ្នាំ2016។

ការប្រែប្រួលនៃពន្ធពន្យារជាទ្រព្យសកម្មនៅក្នុងឆ្នាំដូចខាងក្រោម៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| នាថ្ងៃទី1 ខែមករា | 3,048,924 | 12,250,577 | 2,697,590 | 10,890,171 |
| ចំណាយក្នុងរបាយការណ៍លទ្ធផល | 1,854,861 | 7,452,831 | 351,334 | 1,418,335 |
| **នាថ្ងៃទី31 ខែធ្នូ** | **4,903,785** | **19,703,408** | **3,048,924** | **12,308,506** |

(ខ) បំណុលពន្ធលើប្រាក់ចំណេញ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| នាថ្ងៃទី1 ខែមករា | 4,444,141 | 17,856,559 | 2,783,651 | 11,237,599 |
| ពន្ធលើប្រាក់ចំណេញ | 6,994,065 | 28,102,153 | 5,570,903 | 22,489,735 |
| ពន្ធលើប្រាក់ចំណេញបានបង់ | (5,732,875) | (23,034,692) | (3,910,413) | (15,786,337) |
| **នាថ្ងៃទី31 ខែធ្នូ** | **5,705,331** | **22,924,020** | **4,444,141** | **17,940,997** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ( ត )

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ១៧. ពន្ធលើប្រាក់ចំណេញ ( ត )

( គ ) ចំណាយលើពន្ធ ប្រាក់ចំណេញ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 6,994,065 | 28,102,153 | 5,570,903 | 22,489,735 |
| ពន្ធពន្យារ | (1,854,862) | (7,452,835) | (351,334) | (1,418,335) |
| | **5,139,203** | **20,649,318** | **5,219,569** | **21,071,400** |

អនុលោមទៅតាមច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ធនាគារមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ដោយគណនាតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ។

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញ ដែលគណនាតាមអត្រាពន្ធផ្លូវការ 20% ធៀបទៅនឹងពន្ធលើប្រាក់ចំណេញ ដែលបង្ហាញក្នុងរបាយការណ៍លទ្ធផល មានដូចខាងក្រោម៖

| | | 2018 | | 2017 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) |
| **ចំណេញមុនបង់ពន្ធ** | | **28,233,400** | **113,441,801** | **23,805,608** | **96,103,240** |
| ពន្ធលើប្រាក់ចំណេញតាមអត្រា | 20% | 5,646,680 | 22,688,360 | 4,761,122 | 19,220,648 |
| ចំណាយមិនអាចកាត់កងពន្ធ | (1.8%) | (507,477) | (2,039,042) | 458,447 | 1,850,752 |
| **ចំណាយពន្ធលើប្រាក់ចំណេញ** | **18.2%** | **5,139,203** | **20,649,318** | **5,219,569** | **21,071,400** |

ការគណនាចំណាយពន្ធលើប្រាក់ចំណេញ និងត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយអាជ្ញាធរពន្ធដារ។

## ១៨. បំណុលផ្សេងៗ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) |
| ការប្រាក់ត្រូវទូទាត់ | 12,325,137 | 49,522,400 | 9,159,880 | 36,978,436 |
| បុគ្គលិក និងចំណាយដែលពាក់ព័ន្ធ | 5,590,991 | 22,464,602 | 1,879,122 | 7,586,016 |
| បង្គរសម្រាប់ពន្ធផ្សេងៗ | 553,322 | 2,223,248 | 235,411 | 950,354 |
| ប្រាក់ចំណូលដែលមិនបានទទួល | 536,385 | 2,155,195 | 44,790 | 180,817 |
| សំវិធានធនលើការសន្យាផ្តល់ឥណទាន / ហិរញ្ញប្បទាននិងការធានាហិរញ្ញវត្ថុ | 398,649 | 1,601,772 | - | - |
| គណនីត្រូវទូទាត់ | 393,323 | 1,580,372 | 264,280 | 1,066,898 |
| គណនីត្រូវទូទាត់ផ្សេងៗ | 409,637 | 1,645,921 | 1,248,181 | 5,038,907 |
| | **20,207,444** | **81,193,510** | **12,831,664** | **51,801,428** |

បម្រែបម្រួលសំវិធានធនលើការសន្យាផ្តល់កម្ចី ហិរញ្ញប្បទាន និងការធានាហិរញ្ញវត្ថុ មានដូចខាងក្រោម៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| សមតុល្យនៅដើមឆ្នាំ | - | - | - | - |
| សំវិធានធនក្នុងឆ្នាំ | 398,649 | 1,601,773 | - | - |
| **សមតុល្យនៅចុងឆ្នាំ** | **398,649** | **1,601,773** | **-** | **-** |

ចំណាយសំវិធានធនសរុបសម្រាប់ការបាត់បង់ប្រាក់បញ្ញើ និងសាច់ប្រាក់នៅធនាគារនានា ឥណទាន និងបុរេប្រទាន ការសន្យាផ្តល់ឥណទាន ហិរញ្ញប្បទាន និងការធានាហិរញ្ញវត្ថុក្នុងឆ្នាំ2018 មានចំនួន 7,626,415 ដុល្លារអាមេរិក (2017: 4,871,366ដុល្លារអាមេរិក)។

## ១៩. ដើមទុន

ដើមទុនលម្អិតមានដូចតទៅ៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **MARUHAN Investment Asia Pte. Ltd.** | **120,000,000** | **482,160,000** | **120,000,000** | **484,440,000** |

ចំនួនភាគហ៊ុនរបស់ធនាគារ ដែលបានអនុញ្ញាតមានចំនួន 1,200,000 ហ៊ុន (2017: 1,200,000) ដែលមានតម្លៃ 100 ដុល្លារអាមេរិក ក្នុង 1 ហ៊ុន។ ភាគហ៊ុនទាំងអស់ដែលបានចេញផ្សាយត្រូវបានបង់។

## ២០. ចំណូលលើការប្រាក់

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ឥណទានផ្តល់អោយអតិថិជន | 130,480,716 | 524,271,517 | 114,930,660 | 463,975,074 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 467,916 | 1,880,086 | 401,237 | 1,619,795 |
| ប្រាក់បញ្ញើពីធនាគារនានា | 18,324 | 73,626 | 660,658 | 2,667,076 |
| | **130,966,956** | **526,225,229** | **115,992,555** | **468,261,945** |

## ២១. ចំណាយលើការប្រាក់

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ប្រាក់បញ្ញើពីអតិថិជន និងធនាគារហិរញ្ញវត្ថុនានា | 33,817,986 | 135,880,668 | 34,707,619 | 140,114,658 |
| ប្រាក់កម្ចី | 15,096,881 | 60,659,268 | 12,545,071 | 50,644,452 |
| បំណុលបន្ទាប់បន្សំ | 1,975,016 | 7,935,614 | 1,665,268 | 6,722,687 |
| មូលនិធិសោធននិវត្តន៍ | 726,127 | 2,917,578 | 545,283 | 2,201,307 |
| | **51,616,010** | **207,393,128** | **49,463,241** | **199,683,104** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ( ត )

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ២២. ចំណូលកម្រៃ និងជើងសារសុទ្ធ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) |
| កម្រៃដំណើរការសេវាឥណទាន | 7,970,525 | 32,025,569 | 6,652,013 | 26,854,176 |
| កម្រៃសេវាផ្ទេរប្រាក់ | 113,990 | 458,012 | 64,452 | 260,193 |
| កម្រៃ និងជើងសារផ្សេងៗ | 1,467,369 | 5,895,889 | 85,163 | 343,803 |
| | 9,551,884 | 38,379,470 | 6,801,628 | 27,458,172 |
| ចំណាយកម្រៃ និងជើងសារប្រាក់កម្ចី | (2,107,856) | (8,469,365) | (1,430,903) | (5,776,555) |
| | **7,444,028** | **29,910,105** | **5,370,725** | **21,681,617** |

## ២៣. ចំណាយប្រតិបត្តិការផ្សេងៗ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) | ដុល្លារអាមេរិក | ពាន់រៀល ( កំណត់សម្គាល់ 3 ) |
| ចំណាយបុគ្គលិក និងចំណាយពាក់ព័ន្ធ | 33,406,052 | 134,225,517 | 27,205,183 | 109,827,324 |
| ចំណាយបុគ្គលិក និងចំណាយពាក់ព័ន្ធ | 4,355,549 | 17,500,596 | 3,853,234 | 14,374,328 |
| ចំណាយរំលស់ | 3,043,458 | 12,228,614 | 3,560,646 | 15,555,506 |
| ចំណាយលើសម្ភារ និងបោះពុម្ព | 1,301,330 | 5,228,744 | 1,333,329 | 5,382,649 |
| ចំណាយលើការជួសជុលថែទាំ | 1,055,552 | 4,241,208 | 913,412 | 3,687,444 |
| ចំណាយទឹក និងភ្លើង | 1,003,892 | 4,033,638 | 953,394 | 3,848,852 |
| ថ្លៃអាជ្ញាប័ណ្ណ | 943,519 | 3,791,059 | 964,753 | 3,994,707 |
| ចំណាយលើទំនាក់ទំនង | 740,253 | 2,974,337 | 693,786 | 3,687,444 |
| ចំណាយយានយន្ត | 686,658 | 2,758,992 | 619,555 | 2,501,144 |
| ចំណាយលើសន្តិសុខ | 666,086 | 2,676,334 | 442,360 | 1,785,807 |
| ចំណាយលើសេវាកម្មធនាគារ | 617,916 | 2,482,786 | 431,313 | 1,741,211 |
| ចំណាយផ្នែកច្បាប់និងវិជ្ជាជីវៈ | 585,588 | 2,352,893 | 245,179 | 989,788 |
| ចំណាយទីផ្សារនិងផ្សាយពាណិជ្ជកម្ម | 568,366 | 2,283,695 | 1,104,050 | 4,457,050 |
| ចំណាយពិន័យ | 541,907 | 2,177,382 | 315,186 | 1,272,406 |
| ចំណាយបណ្តុះបណ្តាល/សន្និសីទបុគ្គលិក | 373,213 | 1,499,570 | 525,614 | 2,121,903 |
| ចំណាយដឹកជញ្ជូន | 350,455 | 1,408,128 | 340,340 | 1,373,953 |
| ចំណាយបរិច្ចាគសប្បុរសធម៌ | 32,347 | 129,970 | 75,950 | 306,609 |
| ចំណាយផ្សេងៗ | 2,149,712 | 8,637,542 | 306,292 | 1,236,501 |
| | **52,421,853** | **210,631,005** | **43,883,576** | **177,157,996** |

## ២៤. សាច់ប្រាក់សុទ្ធ (ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពប្រតិបត្តិការ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| *សកម្មភាពប្រតិបត្តិការ* | | | | |
| ចំណេញមុនបង់ពន្ធ | 28,233,400 | 113,441,801 | 23,805,608 | 96,103,240 |
| និយ័តកម្ម: | | | | |
| ចំណាយរំលស់ | 3,043,458 | 12,228,614 | 3,560,646 | 14,374,328 |
| ចំណាយលើមូលនិធិសោធ និវត្តន៍ | 2,167,017 | 8,707,074 | 1,905,098 | 7,690,881 |
| ការជម្រះបញ្ជីទ្រព្យ និងបរិក្ខារនិងទ្រព្យសកម្មអរូបី | 22,985 | 92,354 | 64,683 | 261,125 |
| ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ | (4,063) | (16,325) | (270) | (1,090) |
| ចំណាយសំវិធានធនសម្រាប់ការបាត់បង់ប្រាក់បញ្ញើនិងសាច់ប្រាក់នៅធនាគារនានាឥណទានផ្តល់ឲ្យអតិថិជន ការសន្យាផ្តល់ឥណទានហិរញ្ញប្បទាន និងការធានាហិរញ្ញវត្ថុ | 7,626,415 | 30,642,935 | 4,871,366 | 19,665,705 |
| បម្រែបម្រួល: | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | (39,316,328) | (157,973,006) | (11,494,524) | (46,403,393) |
| សមតុល្យនៅធនាគារនានា | - | - | 1,000,000 | 4,037,000 |
| ឥណទានផ្តល់ឲ្យអតិថជន | (220,162,850) | (884,614,331) | (199,446,599) | (805,165,920) |
| ទ្រព្យសកម្មផ្សេងៗ | (1,923,591) | (7,728,987) | (8,629,104) | (34,835,693) |
| ប្រាក់បញ្ញើរបស់អតិថិជននិងធនាគារហិរញ្ញវត្ថុនានា | 186,527,129 | 749,466,004 | 34,951,254 | 141,098,212 |
| មូលនិធិសោធននិវត្តន៍ | 1,832,635 | 7,363,527 | 1,506,776 | 6,082,854 |
| បំណុលផ្សេងៗ | 6,977,131 | 28,034,111 | 403,115 | 1,627,375 |
| **សាច់ប្រាក់សុទ្ធ ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | **(24,976, 622)** | **(100,356,229)** | **(147,501,951)** | **(595,465,376)** |
| ពន្ធលើប្រាក់ចំណេញបានបង់ | (5,732,874) | (23,034,688) | (3,910,413) | (15,786,337) |
| មូលនិធិសោធននិវត្តន៍បានបង់ | (1,454,278) | (5,843,289) | (678,879) | (2,740,635) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | **(32,163,814)** | **(129,234,206)** | **(152,091,243)** | **(613,992,348)** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ២៥. សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

### (ក) ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

ទំនាក់ទំនងសំខាន់ៗជាមួយសម្ព័ន្ធញាតិក្នុងការិយបរិច្ឆេទមានដូចតទៅ៖

| សម្ព័ន្ធញាតិ | ប្រតិបត្តិការ | 2018 | | 2017 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| MC | បំណុលបន្ទាប់បន្សំ | 10,000,000 | 40,180,000 | - | - |
| | ប្រាក់បញ្ញើ | - | - | 342,318 | 1,381,938 |
| | ចំណាយការប្រាក់ | 370,926 | 1,490,381 | - | - |
| | ចំណាយការប្រាក់ | 195,223 | 784,408 | 898,318 | 3,626,510 |
| | ការដកប្រាក់ | (9,840,145) | (39,537,701) | 821,095 | 3,314,761 |
| MIA | ប្រាក់កម្ចី | 10,000,000 | 40,180,000 | 10,000,000 | 40,370,000 |
| | ការទូទាត់សងប្រាក់កម្ចី | 13,340,000 | 53,600,120 | 1,670,000 | 6,741,790 |
| | ចំណាយការប្រាក់ | 1,645,758 | 6,612,654 | 1,591,377 | 6,424,389 |
| | ការដាក់ប្រាក់ | 438,676 | 1,762,601 | 442,334 | 1,785,702 |
| MJBL | ការដាក់ប្រាក់ | (83) | (335) | 5,389 | 21,755 |
| លាភការនៃអ្នកគ្រប់គ្រង | | 67,184 | 269,943 | 538,308 | 2,173,149 |
| គ្រួសារ Han | ការដាក់ប្រាក់ | 1,540,914 | 6,191,392 | 1,888,491 | 7,623,838 |
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | ការដាក់ប្រាក់ | (59,008) | (237,095) | 301,781 | 1,218,290 |
| | ឥណទាន | (181,551) | (729,472) | 419,802 | 2,173,149 |

### (ខ) សមតុល្យជាមួយសម្ព័ន្ធញាតិ

សមតុល្យជាមួយសម្ព័ន្ធញាតិ ក្នុងការិយបរិច្ឆេទមានដូចតទៅ៖

| សម្ព័ន្ធញាតិ | ទំនាក់ទំនង | 2018 | | 2017 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| MC | បំណុលបន្ទាប់បន្សំ | 10,000,000 | 40,180,000 | - | - |
| | ប្រាក់បញ្ញើ | 20,590,484 | 82,732,566 | 20,414,046 | 82,411,504 |
| MCC | ប្រាក់បញ្ញើ | 11,006,210 | 44,222,953 | 20,846,355 | 84,156,735 |
| MIA | បំណុលបន្ទាប់បន្សំ | 5,000,000 | 20,090,000 | 5,000,000 | 20,185,000 |
| | ប្រាក់កម្ចី | 14,990,000 | 60,229,820 | 18,330,000 | 73,998,210 |
| | ប្រាក់បញ្ញើ | 1,923,672 | 7,729,315 | 1,484,996 | 5,994,929 |
| MJBL | ប្រាក់បញ្ញើ | 16,533 | 66,428 | 16,616 | 67,079 |
| គ្រួសារ Han | ប្រាក់បញ្ញើ | 27,364,336 | 109,949,902 | 25,823,422 | 104,249,155 |
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | ប្រាក់បញ្ញើ | 387,213 | 1,555,821 | 446,221 | 1,801,394 |
| | ឥណទាន | 520,811 | 2,092,618 | 702,362 | 2,835,435 |

## ២៦. ការសន្យា និងយថាភាព

*( ក ) ភតិសន្យាប្រតិបត្តិការ*

ធនាគារមានកិច្ចសន្យាភតិសន្យា ចំពោះការជួលអគារការិយាល័យ ដែលមានកាតព្វកិច្ចជួលអប្បរមាដូចខាងក្រោម៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ក្នុងរយៈពេល 1ឆ្នាំ | 4,071,236 | 16,358,226 | 3,741,459 | 15,104,270 |
| ចន្លោះពី 1ឆ្នាំ ទៅ 5ឆ្នាំ | 10,260,786 | 41,227,838 | 10,836,477 | 43,746,858 |
| លើសពី 5ឆ្នាំ | 4,157,888 | 16,706,394 | 5,099,023 | 20,584,756 |
| | **18,489,910** | **74,292,458** | **19,676,959** | **79,435,884** |

*( ខ ) ភតិសន្យាប្រាក់កម្ចី*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| **ទ្រព្យសកម្ម** | | | | |
| កិច្ចសន្យាប្តូររូបិយប័ណ្ណ | 28,411,613 | 114,157,862 | 27,716,757 | 111,892,548 |
| សមតុល្យឥណទានវិបារូបណ៍ដែលមិនបានប្រើប្រាស់ | 9,382,558 | 37,699,117 | 6,025,772 | 24,326,042 |
| លិខិតឥណទាន | 689,000 | 2,768,402 | 57,790 | 233,298 |
| **បំណុល** | | | | |
| សមតុល្យប្រាក់កម្ចីដែល មិនបានប្រើប្រាស់ | 4,985,002 | 20,029,740 | - | - |
| លិខិតឥណទាន | 1,179,477 | 4,739,141 | 226,869 | 915,870 |
| ប័ណ្ណធានារបស់ធនាគារ | 129,125 | 518,824 | 511,479 | 2,064,841 |

*( គ ) យថាភាពលើពន្ធ*

ពន្ធត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានអង្កេត ដោយក្រុមអាជ្ញាធរ ដែលផ្តល់សិទ្ធិដោយច្បាប់ក្នុងការដាក់ពិន័យការដាក់ទណ្ឌកម្ម និងការគិតការប្រាក់។ ការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិពន្ធលើប្រតិបត្តិការច្រើនប្រភេទប្រឈមនឹងការបំណកស្រាយផ្សេងៗ។

បញ្ហាទាំងនេះ អាចបង្កើតឲ្យមានហានិភ័យពន្ធ ក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈធំជាងនៅប្រទេសដទៃទៀត។ គណៈគ្រប់គ្រងជឿជាក់ថាការធ្វើសំវិធានធនមានលក្ខណៈគ្រប់គ្រាន់ ដោយផ្អែកលើការបកស្រាយនៃច្បាប់សារពើពន្ធ។ ក៏ប៉ុន្តែអាជ្ញាធរជាប់ពាក់ព័ន្ធអាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ។

## ២៧. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

**ធនាគារប្រឈមមុខនឹងហានិភ័យមានដូចខាងក្រោម៖**

- ហានិភ័យប្រតិបត្តិការ
- ហានិភ័យឥណទាន
- ហានិភ័យទីផ្សារ និង
- ហានិភ័យសាច់ប្រាក់ងាយស្រួល

ធនាគារ មិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ (derivative financial instrument) ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និងការផ្តោះប្តូរអត្រាការប្រាក់ (interest rate swaps) ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួននោះទេ។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ២៧. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ក) ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់ផ្ទាល់ ឬប្រយោល ដែលកើតមានឡើងពីការខ្វះខាត ឬបរាជ័យនៃដំណើរការផ្ទៃក្នុង បុគ្គលិកបច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធ និងកើតឡើងពីកត្តាខាងក្រៅមួយចំនួនទៀត ដែលមិនមែនជាហានិភ័យឥណទាន ហានិភ័យទីផ្សារ និងហានិភ័យសាច់ប្រាក់ងាយស្រួល ដូចជា កត្តាដែលកើតមានឡើងពីតម្រូវការច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ និងស្តង់ដារដែលទទួលស្គាល់ជាទូទៅនៅក្នុងសហគ្រាសអាជីវកម្ម។

ការបាត់បង់ពីហានិភ័យប្រតិបត្តិការត្រូវបានគ្រប់គ្រង តាមរយៈការបង្កើតដំណើរការគ្រប់គ្រងហានិភ័យប្រតិបត្តិការការត្រួតពិនិត្យ និងរាយការណ៍សមស្រប លើសកម្មភាពអាជីវកម្ម តាមរយៈបណ្តាអង្គភាពត្រួតពិនិត្យ និងគាំទ្រផ្សេងៗដែលឯករាជ្យលើអង្គភាពអាជីវកម្ម ហើយនិងការត្រួតពិនិត្យដោយគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់ធនាគារតម្រូវឲ្យបង្កើតនូវរចនាសម្ព័ន្ធ តួនាទី និងគោលនយោបាយត្រួតពិនិត្យ និងការគ្រប់គ្រងរបស់អង្គភាពឲ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើន ត្រូវបានអនុវត្តរួមមាន ការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ប្រព័ន្ធត្រួត ពិនិត្យការកំណត់បារ៉ាម៉ែត្រ ការរៀបចំនូវនីតិវិធី និងឯកសារសំអាងនានា ព្រមទាំងអនុលោមភាពតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។

### (ខ) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ហិរញ្ញវត្ថុរបស់ធនាគារ ប្រសិនបើអ្នកខ្ចី ឬបដិភាគីខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាលើការបង់ប្រាក់ដើមចំពោះឥណទានផ្តល់ឲ្យអតិថិជន។

ហានិភ័យឥណទាន គឺជាហានិភ័យសំខាន់បំផុតក្នុងអាជីវកម្មរបស់ធនាគារ។ ហានិភ័យឥណទានជាចម្បងបណ្តាលមកពីសកម្មភាពនៃការផ្តល់ឥណទានដល់អតិថិជន។ ហើយមានហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុក្រៅខ្ទង់តារាងតុល្យការដូចជា ការសន្យាផ្តល់ឥណទានជាដើម។ ការគ្រប់គ្រងហានិភ័យឥណទានត្រូវអនុវត្តន៍ដោយគណៈកម្មការឥណទានរបស់ធនាគារ។

ហានិភ័យឥណទាន ត្រូវបានគ្រប់គ្រងតាមរយៈការវិភាគជាប្រចាំលើលទ្ធភាពរបស់អ្នកខ្ចីប្រាក់ និងសក្តានុពលនៃអ្នកខ្ចីប្រាក់ក្នុងការបំពេញកាតព្វកិច្ចសងប្រាក់ដើម និងការប្រាក់។ ហានិភ័យឥណទាន ក៏ត្រូវបានគ្រប់គ្រងដោយការទទួលវត្ថុបញ្ចាំ និងការធានាជាលក្ខណៈបុគ្គល។ គណៈគ្រប់គ្រងធ្វើការវាយតម្លៃឥណទានរៀងរាល់ឆ្នាំ បន្ទាប់ពីឥណទានត្រូវបានផ្តល់ឲ្យអតិថិជន ដើម្បីវិភាគតាមដានស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់អ្នកខ្ចីប្រាក់។

#### *ការវាស់វែងហានិភ័យឥណទាន*

ធនាគារ បានបង្កើតគោលការណ៍ហានិភ័យឥណទានស្នូល (Core Credit Risk Policy) ដើម្បីគ្រប់គ្រងហានិភ័យរបស់ធនាគារ។ ការពន្យារពេលនៃឥណទានត្រូវបានចាត់ចែងដោយកម្មវិធីឥណទានដែលបានរៀបចំគម្រោងសម្រាប់ផលិតផល ឬសំពាតឥណទានពិសេស រួមទាំងគោលដៅទីផ្សារប្រការ និងលក្ខខណ្ឌឯកសារសំអាង និងនីតិវិធីនៃផលិតផលឥណទាន ដែលត្រូវបានវាស់វែង និងផ្តល់ឲ្យ។

ធនាគារបានបែងចែកមុខងារ និងការទទួលខុត្រូវយ៉ាងច្បាស់លាស់រវាងអ្នកស្នើសុំឥណទាន អ្នកវាយតម្លៃឥណទាន និងអ្នកអនុម័តឥណទាន។

#### *ការគ្រប់គ្រងកម្រិតកំណត់ហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ*

ធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទានផ្តល់ឲ្យអតិថិជនទាំងអតិថិជនជាបុគ្គល ឬសហគ្រាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារគ្រប់គ្រងកម្រិតកំណត់ និងត្រួតពិនិត្យ ការប្រមូលផ្តុំហានិភ័យឥណទាន នៅពេលដែលពួកគេរកឃើញ។ ធនាគារជាតិនៃកម្ពុជាបានកំណត់និយមន័យហានិភ័យឥណទានធំថា ជាហានិភ័យឥណទានទូទៅ ដែលផ្តល់ឲ្យអ្នកទទួលផលជាឯកត្តបុគ្គលម្នាក់ ហើយលើសពី 10% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

យោងតាមលក្ខខណ្ឌនៃប្រកាសលេខ ធ7-06-226 ប្រ.ក របស់ធនាគារជាតិនៃកម្ពុជា ធនាគារចាំបាច់ត្រូវរក្សាគ្រប់ពេលវេលានូវអនុបាតអតិបរមានៃឥណទានសរុបផ្តល់ឲ្យអ្នកទទួលផលជាឯកត្តបុគ្គលម្នាក់ធៀបនឹងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារមិនឲ្យលើសពី 20%។ ហានិភ័យឥណទានធំៗ សរុបមិនត្រូវលើសពី 300% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារទេ។

ធនាគារប្រើប្រាស់គោលការណ៍ និងការអនុវត្តន៍ជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទានក្នុងនោះ គោលការណ៍ជាប្រពៃណី គឺការដាក់ធានាជាវត្ថុបញ្ចាំលើឥណទានដល់អតិថិជន ដែលជាការអនុវត្តទូទៅ។ ធនាគារអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលយកបាននូវចំណាត់ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន។

ប្រភេទវត្ថុបញ្ចាំដើម្បីធានាឥណទានដល់អតិថិជនមានដូចជា៖

- វត្ថុបញ្ចាំលើទ្រព្យសម្បត្តិសម្រាប់តាំងទីលំនៅ (មានដីធ្លី អគារ និងទ្រព្យសម្បត្តិផ្សេងៗ)
- បន្ទុកផ្សេងៗលើទ្រព្យសកម្មក្នុងអាជីវកម្មដូចជា ដីធ្លី និងអគារ
- សាច់ប្រាក់ក្នុងទម្រង់ជាប្រាក់បញ្ញើកម្រិតទុក

#### *គោលនយោបាយសំវិធានធននិងអឺមភែរមិន*

ចាប់ពីថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 ធនាគារតម្រូវឲ្យធ្វើតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើឥណទាន ដោយអនុលោមទៅតាមប្រកាសលេខ ប7-017-344 ប្រ.ក ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន និងសារាចរណែនាំលេខ ប7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន (កំណត់សំគាល់លេខ 2.7)។

### *ការប្រឈមនឹងហានិភ័យឥណទាន*

ហានិភ័យអតិបរមាឥណទានមុនពេលមានវត្ថុបញ្ចាំឬការពង្រឹងឥណទានផ្សេងៗ។

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 37,885,342 | 152,223,304 | 19,601,878 | 79,132,782 |
| សមតុល្យ នៅធនាគារនានា | 7,871,412 | 31,627,333 | 19,095,480 | 77,088,453 |
| ឥណទាន ផ្តល់ឲ្យអតិថិជន | 1,026,009,070 | 4,122,504,444 | 808,958,793 | 3,265,766,647 |
| ទ្រព្យសកម្មផ្សេងៗ | 8,442,684 | 33,922,705 | 7,416,578 | 29,940,726 |
| | **1,080,208,508** | **4,340,277,786** | **855,072,729** | **3,451,928,608** |
| សំវិធានធនសម្រាប់ការបាត់បង់ឥណទានផ្តល់ឲ្យអតិថិជន | (18,947,996) | (76,133,044) | (14,832,802) | (59,880,021) |
| | **1,061,260,512** | **4,264,144,742** | **840,239,927** | **3,392,048,587** |

តារាងខាងលើនេះបង្ហាញពីស្ថានការណ៍ ដែលអាក្រក់បំផុតសម្រាប់ហានិភ័យឥណទានរបស់ធនាគារនាកាលបរិយបរិច្ឆេទរាយការណ៍ ដោយមិនគិតពីវត្ថុបញ្ចាំនានាដែលមាន ឬក៏ការពង្រឹងឥណទានដែលមាន។ សម្រាប់ទ្រព្យសកម្មក្រៅ តារាងតុល្យការ ការប្រឈមដែលមានខាងលើគឺ អាស្រ័យទៅលើសមតុល្យយោងសុទ្ធ។

ដូចដែលបានបង្ហាញខាងលើ 94.98% នៃការប្រឈមអតិបរមាសរុបកើតឡើងពីការផ្តល់ឥណទានដល់អតិថិជន (នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 : 94.61%)។

គណៈគ្រប់គ្រងមានទំនុកចិត្តទៅលើសមត្ថភាពរបស់ខ្លួនឯងក្នុងការបន្តការគ្រប់គ្រង និងរក្សាការប្រឈមនឹងហានិភ័យឥណទានតិចតួចបំផុត សម្រាប់ធនាគារ ចំពោះឥណទានផ្តល់ដល់អតិថិជនមានដូចតទៅ៖

- 98.26% នៃសម្ពាធឥណទានត្រូវបានចាត់ទុកជាឥណទានមិនហួសការកំណត់ និងមិនខាតបង់ (2017: 97.93%)។
- ធនាគារ មានដំណើរការនៃការជ្រើសរើសវាយតម្លៃ និងការប្រមូលសំណងឥណទានតឹងរ៉ឹង សម្រាប់ផ្តល់ឥណទានឲ្យអតិថិជន។

### *ឥណទានដែលបានផ្តល់ឲ្យអតិថិជន*

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 3) |
| ឥណទានមិនហួសការកំណត់និងមិនខាតបង់ | 1,005,909,446 | 4,041,744,154 | 790,105,856 | 3,189,657,341 |
| ឥណទានហួសការកំណត់តែមិនខាតបង់ | 9,140,337 | 36,725,874 | 10,006,325 | 40,395,534 |
| ឥណទានដែលខាតបង់ | 10,959,287 | 44,034,416 | 8,846,612 | 35,713,772 |
| | **1,026,009,070** | **4,122,504,444** | **808,958,793** | **3,265,766,647** |

សម្រាប់គោលបំណងធ្វើសំវិធានធនលើឥណទានទ្រព្យបញ្ចាំដែលគិតថានឹងប្រមូលបានមកវិញ (លើកលែងតែសាច់ប្រាក់) គឺមិនត្រូវបានយកមកធ្វើការពិចារណា ដោយអនុលោមទៅតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។ សំវិធានធនសរុប សម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យសរុបមាន 18,869,561 ដុល្លារអាមេរិក (2017: 14,832,802 ដុល្លារអាមេរិក) ដែលជាសំវិធានធនជាក់លាក់តម្រូវ ដោយធនាគារជាតិនៃកម្ពុជា និងសំវិធានធនទូទៅបន្ថែមទៀតនៃឥណទានបាត់បង់។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ( ត )

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ២៧. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ( ត )

( ខ ) **ហានិភ័យឥណទាន ( ត )**

***ឥណទានដែលបានផ្តល់ឲ្យអតិថិជន ( ត )***

ដើម្បីអនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនសម្រាប់ឥណទានឲ្យអតិថិជន ដែលជាប់សង្ស័យត្រូវបានធ្វើឡើង សម្រាប់ឥណទានដែលយឺតយ៉ាវក្នុងសងត្រលប់លើសពី 30 ថ្ងៃ។ សំវិធានធនជាក់លាក់កម្រិតអប្បរមា សម្រាប់ឱនភាពត្រូវបានធ្វើឡើង ដោយអាស្រ័យទៅលើចំណាត់ថ្នាក់ ដែលបានធ្វើលុះត្រាតែមានព័ត៌មានផ្សេងទៀត ដែលបញ្ជាក់ពីនិន្នភាពនៃសមត្ថភាពសងត្រលប់របស់បដិភាគី។ ( កំណត់សំគាល់ 2.7 )

***ឥណទានមិនទាន់ហួសកាលកំណត់ និងមិនខាតបង់***

ឥណទានមិនទាន់ហួសកាលកំណត់ និងមិនខាតបង់ជាឥណទានមានគុណភាពល្អ ដែលមិនមានបទពិសោធន៍នៃការខាតបង់។ ឥណទានទាំងនេះត្រូវបានធានា ដោយទ្រព្យបញ្ចាំនិងគណៈគ្រប់គ្រងយល់ឃើញថា លទ្ធភាពដែលធ្វើឲ្យឥណទានខាតបង់មានកម្រិតទាប។

***ឥណទានហួសកាលកំណត់ តែមិនទាន់ខាតបង់***

ឥណទានហួសកាលកំណត់ និងមិនទាន់ខាតបង់ជាឥណទានផ្តល់ឲ្យអតិថិជន ដែលកិច្ចសន្យាទូទាត់សងការប្រាក់ ឬប្រាក់ដើមហួសកាលកំណត់លើសពី14ថ្ងៃ តែតិចជាង 30ថ្ងៃ លុះត្រាតែមានព័ត៌មាន ដែលបញ្ជាក់ក្រៅពីនេះ។ ឥណទានហួសកាលកំណត់តែមិនទាន់ខាតបង់ជាឥណទាន ដែលកិច្ចសន្យាទូទាត់ការប្រាក់ ឬប្រាក់ដើមហួសកាលកំណត់លើសពី 30ថ្ងៃ តែតិចជាង 90ថ្ងៃ លុះត្រាតែមានព័ត៌មានដែលបញ្ជាក់ក្រៅពីនេះ។ អនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឥណទាននេះត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំមើល ហើយត្រូវធ្វើសំវិធានធនតាមអត្រា 3%។

***ឱនភាពឥណទានផ្តល់ឲ្យអតិថិជន***

ឥណទានផ្តល់ឲ្យអតិថិជនដែលមាឱនភាព ជាឥណទានផ្តល់ឲ្យអតិថិជន ដែលធនាគារកំណត់ថាមានភស្តុតាងជាក់លាក់ថាមានឱនភាព និងកិច្ចសន្យាទូទាត់សងការប្រាក់ ឬប្រាក់ដើមហួសកាលកំណត់ ឬមានប្រវត្តិហួសកាលកំណត់លើសពី 90ថ្ងៃ លុះត្រាតែមានព័ត៌មានដែលបញ្ជាក់ក្រៅពីនេះ។

ទ្រព្យបញ្ចាំរបស់អតិថិជនភាគច្រើនជាដី ឬក៏ប័ណ្ណកម្មសិទ្ធិផ្ទះ ( ដែលមិនមែនជាប្លង់ដីជាផ្លូវការ ) ដោយសារធនាគារជាទូទៅផ្តល់ឥណទានដល់សហគ្រិនមានចំណូលទាបនៅតាមខេត្ត។ ក្នុងអំឡុងពេលធ្វើឥណទានធនាគារ មិនបានធ្វើការវាយតម្លៃទៅលើទ្រព្យបញ្ចាំទាំងខាងក្នុង និងខាងក្រៅ ដោយសារមិនបានទទួលប្លង់ដីស្របច្បាប់ផ្លូវការ ហើយមិនមានតម្លៃបញ្ជាក់ពីទ្រព្យបញ្ចាំ ដែលបញ្ជាក់ពីកម្មសិទ្ធិ។ យោងទៅតាមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា តម្លៃនៃទ្រព្យបញ្ចាំមិនត្រូវបានយកមកធ្វើការពិចារណាក្នុងការកំណត់ឱនភាពនៃឥណទានផ្តល់ឲ្យអតិថិជន។

***ឥណទានរៀបចំឡើងវិញ***

ឥណទានរៀបចំឡើងវិញ ជាឥណទានដែលកិច្ចសន្យាត្រូវបានពន្យារពេល ឬបុនហិរញ្ញប្បទានទៅតាមប្រការ និងលក្ខខណ្ឌដែលកំណត់កាលវិភាគសងត្រលប់ថ្មី ដោយផ្អែកលើរយៈពេលស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយនៃអ្នកសុំខ្ចី និង/ឬអ្នកសុំខ្ចីគ្មានលទ្ធភាពសងត្រលប់កម្ចីតាមកាលវិភាគនៃកិច្ចសន្យាដើម ដែលបានព្រមព្រៀង។ ឥណទានរៀបចំឡើងវិញ ត្រូវវិភាគលើមូលដ្ឋាននិទស្សន៍អាជីវកម្ម និងសមត្ថភាពសងត្រលប់របស់អ្នកសុំខ្ចីយោងទៅតាមព្យាករណ៍លំហូរសាច់ប្រាក់ថ្មី ដែលគាំទ្រដោយស្ថានភាពអាជីវកម្មថ្មី និងលក្ខខណ្ឌទីផ្សារជារួម ដោយផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន។

បន្ទាប់ពីឥណទានត្រូវបានរៀបចំឡើងវិញ ឥណទាននោះត្រូវរក្សាចំណាត់ថ្នាក់ដូចដើម ដោយមិនគិតពីដំណើរការល្អបន្ទាប់ពីការរៀបចំជាថ្មីឡើយ។ ការចាត់ថ្នាក់នេះមិនត្រូវឲ្យល្អជាងមុនឡើយ លុះត្រាតែគ្មានការហួសការកំណត់សងនៃការប្រាក់ និងប្រាក់ដើម បីវគ្គក្នុង 1ឆ្នាំ និងលើសពី 3ខែ ក្នុងរយៈ 1ឆ្នាំ។

***គោលនយោបាយជម្រះបញ្ជី***

អនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ធនាគារត្រូវជម្រះបញ្ជីឥណទានបុរេប្រទានផ្តល់ឲ្យអតិថិជនទាំងមូល ឬមួយផ្នែកចេញពីតារាងតុល្យការរបស់ខ្លួន នៅពេលដែលធនាគារបាត់សិទ្ធិតាមកិច្ចសន្យាគ្រប់គ្រងលើឥណទាន ឬនៅពេលដែលឃើញថាឥណទានមួយផ្នែក ឬទាំងមូលមិនអាចប្រមូលវិញបាន ឬគ្មានសង្ឃឹមថាឥណទាននេះអាចប្រមូលបានមកវិញទេ។

***ទ្រព្យបញ្ចាំ***

ធនាគាររក្សានូវទ្រព្យបញ្ចាំជាទ្រព្យសម្បត្តិ និងការធានា ចំពោះឥណទានផ្តល់ឲ្យអតិថិជន។ ការប៉ាន់ស្មាននូវតម្លៃទីផ្សារនៃទ្រព្យបញ្ចាំ គឺផ្អែកតាមការវាយតម្លៃទ្រព្យបញ្ចាំប្រចាំឆ្នាំ។

នៅក្នុងការិយបរិច្ឆេទធនាគារ មិនមានទទួលទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុទុកជាទ្រព្យបញ្ចាំធានា ចំពោះឥណទានបុរេប្រទានផ្តល់ឲ្យអតិថិជន។

*ការប្រមូលផ្តុំហានិភ័យរបស់ទ្រព្យសកម្មហិរញ្ញវត្ថុជាមួយការប្រឈមនឹងហានិភ័យឥណទាន*

ការប្រមូលផ្តុំកើតមានឡើង នៅពេលដែលចំនួនអ្នកសុំខ្ចីប្រកបអាជីវកម្មស្រដៀងគ្នា ឬនៅក្នុងតំបន់ភូមិសាស្រ្តដូចគ្នា ឬមានស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នា ដែលអាចនាំមានផលប៉ះពាល់ស្រដៀងគ្នាទៅលើលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ដែលរងផលប៉ះពាល់ពីការផ្លាស់ប្តូរនៃសេដ្ឋកិច្ចនយោបាយ ឬលក្ខខណ្ឌផ្សេងទៀត។ ការប្រមូលផ្តុំបង្ហាញពីបម្រែបម្រួលលទ្ធផលមធ្យមរបស់ធនាគារ ដែលរងផលប៉ះពាល់ពីវិស័យ ឬទីតាំងភូមសាស្រ្តជាក់លាក់ណាមួយ។

*សមតុល្យនៅធនាគារនានា*

ធនាគារបានដាក់ប្រាក់បញ្ញើរយៈពេលខ្លី ដែលលើសពីសាច់ប្រាក់ងាយស្រួលនៅធនាគារនានា ដែលបណ្តាលឲ្យមានការប្រឈមហានិភ័យបដិភាគី។ ធនាគារគ្រប់គ្រងការប្រឈមហានិភ័យបដិភាគីដោយធ្វើការវិភាគរត្រួតពិនិត្យបដិភាគីនីមួយៗ ដោយដាក់កម្រិតកំណត់ប្រាក់បញ្ញើក្នុងធនាគារមួយ និងដាក់ប្រាក់បញ្ញើនៅធនាគារផ្សេងៗគ្នា។

**(គ) ហានិភ័យទីផ្សារ**

ធនាគារប្រឈមនឹងហានិភ័យទីផ្សារ ជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុ នឹងប្រែប្រួលដោយសារការផ្លាស់ប្តូរតម្លៃទីផ្សារ។

ហានិភ័យទីផ្សារកើតឡើងមកពីស្ថានភាពចំហរនៃអត្រាការប្រាក់ រូបិយប័ណ្ណ និងផលិតផលមូលធនដែលប្រឈមនឹងចលនាទីផ្សារជាក់លាក់និងទូទៅ និងការផ្លាស់ប្តូរក្នុងកម្រិតងាយនៃអត្រាទីផ្សារ ឬតម្លៃទីផ្សារ ដូចជាអត្រាការប្រាក់គម្លាត ការប្រាក់នៃឥណទាន អត្រាប្តូររូបិយប័ណ្ណបរទេស និងតម្លៃមូលធន។

*ហានិភ័យរូបិយប័ណ្ណបរទេស*

ធនាគារប្រកបអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា និងប្រតិបត្តិការក្នុងរូបិយប័ណ្ណជាច្រើន ហើយប្រឈមនឹងហានិភ័យរូបិយប័ណ្ណជាច្រើនជាពិសេសជាមួយរូបិយប័ណ្ណ ប្រាក់រៀល ដុល្លារអាមេរិក ប្រាក់យ៉េន និងថៃបាត។ ល។

ហានិភ័យរូបិយប័ណ្ណកើតពីប្រតិបត្តិការពាណិជ្ជកម្មក្នុងពេលអនាគត និងកត់ត្រាទ្រព្យសកម្ម និងបំណុលជារូបិយប័ណ្ណមួយ ដែលមិនមែនជារូបិយប័ណ្ណមុខងាររបស់ធនាគារ។

គណៈគ្រប់គ្រងត្រួតពិនិត្យហានិភ័យរូបិយប័ណ្ណបរទេសជាមួយរូបិយប័ណ្ណមុខងារ តាមរយៈការគ្រប់គ្រងហានិភ័យរូបិយប័ណ្ណបរទេសដោយមិនឲ្យលើស 20% នៃមូលនិធិផ្ទាល់សុទ្ធ ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 សមតុល្យទ្រព្យសកម្ម និងបំណុលជារូបិយប័ណ្ណផ្សេងទៀត ក្រៅពីដុល្លារអាមេរិកមិនមានផលប៉ះពាល់អ្វីទេ។ ដូចនេះការវិភាគរូបិយប័ណ្ណបរទេសមិនត្រូវបានបង្ហាញឡើយ។

*ហានិភ័យអត្រាការប្រាក់*

ហានិភ័យអត្រាការប្រាក់ គឺសំដៅលើការប្រែប្រួលនូវចំណូលការប្រាក់សុទ្ធ ដែលជាលទ្ធផលនៃការផ្លាស់ប្តូរកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្ម និងបំណុល។ ហានិភ័យអត្រាការប្រាក់ត្រូវបានគ្រប់គ្រង តាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើអនុបាតចំណេញលើការវិនិយោគ តម្លៃទីផ្សារ ថ្លៃដើមនៃមូលនិធិបំណុល និងការវិភាគគំលាតវេទយិតភាពការប្រាក់។ សក្តានុពលនៃការធ្លាក់ចុះចំណូលការប្រាក់សុទ្ធ បណ្តាលមកពីការប្រែប្រួលអត្រាការប្រាក់ ដែលខុសប្រក្រតី ត្រូវបានត្រួតពិនិត្យដោយធៀបទៅនឹងកម្រិតហានិភ័យអាចទទួលយកបាន។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018**

## ២៧. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(គ) **ហានិភ័យទីផ្សារ** (ត)

***ហានិភ័យអត្រាការប្រាក់ (ត)***

ការវិភាគនៃហានិភ័យអត្រាការប្រាក់ទៅនឹងទ្រព្យសកម្ម និងបំណុលរបស់ធនាគារបានបង្ហាញដូចខាងក្រោម៖

| | រហូតដល់ 1ខែ | >1 - 3 ខែ | >3 - 12 ខែ | >1 - 5 ឆ្នាំ | លើសពី 5 ឆ្នាំ | គ្មានការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2018** | | | | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | 67,916,384 | 67,916,384 |
| សមតុល្យនៅធនាគារជាតិនៅធនាគារជាតិនៃកម្ពុជា | 6,950,000 | 1,900,000 | 20,160,000 | - | - | 139,960,016 | 168,970,016 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | 127,759 | - | - | - | - | 7,743,653 | 7,871,412 |
| ឥណទានផ្តល់ឲ្យអតិថិជន | 29,030,010 | 56,883,759 | 223,460,024 | 662,176,487 | 54,458,790 | - | 1,026,009,070 |
| ការវិនិយោគផ្សេងៗ | - | - | - | - | - | 50,000 | 50,000 |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | 8,442,684 | 8,442,684 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **36,107,769** | **58,783,759** | **243,620,024** | **662,176,487** | **54,458,790** | **224,112,737** | **1,279,259,566** |
| បំណុលហិរញ្ញវត្ថុ | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារហិរញ្ញវត្ថុផ្សេងៗ | 206,895,315 | 134,403,530 | 334,060,806 | 100,506,563 | - | 28,833,168 | 804,699,381 |
| ប្រាក់កម្ចី | 3,611,560 | 37,794,333 | 77,590,495 | 134,821,000 | - | - | 253,817,389 |
| បំណុលបន្ទាប់បន្សំ | - | - | 2,000,000 | 20,400,000 | 7,600,000 | - | 30,000,000 |
| មូលនិធិសោធននិវត្តន៍ | 129,026 | 258,051 | 1,161,231 | 6,193,230 | 5,182,338 | - | 12,923,876 |
| បំណុលផ្សេងៗ | - | - | - | - | - | 20,207,444 | 20,207,444 |
| **បំណុលហិរញ្ញវត្ថុសរុប** | **210,635,901** | **172,455,914** | **414,812,532** | **261,920,793** | **12,782,338** | **49,040,612** | **1,121,648,090** |
| **គំលាតការប្រាក់សរុប** | **(174,528,132)** | **(113,672,155)** | **(171,192,508)** | **400,255,694** | **41,676,452** | **175,072,125** | **157,611,476** |
| **សមមូល ពាន់រៀល** (កំណត់សំគាល់ 3) | **(701,254,034)** | **(456,734,719)** | **(687,851,497)** | **1,608,227,378** | **167,455,984** | **703,439,798** | **633,282,911** |

| | រហូតដល់1ខែ | >1 - 3 ខែ | >3 - 12 ខែ | >1 - 5 ឆ្នាំ | លើសពី 5 ឆ្នាំ | គ្មានការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ | - | - | - | - | - | 43,744,709 | 43,744,709 |
| សមតុល្យនៅធនាគារជាតិនៅធនាគារជាតិនៃកម្ពុជា | - | - | 3,839,485 | - | - | 15,762,393 | 19,601,878 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | 9,571,457 | 700,000 | - | - | - | 8,824,023 | 19,095,480 |
| ឥណទានផ្តល់ឲ្យអតិថិជន | 22,102,738 | 49,668,856 | 194,788,018 | 510,875,138 | 31,524,043 | - | 808,958,793 |
| ការវិនិយោគផ្សេងៗ | - | - | - | - | - | 50,000 | 50,000 |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | 7,416,578 | 7,416,578 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **31,674,195** | **50,368,856** | **198,627,503** | **510,875,138** | **31,524,043** | **75,797,703** | **898,867,438** |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| បំណុលហិរញ្ញវត្ថុ | 159,692,432 | 103,138,376 | 288,855,365 | 49,656,912 | - | 16,829,167 | 618,172,252 |
| ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារហិរញ្ញវត្ថុផ្សេងៗ | 125,000 | 24,461,667 | 49,836,666 | 140,365,000 | - | - | 214,788,333 |
| ប្រាក់កម្ចី | - | - | 2,000,000 | 11,000,000 | - | - | 13,000,000 |
| បំណុលបន្ទាប់បន្សំ | 70,471 | 140,943 | 632,241 | 3,382,620 | 6,150,227 | - | 10,378,502 |
| មូលនិធិសោធននិវត្តន៍ | - | - | - | - | - | 12,831,664 | 12,831,664 |
| បំណុលផ្សេងៗ | **159,887,903** | **127,740,986** | **341,326,272** | **204,404,532** | **6,150,227** | **29,660,831** | **869,170,751** |
| **គំលាតការប្រាក់សរុប** | **(128,213,708)** | **(77,372,130)** | **(142,698,769)** | **306,470,606** | **25,373,816** | **46,136,872** | **29,696,687** |
| **សមមូលពាន់រៀល (កំណត់សំគាល់ 3)** | **(517,598,739)** | **(312,351,289)** | **(576,074,930)** | **1,237,221,836** | **102,434,095** | **186,254,552** | **119,885,525** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ( ត )

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018**

## ២៧. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ( ត )

### (គ) ហានិភ័យទីផ្សារ ( ត )

#### *ហានិភ័យអត្រាការប្រាក់ ( ត )*

***ការវិភាគគំលាតវេទយិតភាពតម្លៃសមស្រប សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរ***

ធនាគារមិនបានកត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុតាមតម្លៃទីផ្សារសមស្រប ដោយភាពលំអៀងត្រូវបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផល។ ដូច្នេះការផ្លាស់ប្តូរអត្រាការប្រាក់នាចុងកាលបរិច្ឆេទពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ ឬខាតនោះទេ។

***ការវិភាគគំលាតវេទយិតភាពលំហូរសាច់ប្រាក់ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់អថេរ***

ធនាគារ ពុំមានឧបករណ៍ហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់អថេរ។ ដូច្នេះការវិភាគគំលាតវេទយិតភាពលំហូរសាច់ប្រាក់ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់អថេរមិនត្រូវបានបង្ហាញឡើយ។

### (ឃ) ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យ ដែលធនាគារមិនមានលទ្ធភាពបំពេញកាតព្វកិច្ចសងប្រាក់តាមកាលកំណត់សង ចំពោះបំណុលហិរញ្ញវត្ថុរបស់ខ្លួន និងការដកមូលនិធិរបស់ម្ចាស់ប្រាក់បញ្ញើ។ ជាលទ្ធផលធ្វើឲ្យខកខានការបំពេញកាតព្វកិច្ចសងបំណុលឲ្យម្ចាស់ប្រាក់បញ្ញើ និងមិនអាចបំពេញការសន្យាផ្តល់ឥណទាន។

***ដំណើរការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល***

គណៈគ្រប់គ្រងធនាគារ តាមដានសាច់ប្រាក់ងាយស្រួលក្នុងតារាងតុល្យការ និងគ្រប់គ្រងការប្រមូលផ្តុំ និងប្រវត្តិកាលអវសាន្តនៃបំណុល។ តាមដាននិងការរាយការណ៍ប្រចាំថ្ងៃនៃស្ថានភាពសាច់ប្រាក់ និងព្យាករណ៍ស្ថានភាពសាច់ប្រាក់ប្រចាំថ្ងៃសប្តាហ៍ និងខែជាការិយបរិច្ឆេទគន្លឹះ សម្រាប់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល។ គណៈគ្រប់គ្រងតាមដានបម្រែបម្រួលនៃម្ចាស់ប្រាក់បញ្ញើ និងបំណុលសំខាន់ ៗ និងព្យាករណ៍ការដកប្រាក់របស់ពួកគេ។

***មធ្យោបាយស្វែងរកមូលនិធិ***

ប្រភពចម្បងនៃសាច់ប្រាក់ងាយស្រួល គឺបានមកពីដើមទុនរបស់ភាគទុនិក ប្រាក់កម្ចី និងប្រាក់បញ្ញើពីអតិថិជន។ ប្រភពនៃសាច់ប្រាក់ងាយស្រួលត្រូវបានពិនិត្យយ៉ាងទៀតទាត់ តាមរយៈការពិនិត្យពីគណៈគ្រប់គ្រងលើកាលកំណត់របស់ប្រាក់បញ្ញើមានការកំណត់អ្នកដាក់ប្រាក់បញ្ញើសំខាន់ៗ ប្រាក់កម្ចី និងបំណុលបន្ទាប់បន្សំ។

***លំហូរសាច់ប្រាក់មិនមែននិទស្សន៍***

តារាងនៅទំព័របន្ទាប់នេះបង្ហាញពីលំហូរសាច់ប្រាក់ ដែលត្រូវបង់ដោយធនាគារដែលមិនមែនជាបំណុលហិរញ្ញវត្ថុនិទស្សន៍ តាមកាលកំណត់តាមកិច្ចសន្យានៅក្នុងការិយបរិច្ឆេទ ដែលមាននៅតារាងតុល្យការនោះទេ។ ចំនួនទឹកប្រាក់ដែលបានបង្ហាញនៅក្នុងតារាងគឺជាលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលមិនបញ្ចុះតម្លៃ ខណៈដែលធនាគារគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ដោយផ្អែកលើលំហូរសាច់ប្រាក់នាពេលអនាគតដែលមិនបញ្ចុះតម្លៃ។

| | រហូតដល់1ខែ | >1 - 3 ខែ | >3 - 12 ខែ | >1 - 5 ឆ្នាំ | លើសពី 5 ឆ្នាំ | គ្មានការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 67,916,384 | - | - | - | - | - | 67,916,384 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 56,409,306 | 20,024,617 | 53,833,855 | 26,702,238 | - | 12,000,000 | 168,970,016 |
| សមតុល្យនៅធនាគារនានា | 7,871,412 | - | - | - | - | - | 7,871,412 |
| ឥណទាន ផ្តល់ឲ្យអតិថិជន | 29,030,010 | 56,883,759 | 223,460,024 | 662,176,487 | 54,458,790 | - | 1,026,009,070 |
| ការវិនិយោគផ្សេងៗ | - | - | - | - | 50,000 | - | 50,000 |
| ទ្រព្យសកម្មផ្សេងៗ | 8,442,684 | - | - | - | - | - | 8,442,684 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **169,669,796** | **76,908,376** | **277,293,879** | **688,878,725** | **54,508,790** | **12,000,000** | **1,279,259,566** |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារហិរញ្ញវត្ថុផ្សេងៗ | 235,728,483 | 134,403,530 | 334,060,806 | 100,506,563 | - | - | 804,699,381 |
| ប្រាក់កម្ចី | 3,611,560 | 37,794,333 | 77,590,495 | 134,821,000 | - | - | 253,817,388 |
| បំណុលបន្ទាប់បន្សំ | - | - | 2,000,000 | 20,400,000 | 7,600,000 | - | 30,000,000 |
| មូលនិធិសោធននិវត្តន៍ | 129,026 | 258,051 | 1,161,231 | 6,193,230 | 5,182,338 | - | 12,923,876 |
| បំណុលផ្សេងៗ | 4,290,077 | 6,166,186 | 6,420,233 | 2,478,207 | 830,639 | 22,102 | 20,207,444 |
| បំណុលហិរញ្ញវត្ថុសរុប | **243,759,146** | **178,622,100** | **421,232,765** | **264,399,000** | **13,612,977** | **22,102** | **1,121,648,089** |
| គំលាតសាច់ប្រាក់ងាយស្រួល -សុទ្ធសរុប | **(74,089,350)** | **(101,713,724)** | **(149,938,886)** | **424,479,725** | **40,895,813** | **11,977,898** | **157,611,477** |
| សមមូលពាន់រៀល (កំណត់សំគាល់ 3) | **(297,691,008)** | **(408,685,743)** | **(578,346,444)** | **1,705,559,535** | **164,319,377** | **48,127,194** | **633,282,915** |

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## ២៧. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(ឃ) ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

*លំហូរសាច់ប្រាក់មិនមែននិទស្សន៍ (ត)*

| | រហូតដល់1ខែ | >1 - 3 ខែ | >3 - 12 ខែ | >1 - 5 ឆ្នាំ | លើសពី 5 ឆ្នាំ | គ្មានការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 43,744,709 | - | - | - | - | - | 43,744,709 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 15,762,393 | - | 3,839,485 | - | - | - | 19,601,878 |
| សមតុល្យនៅធនាគារនានា | 18,395,480 | 700,000 | - | - | - | - | 19,095,480 |
| ឥណទាន ផ្តល់ឲ្យអតិថិជន | 22,102,737 | 49,668,856 | 194,788,017 | 510,875,139 | 31,524,044 | - | 808,958,793 |
| ការវិនិយោគផ្សេងៗ | - | - | - | - | 50,000 | - | 50,000 |
| ទ្រព្យសកម្មផ្សេងៗ | 7,416,578 | - | - | - | - | - | 7,416,578 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **107,421,897** | **50,368,856** | **198,627,502** | **510,875,139** | **31,574,044** | **-** | **898,867,438** |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារហិរញ្ញវត្ថុនានា | 176,521,599 | 103,138,376 | 288,855,365 | 49,656,912 | - | - | 618,172,252 |
| ប្រាក់កម្ចី | 125,000 | 24,461,666 | 49,836,667 | 140,365,000 | - | - | 214,788,333 |
| បំណុលបន្ទាប់បន្សំ | - | - | 2,000,000 | 11,000,000 | - | - | 13,000,000 |
| មូលនិធិសោធននិវត្តន៍ | 70,471 | 140,943 | 634,241 | 3,382,620 | 6,150,227 | - | 10,378,502 |
| បំណុលផ្សេងៗ | 7,933,844 | 3,991,374 | 35,021 | 46,695 | 824,730 | - | 12,831,664 |
| បំណុលហិរញ្ញវត្ថុសរុប | **184,650,914** | **131,732,359** | **341,361,294** | **204,451,227** | **6,974,957** | **-** | **869,170,751** |
| **គំលាតសាច់ប្រាក់ងាយស្រួល - សុទ្ធសរុប** | **(77,229,017)** | **(81,363,503)** | **(142,733,792)** | **306,423,912** | **24,599,087** | **-** | **29,696,687** |
| **សមមូលពាន់រៀល (កំណត់សំគាល់ 3)** | **(311,773,542)** | **(328,464,462)** | **(576,216,318)** | **1,237,033,333** | **99,306,514** | **-** | **119,885,525** |

( ង ) **ការគ្រប់គ្រង់ប្រាក់ដើមទុន**

(i) **បទប្បញ្ញត្តិដើមទុន**

ចក្ខុវិស័យរបស់ធនាគារក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញក្នុងតារាងតុល្យការ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា
- ការពារលទ្ធភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ដូចនេះ ធនាគារអាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍អាជីវកម្ម។

ធនាគារជាតិនៃកម្ពុជា តម្រូវគ្រប់ស្ថាប័នធនាគារឲ្យបំពេញនូវ (i) តម្រូវការដើមទុនចុះបញ្ជីអប្បបរមា និង (ii) អនុលោមតាមអនុបាតសាធនភាព អនុបាតសាច់ប្រាក់ងាយស្រួល និងតម្រូវការផ្សេងៗទៀត។

(ii) **ការបែងចែកដើមទុន**

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងក្នុងកម្រិតបង្កើនប្រសិទ្ធិភាពអតិបរមាប្រាក់ចំណេញពីដើមទុនដែលបែងចែក។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗ ត្រូវផ្អែកទៅតាមដើមទុន ដែលកំណត់ដោយច្បាប់។

( ច ) **តម្លៃសមស្រប**

តម្លៃសមស្រប គឺជាតម្លៃដែលទ្រព្យសកម្មអាចប្តូរបាន ឬជាបំណុលត្រូវទូទាត់ តាមរយៈគោលការណ៍ជំហ៊ោងដៃ (arms-length-basis)។ ដោយសារតម្លៃសមស្រប និងតម្លៃទីផ្សារពុំមានសម្រាប់វាយតម្លៃបានជាសារវន្ត ដូច្នោះការវាយតម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលរបស់ធនាគារមិនបានបង្ហាញទេ។

## ២៨. ព្រឹត្តិការណ៍ជាបន្តបន្ទាប់

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានបញ្ហាឬកាលៈទេសៈផ្សេងទៀត ដែលកើតឡើងបន្ទាប់ពីកាលបរិច្ឆេទនៃតារាងតុល្យការ ដែលតម្រូវឲ្យធ្វើនិយ័តកម្ម ឬការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## ២៩. ព្រឹត្តិការណ៍ក្រោយតារាងតុល្យការ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍សំខាន់ណាមួយកើតឡើង ចំពោះកាលបរិច្ឆេទនៃតារាងតុល្យការ ដែលតម្រូវអោយមានការធ្វើនិយ័តកម្ម ឬក៏បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារនេះទេ។

# កំណត់ចំណាំ



ធនាគារ ស្ថាបនា

SATHAPANA BANK


អគារលេខ ៨៣ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

023/081 999 010

@sathapanabank

customercare@sathapana.com.kh

www.sathapana.com.kh